**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Royal University of Law and Economics

Université Royale de Droit et des Sciences Economiques


## សារណាបញ្ចប់ការសិក្សា

# ការជំនុំជម្រះសាជាថ្មី

ស្រាវជ្រាវពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **តាំង សៀវអៀង**

កញ្ញា **ហុង ម៉ារីណិច**

សាស្ត្រាចារ្យណែនាំ

លោក **គេត សុជាតិ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៨

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Royal University of Law and Economics

Université Royale de Droit et des Sciences Economiques

# សារណាបញ្ចប់ការសិក្សា

# ការជំនុំជម្រះសាជាថ្មី

ស្រាវជ្រាវពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **តាំង សៀអៀង**

កញ្ញា **ហុង ម៉ារីណិច**

សាស្ត្រាចារ្យណែនាំ

លោក **កេត សុជាតិ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៨

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# អារម្ភកថា

បន្ទាប់ពីបានឆ្លងកាត់ការក្រេបជញ្ជក់យកចំណេះដឹង នៅថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្រ្ត នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច អស់រយៈពេលជិត០៤ឆ្នាំកន្លងមកនេះ យើងខ្ញុំទាំងពីររូប មានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ដែលទទួលបានឱកាសក្នុងការសរសេរសារណាបញ្ចប់ការសិក្សា ។ ចំពោះការសរសេរសារណាបញ្ចប់ការសិក្សានេះ យើងខ្ញុំទាំងពីរនាក់មានគោលបំណងរួមមួយ គឺដើម្បីអភិវឌ្ឍចំណេះដឹងបន្ថែម ទៅលើអ្វីដែលបានសិក្សាកន្លងមក ព្រមទាំងដើម្បីចងក្រងទុកស្នាដៃមួយទុកសំរាប់ឱ្យនិស្សិតជំនាន់ក្រោយសិក្សា ស្វែងយល់ និងស្រាវជ្រាវបន្ថែម ។ ហេតុនេះហើយ ទើបយើងខ្ញុំទាំងពីរនាក់ បានសម្រេចចិត្ត ជ្រើសរើសយកប្រធានបទមួយ គឺ "**ការជំនុំជម្រះសាជាថ្មី**" ដើម្បីតាក់តែងធ្វើជាសារណាបញ្ចប់ការសិក្សា ។

ដើម្បីចងក្រងនូវសារណានេះឡើង យើងខ្ញុំទាំងពីរនាក់បានខិតខំប្រឹងប្រែងក្នុងការស្វែងរកឯកសារដែលពាក់ព័ន្ធពីគ្រប់មជ្ឈដ្ឋាន ដើម្បីធ្វើជាមូលដ្ឋានមួយក្នុងការសរសេរប្រធានបទនេះឡើងឱ្យមានភាពក្បោះក្បាយ ។ តាមរយៈការស្រាវជ្រាវលើប្រធានបទសារណានេះ យើងខ្ញុំសង្កេតឃើញថា ឯកសារជំនួយស្មារតីពាក់ព័ន្ធនឹងប្រធានបទនេះ ហាក់បីដូចជាមិនទាន់មានគ្រប់គ្រាន់នៅឡើយ ហើយយើងខ្ញុំក៏មិនហ៊ានធានាថាការស្រាវជ្រាវនេះមានភាពល្អឥតខ្ចោះមួយរយភាគរយនោះដែរ ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែការប្តេជ្ញាចិត្ត និងខិតខំប្រឹងប្រែងអស់ពីសមត្ថភាពរបស់យើងខ្ញុំទាំងពីរនាក់ បូករួមទាំងការជួយណែនាំពីសំណាក់លោកគ្រូដឹកនាំថែមទៀតនោះ ជាលទ្ធផល សារណាបញ្ចប់ការសិក្សាមួយនេះ មានរួមបញ្ចូលនូវខ្លឹមសារល្អប្រសើរជាច្រើន។

ជាទីបញ្ចប់ យើងខ្ញុំទាំងពីរនាក់ សង្ឃឹមថាស្នាដៃមួយនេះនឹងទទួលបានលទ្ធផលល្អ ហើយអាចក្លាយជាឯកសារជំនួយស្មារតីដល់ការស្រាវជ្រាវបន្ថែមរបស់មិត្តនិស្សិត និងអ្នកសិក្សាស្រាវជ្រាវបន្តទៅទៀត ។ ចំពោះរាល់កំហុសខុសឆ្គងពាក់ព័ន្ធនឹងអក្ខរាវិរុទ្ធ និងខ្លឹមសារទាំងឡាយ យើងខ្ញុំនឹងរងចាំទទួលនូវរាល់ការរិះគន់ក្នុងន័យស្ថាបនា ពីសំណាក់សាស្រ្តាចារ្យ និស្សិត ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវទាំងអស់ ដោយក្តីសោមនស្សរីករាយ និងការគោរពរាប់អានដ៏ជ្រាលជ្រៅពីយើងខ្ញុំទាំងពីរនាក់ ។

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **តាំង សៀវអៀង** និងនាងខ្ញុំឈ្មោះ **ហុង ម៉ារីណែច** ជានិស្សិតឆ្នាំទី៤ ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី១៨ នៃសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

**សូមគោរពប្រតិបត្តិ និងសូមសម្ដែងនូវកតញ្ញូតាធមយ៉ាងជ្រាលជ្រៅជូនចំពោះ៖**

- អ្នកមានគុណទាំងពីររបស់ខ្ញុំបាទគឺលោកឪពុក **គឹម តាំងតុង** និងអ្នកម្ដាយ **វៀម ពៅ**

- អ្នកមានគុណទាំងពីររបស់នាងខ្ញុំគឺលោកឪពុក **នូ ណាំហុង** និងអ្នកម្ដាយ **សុខ នាង**

លោកឪពុក អ្នកម្ដាយ ជាអ្នកមានគុណដែលបានផ្ដល់កំណើត និងបានខិតខំអស់ពីកម្លាំងកាយចិត្ត ដោយពុំខ្លាចនឿយហត់ក្នុងការចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មានប្រៀនប្រដៅ និងបានបញ្ជូនពួកខ្ញុំទៅសិក្សា រៀនសូត្រ និងប្រព្រឹត្តតែអំពើល្អ ។ លោកឪពុក អ្នកម្ដាយ ក៏បានធ្វើការឧបត្ថម្ភគាំទ្រ ទាំងផ្នែកស្មារតី ធនធាន និងសម្ភារៈ តាំងពីកូនៗនៅវ័យកុមារ រហូតដល់ពេញវ័យ ហើយថែមទាំងជម្រុញឱ្យយើងខ្ញុំមានឱកាសបានចូលសិក្សា ក្រេបជញ្ជក់ចំណេះដឹង តាំងពីកម្រិតមូលដ្ឋានរហូតមកដល់ថ្នាក់បរិញ្ញាបត្រ ដែលនឹងត្រូវបញ្ចប់នាពេលដ៏ខ្លីខាងមុខនេះ ។

យើងខ្ញុំសូមសម្ដែងការដឹងគុណយ៉ាងជ្រាវជ្រៅផងដែរចំពោះ៖

- **ឯកឧត្ដម លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្ដល់ឱកាសឱ្យយើងខ្ញុំ ពង្រីកចំណេះដឹង និងបង្កើតជំនាញ តាមរយៈការចងក្រងសារណាបញ្ចប់ការសិក្សានេះឡើង ។

- ជាពិសេស **លោកសាស្ត្រាចារ្យណែនាំ កេត សុជាតិ** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងកាលវិភាគដ៏មមាញឹក ប្រឹងប្រែង មិនខ្លាចនឿយហត់ក្នុងការចង្អុលបង្ហាញផ្លូវ និងក្នុងការណែនាំ កែប្រែនូវរាល់កំហុសឆ្គងដែលយើងខ្ញុំបានបង្កើតឡើងក្នុងការសរសេរសារណានេះ ដើម្បីធានាឱ្យបាននូវសមិទ្ធផលមួយដែលមានគុណភាព ។

- **លោក លោកស្រីសាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសេដ្ឋកិច្ចទាំងមូលដែលបានបង្ហាត់បង្រៀន អប់រំ ណែនាំ និងផ្ដល់នូវឱវាទ រួមទាំងបទពិសោធន៍ល្អៗគ្រប់បែបយ៉ាងដល់យើងខ្ញុំ តាំងពីថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន រហូតដល់ពេលបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។

- សិស្សច្បង និងមិត្តនិស្សិត ដែលតែងតែជួយណែនាំអំពីការស្រាវជ្រាវរកឯកសារ និងជួយផ្ដល់ឯកសារជំនួយដល់រូបយើងខ្ញុំ ព្រមទាំងជួយពិនិត្យពាក្យពេចន៍ អក្ខរាវិរុទ្ធ និងកែតម្រូវកំហុសខុសឆ្គង និងផ្ដល់ជាកម្លាំងចិត្ត ជម្រុញឱ្យយើងខ្ញុំខិតខំបន្តការសិក្សាស្រាវជ្រាវនេះរហូតបានសម្រេច។

ខ្ញុំបាទ **តាំង សៀវអៀង** និងនាងខ្ញុំ **ហុង ម៉ារីណិច** សូមគោរពជូនពរ និងលើកហត្ថទាំងទ្វេ បួងសួងដល់ទេវតា ដែលតាមថែរក្សាព្រះរាជាណាចក្រកម្ពុជាទាំងមូល សូមជួយតាមថែរក្សាលោកអ្នកមានគុណទាំងទ្វេ ឯកឧត្តម សាស្ត្រាចារ្យ លោក  លោកស្រីសាស្ត្រាចារ្យ និងអ្នកបានជួយទំនុកបម្រុងក្នុងកិច្ចការស្រាវជ្រាវនេះ ឱ្យជួបប្រទះនូវពុទ្ធពរទាំងបួន ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមទទួលបានជោគជ័យលើគ្រប់ភារកិច្ច ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ...... ១

**ជំពូកទី១ សញ្ញាណនៃការជំនុំជម្រះសាជាថ្មី** ...... ៣

**ផ្នែកទី១ ប្រវត្តិនៃការជំនុំជម្រះសាជាថ្មី** ...... ៣

**ផ្នែកទី២ អត្ថន័យ និងគោលបំណងនៃការជំនុំជម្រះសាជាថ្មី** ...... ៤

**ផ្នែកទី៣ រចនាសម្ព័ន្ធនៃការជំនុំជម្រះសាជាថ្មី** ...... ៥

**ជំពូកទី២ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី** ...... ៦

**ផ្នែកទី១ លក្ខខណ្ឌសារធាតុ** ...... ៦

**កថាខណ្ឌទី១ មូលហេតុនៃការជំនុំជម្រះសាជាថ្មី** ...... ៦

១.១ ករណីដែលមានការបំពាននីតិវិធីធ្ងន់ធ្ងរ ...... ៧

១.២ ករណីមានភាពមិនប្រក្រតីនៃមូលដ្ឋាននៃសាលក្រម ឬ សាលដីកា ...... ៩

១.៣ ករណីដែលមានការភ្លេចបញ្ចូលការវិនិច្ឆ័យ ...... ១២

១.៤ ករណីដែលសាលក្រម ឬ សាលដីកាមានខ្លឹមសារផ្ទុយគ្នា ...... ១៣

១.៥ ករណីពិសេស ...... ១៤

**កថាខណ្ឌទី២ ភាពបន្ទាប់បន្សំនៃការជំនុំជម្រះសាជាថ្មី** ...... ១៤

២.១ ការបានធ្វើការអះអាង ...... ១៥

២.២ ការមិនបានធ្វើការអះអាង ...... ១៥

២.២.១ ការមិនបានធ្វើការអះអាងក្នុងដំណើរការនីតិវិធី ...... ១៦

២.២.២ ការមិនបានធ្វើការអះអាងក្នុងបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ...... ១៦

**កថាខណ្ឌទី៣ ភាគីនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី** ...... ១៦

៣.១ គោលការណ៍ ...... ១៧

៣.២ អញ្ញត្រកម្ម ...... ១៧

**កថាខណ្ឌទី៤ កម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី** ...... ១៨

៤.១ សាលក្រម ឬ សាលដីកា ...... ១៨

៤.២ ដីកាសម្រេច ........................................ ១៩
**កថាខណ្ឌទី៥ ការកម្រិតអំឡុងពេល** ........................................ ២០
**ផ្នែកទី២  លក្ខខណ្ឌទម្រង់** ........................................ ២១
**កថាខណ្ឌទី១ ការសរសេរពាក្យបណ្តឹង** ........................................ ២១
១.១ ចំណុចដែលត្រូវសរសេរ ........................................ ២១
១.២ ឯកសារភ្ជាប់ ........................................ ២២
**កថាខណ្ឌទី២ ការដាក់ពាក្យបណ្តឹង** ........................................ ២២
២.១ តុលាការមានសមត្ថកិច្ច ........................................ ២៣
២.២ ពន្ធដាក់ពាក្យសុំ ........................................ ២៥
**ជំពូកទី៣  ចំណាត់ការលើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី** ........................................ ២៦
**ផ្នែកទី១  ការវិនិច្ឆ័យ និងសម្រេចសេចក្តីលើភាពត្រឹមត្រូវនៃបណ្តឹង** ........................................ ២៦
**កថាខណ្ឌទី១ ភាពស្របច្បាប់នៃបណ្តឹង** ........................................ ២៦
**កថាខណ្ឌទី២ អត្ថិភាព ឬ នត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី** ........................................ ២៧
**ផ្នែកទី២  ការវិនិច្ឆ័យ និងសម្រេចសេចក្តីលើអង្គសេចក្តី** ........................................ ២៨
**កថាខណ្ឌទី១ ការវិនិច្ឆ័យលើអង្គសេចក្តី** ........................................ ២៩
**កថាខណ្ឌទី២ សាលក្រម ឬ សាលដីកា** ........................................ ២៩
២.១ ការច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី ........................................ ២៩
២.២ ការលុបចោលសេចក្តីសម្រេចដើម និងសម្រេចសាជាថ្មី ........................................ ៣០
**សេចក្តីសន្និដ្ឋាន** ........................................ ៣១
**អនុសាសន៍** ........................................ ៣២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីរូប

**រូបទី១ ៖** រចនាសម្ព័ន្ធផ្នែកតាមទីតាំងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី

**រូបទី២៖** តុលាការដែលមានសមត្ថកិច្ចចំពោះបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

# សេចក្តីផ្តើម

ការជំនុំជម្រះលើរឿងក្តីរដ្ឋប្បវេណី គឺជានីតិវិធីមួយដ៏សំខាន់ ដែលអាចឱ្យវិវាទទទួលបាននូវចំណាត់ការ និងភាពយុត្តិធម៌ពីតុលាការ ។ បណ្តឹងរដ្ឋប្បវេណីត្រូវបានធ្វើឡើង ដើម្បីដោះស្រាយនូវវិវាទរវាងបុគ្គលឯកជន ដែលមិនអាចត្រូវបានដោះស្រាយដោយសន្តិវិធីក្រៅផ្លូវតុលាការបាន ដែលទាមទារឱ្យមានអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ច គឺតុលាការទាំងបីថ្នាក់នេះឯង ។ បន្ទាប់ពីឆ្លងកាត់ការវិនិច្ឆ័យហើយ ទំនាក់ទំនងសិទ្ធិដែលត្រូវបានចូលជាស្ថាពរដោយសាលក្រម ឬ សាលដីកាជាគោលការណ៍ គឺមិនអាចត្រូវបានយកមកធ្វើការវិនិច្ឆ័យម្តងទៀតបានឡើយ ដោយសារអានុភាពនៃអាជ្ញាអស់ជំនុំត្រូវបានកើតឡើងនៅពេលសាលក្រម ឬ សាលដីកាចូលជាស្ថាពរ[១] ។ ប្រសិនបើភាគីត្រូវបានអនុញ្ញាតឱ្យធ្វើការតតាំងគ្នាចំពោះសិទ្ធិដែលត្រូវបានចូលជាស្ថាពររួចមកហើយ ឬ ក្នុងន័យម្យ៉ាងទៀត ប្រសិនបើមិនមានអត្ថិភាពនៃអានុភាពនៃអាជ្ញាអស់ជំនុំទេ នោះវិវាទមួយនោះនឹងគ្មានថ្ងៃដែលអាចត្រូវបានដោះស្រាយបានឡើយ ។ ទោះបីជាយ៉ាងនេះក៏ដោយ ការរក្សាទុកនូវអត្ថិភាពនៃសាលក្រម ឬ សាលដីកាស្ថាពរ ដែលមានវិការៈធ្ងន់ធ្ងរក្នុងការវិនិច្ឆ័យ ក៏មិនត្រឹមត្រូវដែរ ពីព្រោះវាផ្ទុយទៅនឹងគោលការណ៍គ្រឹះនៃបណ្តឹងរដ្ឋប្បវេណី ដែលមានដូចជា គោលការណ៍នៃការជម្រះក្តីដោយយុត្តិធម៌ និងគោលការណ៍នៃការការពារសិទ្ធិស្របច្បាប់របស់បុគ្គលឯកជន ជាអាទិ៍ ។ ហេតុដូចនេះហើយ ទើបរបបនៃការជំនុំជម្រះសាជាថ្មី ត្រូវបានបង្កើតឡើង ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃគោលការណ៍ទាំងនេះ ។

នីតិវិធីនៃការជំនុំជម្រះសាជាថ្មី គឺជានីតិវិធីឧបាស្រ័យពិសេស ដែលផ្តល់លទ្ធភាពឱ្យភាគីនៃសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ ឬ តតិយជន ដែលពាក់ព័ន្ធ ហើយទទួលឥទ្ធិពលពីសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ អាចធ្វើការទាមទារឱ្យតុលាការលុបចោលនូវសាលក្រម ឬ សាលដីកាដើមនោះ និងសម្រេចសេចក្តីសាជាថ្មី ចំពោះអង្គសេចក្តី ដែលមានអានុភាពនៃអាជ្ញាអស់ជំនុំ ដោយការចូលជាស្ថាពរនៃសាលក្រម ឬ សាលដីការួចមកហើយ ។ ប៉ុន្តែការជំនុំជម្រះសាជាថ្មីលើអង្គហេតុដែលត្រូវបានជំនុំជម្រះរួចមកហើយបែបនេះ បង្កឱ្យមានភាពស្មុគស្មាញ និងការចំណាយពេលវេលា និងថវិកាជាច្រើន អាស្រ័យហេតុនេះ លុះត្រាតែមានករណីយ៉ាងពិសេស និងមានការគោរពនូវលក្ខខណ្ឌយ៉ាងតឹងរ៉ឹង ដូចមានកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីមាត្រា៣០៧ ដល់មាត្រា៣១៨ ប៉ុណ្ណោះ ទើបនីតិវិធីនៃការជំនុំជម្រះសាជាថ្មីត្រូវបានទទួលស្គាល់ ។

---

[១] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៩៤។

ដោយសារតែមើលឃើញពីភាពស្មុគស្មាញក្នុងការអនុវត្តនីតិវិធីនៃការទាមទារឱ្យជំនុំជម្រះសាជាថ្មីបែបនេះហើយ បានជាប្រធានបទស្តីអំពី "**ការជំនុំជម្រះសាជាថ្មី**" នេះ ត្រូវបានផ្តួចផ្តើមបង្កើតជាសារណា រហូតដល់លេចចេញជារូបរាងឡើង ក្នុងគោលបំណងស្វែងរកចំណុចជាមូលដ្ឋានមួយ ក្នុងការអនុវត្តដំណើរការនីតិវិធី ចាប់តាំងពីការដាក់ពាក្យបណ្តឹង រហូតដល់ចំណាត់ការរបស់តុលាការចំពោះពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ប្រកបដោយសង្គតិភាព ។

ប្រធានបទសារណាស្តីពី "**ការជំនុំជម្រះសាជាថ្មី**" នេះ មានវិសាលភាពគ្របដណ្តប់តែត្រឹមកម្រិតនៃការជំនុំជម្រះសាជាថ្មីចំពោះសេចក្តីសម្រេចក្នុងនីតិវិធីអង្គសេចក្តី ដែលមានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៦ ប៉ុណ្ណោះ ។ ចំណែកឯ សេចក្តីសម្រេចក្នុងនីតិវិធីអនុវត្ត ដែលមានដូចជា៖ ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ និងដីកាសម្រេចរក្សាការពារ ជាអាទិ៍ មិនត្រូវបានលើកយកមកបកស្រាយក្នុងសារណានេះឡើយ ។

ប្រភពទិន្នន័យ ដែលត្រូវបានក្លាយជាមូលដ្ឋានក្នុងការសរសេរប្រធានបទសារណានេះ មានដូចជា៖ ច្បាប់ និងបទដ្ឋានគតិយុត្តនានា ដែលកំពុងតែត្រូវបានអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ន ក៏ដូចជាឯកសារជំនួយស្មារតីផ្នែកច្បាប់ ដែលត្រូវបានចងក្រងដោយអ្នកជំនាញការផ្នែកច្បាប់នានានៃប្រទេសកម្ពុជា និងប្រទេសជប៉ុន ដែលនេះគឺជាកត្តាយ៉ាងចម្បងក្នុងការធ្វើឱ្យប្រធានបទសារណានេះ ដើរទាន់សម័យកាល ។ ទិន្នន័យដែលមាននៅក្នុងសារណានេះ ត្រូវបានប្រមូលយកមក តាមរយៈការអានឯកសារដូចបានរៀបរាប់ខាងលើ និងតាមរយៈការសាកសួរអ្នកវិជ្ជាជីវៈ ដែលកំពុងតែអនុវត្តផ្ទាល់រួមមាន៖ ចៅក្រម មេធាវី ជាអាទិ៍ ចំពោះបញ្ហានានាដែលកើតមានឡើងក្នុងការអនុវត្តនីតិវិធីនៃការជំនុំជម្រះសាជាថ្មី ។

ដើម្បីទទួលបានមូលដ្ឋានមួយក្នុងការអនុវត្តដំណើរការនីតិវិធីនៃការជំនុំជម្រះសាជាថ្មីប្រកបដោយសង្គតិភាព ដូចបានលើកឡើងខាងលើ ប្រធានបទសារណាស្តីអំពី "**ការជំនុំជម្រះសាជាថ្មី**" ត្រូវបានបែងចែកចេញជា ០៣ (បី) ជំពូក ដែលមានខ្លឹមសារដូចខាងក្រោម ៖

**ជំពូកទី១ ៖** សញ្ញាណនៃការជំនុំជម្រះសាជាថ្មី

**ជំពូកទី២ ៖** បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

**ជំពូកទី៣ ៖** ចំណាត់ការលើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ។

# ជំពូកទី១

## សញ្ញាណនៃការជំនុំជម្រះសាជាថ្មី

# ជំពូកទី១ សញ្ញាណនៃការជំនុំជម្រះសាជាថ្មី

ដើម្បីឱ្យរបៀនស្ដីអំពីការជំនុំជម្រះសាជាថ្មីមានភាពស៊ីជម្រៅ ប្រកបដោយប្រត្យក្សសេចក្ដីចំណុចដែលត្រូវយកមកធ្វើការសិក្សាមុនដំបូងគេនោះគឺ សញ្ញាណនៃការជំនុំជម្រះសាជាថ្មី ដែលរួមមានៈ ប្រវត្តិ (ផ្នែកទី១) អត្ថន័យ និងគោលបំណង (ផ្នែកទី២) និងរចនាសម្ព័ន្ធ (ផ្នែកទី៣) ។

## ផ្នែកទី១ ប្រវត្តិនៃការជំនុំជម្រះសាជាថ្មី

នៅមុនសតវត្សរ៍ទី២១ ប្រទេសកម្ពុជាធ្លាប់បានធ្លាក់ចូលក្នុងរណ្ដៅសង្គ្រាមអស់រយៈពេលជាច្រើនឆ្នាំ ដែលបណ្ដាលឱ្យវិស័យនានាក្នុងប្រទេសកម្ពុជាត្រូវបានបំផ្លិចបំផ្លាញ និងចុះអន់ថយជាលំដាប់ ដែលក្នុងនោះក៏មានវិស័យយុត្តិធម៌ផងដែរ ។ ហេតុដូចនេះហើយ បានជាចាប់តាំងពីពេលដែលប្រទេសទទួលបានសុខសន្តិភាព ច្បាប់ និងបទដ្ឋានគតិយុត្តនានា ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ ដើម្បីធានាឡើងវិញនូវប្រសិទ្ធភាពនៃការអនុវត្តក្នុងវិស័យយុត្តិធម៌ ។

ក្នុងឆ្នាំ១៩៨៤ ក្រសួងយុត្តិធម៌ បានចេញសារាចរលេខ ០៤ ស.រ.ច.៨៤ ស្ដីពីសេចក្ដីណែនាំអំពីនីតិវិធីរដ្ឋប្បវេណីឆ្នាំ១៩៨៤ ។ សារាចរនេះ មានបញ្ញត្តអំពីការប្ដឹងជំទាស់ និងការជំនុំជម្រះសាឡើងវិញ ដែលមានន័យប្រហាក់ប្រហែលគ្នាទៅនឹងការជំនុំជម្រះសាជាថ្មី ដូចបានបញ្ញត្តក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ។ ក្នុងករណីនេះ បើរដ្ឋអាជ្ញាយល់ឃើញថា សាលក្រមរដ្ឋប្បវេណីរបស់តុលាការប្រជាជនខេត្តក្រុង ត្រូវបានសម្រេចដោយមានការភាន់ច្រឡំ រដ្ឋអាជ្ញា ត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីពិនិត្យ និងសម្រេច ។ ចៅក្រម ដែលធ្វើការជំនុំជម្រះសាឡើងវិញនោះត្រូវតែជាប្រធាន និងទីប្រឹក្សាប្រជាជន ដែលមានចំនួន ០៣នាក់ ហើយត្រូវតែជាចៅក្រមដែលមិនបានចូលរួមក្នុងការជំនុំជម្រះលើកមុន ។ សាលក្រមរបស់តុលាការប្រជាជនខេត្ត ក្រុង ដែលត្រូវបានជំនុំជម្រះសាឡើងវិញ ទោះបីត្រូវបានសម្រេចកំបាំងមុខក៏ដោយ ក៏មិនអាចឱ្យមានការប្ដឹងជំទាស់ ឬតវ៉ាទៀតឡើយ ។

ក្រោយមក នៅឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្ដើមធ្វើកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាលជប៉ុន ក្នុងការអភិវឌ្ឍលើវិស័យយុត្តិធម៌ តាមរយៈគម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ នៃក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ដើម្បីធ្វើការតាក់តែងសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីរហូតទទួលបានសមិទ្ធផលជាស្ថាពរក្នុងឆ្នាំ២០០៧ ។ ចាប់តាំងពីពេលនោះមក នីតិវិធីនៃការជំនុំជម្រះសាជាថ្មី ត្រូវបានអនុវត្ត ដោយផ្អែកតាមបទប្បញ្ញត្តិដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ។

## ផ្នែកទី២ អត្ថន័យ និងគោលបំណងនៃការជំនុំជម្រះសាជាថ្មី

ការជំនុំជម្រះសាជាថ្មី គឺជានីតិវិធីប្ដឹងឧបាស្រ័យ ឬ ប្ដឹងតវ៉ាពិសេស ដែលភាគីទាមទារឱ្យតុលាការលុបចោលនូវសាលក្រម ឬ សាលដីកា ដែលបានចូលជាស្ថាពរ ហើយធ្វើការជំនុំជម្រះនិងចេញសាលក្រម ឬ សាលដីកាថ្មីចំពោះរឿងក្ដីនោះ ដោយមូលហេតុមានវិការៈធ្ងន់ធ្ងរក្នុងនីតិវិធីបណ្ដឹង ឬ មូលដ្ឋាននៃសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរនោះមានភាពមិនប្រក្រតីជាអាទ៍ ។

ជាគោលការណ៍ ក្រោយពីសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរ ប្រសិនបើទទួលស្គាល់នូវការទាមទារឱ្យលុបចោល ឬ ផ្លាស់ប្ដូរនូវសាលក្រម ឬ សាលដីកា ដោយគ្រាន់តែមានមូលហេតុថា ការវិនិច្ឆ័យ ពុំមានភាពត្រឹមត្រូវ ឬ ការរកឃើញនូវភស្តុតាងថ្មីទៀត វិវាទនោះមិនអាចបញ្ចប់បានឡើយ ហើយមិនអាចសម្រេចនូវការសង្គ្រោះសិទ្ធិរបស់ភាគីរងគ្រោះ ដោយតុលាការបានឡើយ ។ ដូច្នេះ បន្ទាប់ពីឆ្លងកាត់ការវិនិច្ឆ័យហើយ ទំនាក់ទំនងសិទ្ធិដែលត្រូវបានចូលជាស្ថាពរ ដោយសាលក្រម ឬ សាលដីកា ជាគោលការណ៍ គឺមិនអាចត្រូវបានយកមកធ្វើការវិនិច្ឆ័យម្ដងទៀតបានឡើយ ដោយសារអានុភាពនៃអាជ្ញាអស់ជំនុំ ត្រូវបានកើតឡើងនៅពេលសាលក្រម ឬ សាលដីកាចូលជាស្ថាពរ[៦] ។ ប្រសិនបើភាគីត្រូវបានអនុញ្ញាតឱ្យធ្វើការតតាំងគ្នាចំពោះសិទ្ធិដែលត្រូវបានចូលជាស្ថាពររួចមកហើយ ឬ ក្នុងន័យម្យ៉ាងទៀត ប្រសិនបើមិនមានអត្ថិភាពនៃអានុភាពនៃអាជ្ញាអស់ជំនុំទេ នោះវិវាទមួយនោះនឹងគ្មានថ្ងៃ ដែលអាចត្រូវបានដោះស្រាយបានឡើយ ។

ផ្ទុយទៅវិញ ប្រសិនបើមិនអនុញ្ញាតឱ្យមានការលុបចោលសាលក្រមទាល់តែសោះ ទោះបីជាមានវិការៈធ្ងន់ធ្ងរទេនោះ វាហាក់បីដូចមានលក្ខណៈផ្ទុយនឹងទស្សនៈស្ដីពីការស្វែងរកយុត្តិធម៌តាមរយៈនីតិវិធីនៃបណ្ដឹងដែលប្រកបដោយភាពត្រឹមត្រូវមួយ ហើយនាំឱ្យមានការប៉ះពាល់ទៅដល់សិទ្ធិនិងផលប្រយោជន៍របស់ភាគីដែលពាក់ព័ន្ធ ។ ហេតុដូចនេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណីបានបញ្ញត្តអំពីករណីមួយចំនួន ដែលអនុញ្ញាតឱ្យភាគីដាក់ពាក្យបណ្ដឹងសុំលុបចោលសាលក្រម ឬ សាលដីកា ដែលបានចូលជាស្ថាពរ តែក្នុងករណីដែលសាលក្រម ឬ សាលដីកានោះមានវិការៈធ្ងន់ធ្ងរក្នុងនីតិវិធី ហើយតុលាការយល់ឃើញថាយុត្តិធម៌នឹងត្រូវបានបំពាន ក្នុងករណីដែលមិនអនុញ្ញាតឱ្យលុបចោលសាលក្រម ឬ សាលដីកាទេនោះ ។ នីតិវិធីនេះ អាចធ្វើឡើងតែក្នុងក្របខណ្ឌដ៏តឹងរ៉ឹងនៃបញ្ញត្តិច្បាប់ប៉ុណ្ណោះ ហើយនីតិវិធីនេះ ត្រូវបានហៅថា នីតិវិធីនៃការជំនុំជម្រះសាជាថ្មី ។

---

[៦] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៩៤។

## ផ្នែកទី៣ រចនាសម្ព័ន្ធនៃការជំនុំជម្រះសាជាថ្មី

ការជំនុំជម្រះសាជាថ្មី មានបញ្ញត្តក្នុងគន្ថីទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចាប់ពីមាត្រា ៣០៧ ដល់មាត្រា ៣១៨ ។ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការស្វែងរក និងយល់ដឹងពីលំហូរនៃនីតិវិធីដែលមានកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី រចនាសម្ព័ន្ធនៃការជំនុំជម្រះសាជាថ្មីអាចត្រូវបានកំណត់ដោយផ្អែកតាមទីតាំងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដូចខាងក្រោម ។

(រូបទី១) រចនាសម្ព័ន្ធផ្អែកតាមទីតាំងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី



# ជំពូកទី២

## បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

# ជំពូកទី២ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

បណ្តឹង គឺជាសកម្មភាពទាមទារមួយ ដែលដើមចោទធ្វើឡើងចំពោះចុងចម្លើយ នៅតុលាការ ដោយលើកឡើងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់នីតិឯកជនមួយ ហើយទាមទារឱ្យតុលាការចេញសាលក្រម ដែលមានខ្លឹមសារជាកំណត់មួយ ដោយផ្អែកលើការអះអាងទាំងនេះ ហើយជាគោលការណ៍ទូទៅ សកម្មភាពនៃបណ្តឹងនេះ ត្រូវធ្វើឡើងដោយវិធីដាក់ពាក្យបណ្តឹង[៣] ។ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ក៏មានលក្ខខណ្ឌគ្រឹះមិនខុសគ្នាពីបណ្តឹងធម្មតាដែរ គឺអាចត្រូវបានធ្វើឡើងតាមរយៈវិធីដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយត្រូវអនុលោមតាមលក្ខខណ្ឌដ៏តឹងរ៉ឹង ដែលមានបញ្ញត្តក្នុងច្បាប់ បើមិនដូចនេះទេ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចនឹងត្រូវក្លាយជាកម្មវត្ថុនៃការច្រានចោល ឬ លើកចោលដោយតុលាការ ។ ហេតុដូចនេះហើយ ដើម្បីជៀសវាងឱ្យបានជាអតិបរមានូវបាតុភូតអសកម្មទាំងនេះ ភាគីចាំបាច់ត្រូវគោរពតាមលក្ខខណ្ឌសារធាតុ (ផ្នែកទី១) ក៏ដូចជាលក្ខខណ្ឌទម្រង់ (ផ្នែកទី២) នៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដូចមានកំណត់ក្នុងជំពូកទី២នេះ ។

## ផ្នែកទី១ លក្ខខណ្ឌសារធាតុ

បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះរឿងក្តីដែលត្រូវបានបញ្ចប់ដោយសាលក្រម ឬ សាលដីកាចុងក្រោយដែលបានចូលជាស្ថាពររួចហើយនោះ តម្រូវឱ្យដើមចោទនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ធ្វើការអះអាងនូវមូលហេតុនៃការជំនុំជម្រះសាជាថ្មី (កថាខណ្ឌទី១) យ៉ាងជាក់លាក់ដូចមានបញ្ញត្តក្នុងច្បាប់ ដោយតម្រូវឱ្យបំពេញភាពបង្គ្រប់កិច្ច (កថាខណ្ឌទី២) មានភាគីដូចមានកំណត់ក្នុងច្បាប់ (កថាខណ្ឌទី៣) មានកម្មវត្ថុជាសាលក្រម ឬ សាលដីកា ឬ ដីកាសម្រេច ដែលបានចូលជាស្ថាពរហើយ (កថាខណ្ឌទី ៤) និងមានការគោរពតាមការកម្រិតអំឡុងពេល (កថាខណ្ឌទី៥) បានត្រឹមត្រូវ ។

### កថាខណ្ឌទី១ មូលហេតុនៃការជំនុំជម្រះសាជាថ្មី

មូលហេតុនៃការជំនុំជម្រះសាជាថ្មី ជាលក្ខខណ្ឌសារវន្តមួយ ដែលនាំឱ្យការជំនុំជម្រះសាជាថ្មី មានលក្ខណៈពិសេសជាងបណ្តឹងរដ្ឋប្បវេណីផ្សេងៗទៀត ដោយហេតុថា មូលហេតុទាំងនេះជា

[៣] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *នីតិវិធីបណ្តឹង* (ភាគ១ នៃសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ២០០៨), ៦។

កត្តាដែលជម្រុញឱ្យមានដំណើរការនៃនីតិវិធីនៃការជំនុំជម្រះសាជាថ្មីលើសាលក្រម ឬ សាលដីកាដែលមានអានុភាពអាជ្ញាអស់ជំនុំទៅហើយ ។

មូលហេតុនៃការជំនុំជម្រះសាជាថ្មី យោងតាមមាត្រា ៣០៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី មានចំនួន ១០ (ដប់) មូលហេតុផ្សេងគ្នា ដែលមានលំដាប់រៀងពី **ក** ដល់ **ញ** ។ មូលហេតុទាំងនេះ អាចត្រូវបានបែងចែកចេញជា ០៤ (បួន) ករណីធំៗ ដែលរួមមាន៖ ករណីដែលមានការបំពាននីតិវិធីធ្ងន់ធ្ងរ (១.១) ករណីដែលមានភាពមិនប្រក្រតីនៃមូលដ្ឋាននៃសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ (១.២) ករណីដែលមានការភ្លេចបញ្ចូលការវិនិច្ឆ័យនៅក្នុងសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ (១.៣) និងករណីខ្លឹមសារនៃសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរផ្ទុយគ្នានឹងខ្លឹមសារនៃសាលក្រម ឬ សាលដីកាមុនដែលបានចូលជាស្ថាពរ (១.៤) ។ បន្ថែមពីលើមូលហេតុទាំងនេះ ក៏នៅមានករណីពិសេស (១.៥) មួយផ្សេងទៀត ដូចមានកំណត់ក្នុងមាត្រា ៣១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ផងដែរ។

### ១.១ ករណីដែលមានការបំពាននីតិវិធីធ្ងន់ធ្ងរ[៤]

សាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរអាចមានអានុភាពចងភាគីបាន លុះត្រាតែនីតិវិធីនៃការជំនុំជម្រះត្រូវបានធានាត្រឹមត្រូវ ។ ប្រសិនបើមានការបំពានលើនីតិវិធីធ្ងន់ធ្ងរ នោះនីតិវិធីនៃការជំនុំជម្រះ ក៏មិនអាចត្រូវបានធានា ហើយសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរនោះ ក៏មិនអាចមានអានុភាពចងភាគីបានដែរ ។ អាស្រ័យហេតុនេះ ការធ្វើផ្ទុយនឹងនីតិវិធី គឺជាមូលហេតុធ្ងន់ធ្ងរមួយដែលអាចឱ្យភាគីធ្វើការទាមទារឱ្យជំនុំជម្រះសាជាថ្មី ទោះបីជាការធ្វើផ្ទុយ ឬការបំពាននីតិវិធីនេះមាន ឬ គ្មានឥទ្ធិពលលើខ្លឹមសារនៃសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរនោះ ក៏ដោយ ។ ករណីដែលមានការបំពាននីតិវិធីធ្ងន់ធ្ងរនេះ មានកំណត់ក្នុងចំណុច **ក** ចំណុច **ខ** និង ចំណុច **គ** នៃ មាត្រា ៣០៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**ក- បើពុំបានចាត់តាំងតុលាការដែលបានចេញសាលក្រម ឬ សាលដីកា ទៅតាមច្បាប់កំណត់ ។**

ឧទាហរណ៍៖

- ការធ្វើសាលក្រម ឬ សាលដីកា ដោយបុគ្គលដែលមិនមានលក្ខណៈសម្បត្តិជាចៅក្រម ដូចជាដោយក្រឡាបញ្ជី ឬ ជំនួយការជាអាទិ៍ ។

[៤] Kazuyuki, Higashio., Ryo, Yukawa. និង Jun, Uchiyama, "ការជំនុំជម្រះសាជាថ្មី" (បទបង្ហាញនៅក្នុងសិក្ខាសាលាស្តីពីបញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី, សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ, ១៧ មករា ២០១៨), ៨១។

– រឿងក្តីដែលត្រូវវិនិច្ឆ័យ និងសម្រេចក្តីដោយក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម [៥] ចំនួនបីរូប តែបែរជាមានតែចៅក្រមពីររូប ឬ ចៅក្រមទោលប៉ុណ្ណោះ ដែលបាន វិនិច្ឆ័យ និងសម្រេចក្តីលើរឿងក្តីនោះ ។

– ការចេញសាលក្រម ឬ សាលដីកា ដោយចៅក្រមផ្សេងពីចៅក្រមដែលបាន បញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ [៦] ។

**ខ- បើចៅក្រមដែលពុំអាចចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកាតាមច្បាប់ បានចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកានោះ ។**

ឧទាហរណ៍៖

– ចៅក្រមដែលមានមូលហេតុដកហូត [៧] តាមមាត្រា ២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចូលរួមក្នុងការវិនិច្ឆ័យ ជម្រះក្តី និងចេញសាលក្រម ឬ សាលដីកា ។

– ចៅក្រមដែលបានចេញសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី បានចូលរួមក្នុងការជំនុំជម្រះ និងសម្រេចសេចក្តីអំពីបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះ [៨] ។

**គ- បើខ្វះសិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ខ្វះការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្តឹង ឬ ខ្វះសិទ្ធិតំណាងដោយអាណត្តិ ។**

---

[៥] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៣ កថាខណ្ឌទី៣ ។

[៦] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៨៥។

[៧] មូលហេតុដកហូតតាមមាត្រា ២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី រួមមាន៖

ក-កាលណាចៅក្រម ឬ សហព័ទ្ធរបស់ចៅក្រម ឬ អតីតសហព័ទ្ធរបស់ ចៅក្រមជាភាគីណាមួយក្នុងរឿងក្តី ។

ខ-កាលណាចៅក្រមជាញាតិលោហិតក្នុងថ្នាក់ទី ៦ (ប្រាំមួយ) ឬ ញាតិ ពន្ធក្នុងថ្នាក់ទី ៣ (បី) របស់ភាគីណាមួយ ។

គ-កាលណាចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ ។

ឃ-កាលណាចៅក្រមដែលទទួលបន្ទុករឿងក្តី ធ្លាប់ ឬ កំពុងមានវិវាទ នៅតុលាការជាមួយភាគីណាមួយ ។

ង-កាលណាចៅក្រមបានធ្វើជាសាក្សី ឬ ធ្វើជាអ្នកជំនាញក្នុងរឿងក្តី ។

ច-កាលណាចៅក្រមជាអ្នកតំណាង ឬ ធ្លាប់ជាអ្នកតំណាង ឬ ជាអ្នក ជំនួយឱ្យភាគីចំពោះរឿងក្តី ។

ឆ-កាលណាចៅក្រមបានចូលរួមក្នុងការសម្រេចសេចក្តីមជ្ឈត្តករចំពោះរឿងក្តី ឬ បានចូលរួមក្នុងការសម្រេចសេចក្តីនៅក្នុងនីតិវិធីនៃការជំនុំជម្រះលើកទី១ ដែលបានឧបាស្រ័យ ឬ ការជំនុំជម្រះនៃបណ្តឹងឧទ្ធរណ៍ ដែលបានឧបាស្រ័យ ឬ បង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ចំពោះរឿងក្តី ។

[៨] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣០៩ កថាខណ្ឌទី៣ ។

ឧទាហរណ៍៖

- អ្នកដែលគ្មានអំណាចមេបា បានធ្វើសកម្មភាពបណ្ដឹងឱ្យអនីតិជន ក្នុងនាមជាអ្នកមានអំណាចមេបា[៩] ។
- រូបវន្តបុគ្គល បានធ្វើសកម្មភាពបណ្ដឹង ក្នុងនាមជាអ្នកតំណាងរបស់នីតិបុគ្គល[១០] ដោយមិនមានការប្រគល់សិទ្ធិតំណាង ។
- មេធាវី បានធ្វើសកម្មភាពបណ្ដឹងឱ្យកូនក្ដី ក្នុងនាមជាអ្នកតំណាងដោយអាណត្តិ ដោយមិនមានការប្រគល់សិទ្ធិតំណាង[១១] ។

### ១.២ ករណីមានភាពមិនប្រក្រតីនៃមូលដ្ឋាននៃសាលក្រម ឬ សាលដីកា[១២]

ករណីដែលមានភាពមិនប្រក្រតីនៃមូលដ្ឋាននៃសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរមាន ០៥ (ប្រាំ) មូលហេតុ ដូចមានកំណត់ក្នុងចំណុច **ឃ** ចំណុច **ង** ចំណុច **ច** ចំណុច **ឆ** និងចំណុច **ជ** នៃមាត្រា ៣០៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**ឃ- បើចៅក្រមដែលបានចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកា បានប្រព្រឹត្តអំពើល្មើសដែលពាក់ព័ន្ធនឹងមុខងាររបស់ខ្លួនចំពោះរឿងក្ដី ។**

ករណីនេះ ពាក់ព័ន្ធនឹងអំពើល្មើសរបស់ចៅក្រម ដែលទាមទារឱ្យមានការចូលជាស្ថាពរនៃសាលក្រម ឬ សាលដីកាដែលផ្ដន្ទាទោស ឬ សេចក្ដីសម្រេចដាក់ប្រាក់ពិន័យ ចំពោះអំពើល្មើសនោះ ដោយមិនចាំបាច់ពិចារណាថា អំពើដែលត្រូវដាក់ទណ្ឌកម្មនោះ មាន ឬ គ្មានឥទ្ធិពលទៅលើលទ្ធផលនៃសាលក្រម ឬ សាលដីកានោះទេ ឱ្យតែមានវត្តមាននៃអំពើល្មើសគឺគ្រប់គ្រាន់ ។

ឧទាហរណ៍៖

- <u>បទស៊ីសំណូកប្រព្រឹត្តដោយចៅក្រម[១៣]</u> ៖ ចៅក្រមទទួលសំណូកពីភាគីណាមួយ ហើយសម្រេចឱ្យភាគីនោះឈ្នះក្ដី ក្នុងសាលក្រម ឬ សាលដីកា ។

---

[៩] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣២ កថាខណ្ឌទី៣ និងទី៤ ។

[១០] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៨។

[១១] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៧ កថាខណ្ឌទី៣។

[១២] Kazuyuki, Higashio., Ryo, Yukawa. និង Jun, Uchiyama, "ការជំនុំជម្រះសាជាថ្មី" (បទបង្ហាញនៅក្នុងសិក្ខាសាលាស្ដីពីបញ្ហានានាដែលមាននៅក្នុងរឿងក្ដីរដ្ឋប្បវេណី, សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ, ១៧ មករា ២០១៨), ៩៥។

[១៣] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៥១៧។

**ង- បើភាគីបានសារភាព ឬ ត្រូវបានរារាំងក្នុងការដាក់មធ្យោបាយតទល់ ឬមធ្យោបាយការពារខ្លួនដែលមានឥទ្ធិពលដល់សាលក្រម ឬ សាលដីកា ដោយសារបទល្មើសអ្នកដទៃ ។**

ករណីនេះ ទាមទារឱ្យមានការចូលជាស្ថាពរនៃសាលក្រម ឬ សាលដីកាដែលផ្តន្ទាទោស ឬ សេចក្តីសម្រេចដាក់ប្រាក់ពិន័យចំពោះអំពើល្មើសនោះ និងទាមទារដាច់ខាតឱ្យអំពើល្មើសនោះ មានឥទ្ធិពលទៅលើលទ្ធផលនៃសាលក្រម ឬ សាលដីកាដែលចូលជាស្ថាពរ ។

ឧទាហរណ៍៖

- <u>បទគំរាមកំហែង[១៤]</u> ៖ ភាគីម្ខាង ត្រូវបានភាគីម្ខាងទៀតគំរាមថានឹងប្រព្រឹត្តអំពើហិង្សា ប្រសិនបើភាគីនោះ មិនសារភាពអំពីអង្គហេតុ ដែលជាមូលដ្ឋាននៃការចេញសាលក្រម ឬ សាលដីកា ។
- <u>បទហិង្សា[១៥]</u> ៖ ភាគីណាម្ខាង ខកខានមិនបានអះអាងអំពីអង្គហេតុ ឬ មិនបានដាក់ភស្តុតាងសំខាន់ ដែលជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកា ដោយសារខ្លួនជាជនរងគ្រោះនៃអំពើហិង្សា ។

**ច- បើឯកសារ ឬ វត្ថុឯទៀតដែលបានក្លាយជាភស្តុតាងសម្រាប់សាលក្រម ឬ សាលដីកា ត្រូវបានក្លែង ឬ កែប្រែដោយបន្លំ ។**

ករណីនេះ ទាមទារឱ្យមានការចូលជាស្ថាពរនៃសាលក្រម ឬ សាលដីកាដែលផ្តន្ទាទោស ឬ សេចក្តីសម្រេចដាក់ប្រាក់ពិន័យចំពោះអំពើល្មើសនោះ និងទាមទារដាច់ខាតឱ្យអំពើល្មើសនោះ មានឥទ្ធិពលទៅលើលទ្ធផលនៃសាលក្រម ឬ សាលដីកាដែលចូលជាស្ថាពរ ។

ឧទាហរណ៍៖

- <u>បទប្រើប្រាស់លិខិតក្លែង[១៦]</u> ៖ ភាគីបានយកកិច្ចសន្យាឯកជនក្លែងក្លាយមកដាក់ជាភស្តុតាងជូនតុលាការ ហើយតុលាការបានសម្រេចក្តី ដោយយកភស្តុតាងនោះជាមូលដ្ឋានក្នុងការទទួលស្គាល់អង្គហេតុ ។

**ឆ- បើសេចក្តីថ្លែងការណ៍មិនពិតរបស់សាក្សី អ្នកធ្វើកោសលវិច័យ អ្នកបកប្រែ ភាគីដែលបានធ្វើសម្បថ ឬ របស់អ្នកតំណាងដែលច្បាប់បានកំណត់ដែលបានធ្វើសម្បថ បានក្លាយជាភស្តុតាងសម្រាប់សាលក្រម ឬ សាលដីកា ។**

---

[១៤] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២៣១។

[១៥] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២១៧។

[១៦] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៦២៨។

ករណីនេះ ក៏ទាមទារឱ្យមានការចូលជាស្ថាពរនៃសាលក្រម ឬ សាលដីកាដែលផ្តន្ទាទោស ឬ សេចក្តីសម្រេចដាក់ប្រាក់ពិន័យចំពោះអំពើល្មើសនោះ និងទាមទារដាច់ខាតឱ្យអំពើល្មើសនោះ មានឥទ្ធិពលទៅលើលទ្ធផលនៃសាលក្រម ឬ សាលដីកាដែលចូលជាស្ថាពរ ។

ឧទាហរណ៍៖

- <u>បទផ្តល់សក្ខីកម្មក្លែងក្លាយ</u>[១៧] ៖ សាក្សីបានផ្តល់សក្ខីកម្មភូតកុហក នៅចំពោះមុខតុលាការ ហើយតុលាការបានសម្រេចសេចក្តី ដោយផ្អែកលើសក្ខីកម្មនោះ ។
- <u>បទក្លែងដោយអ្នកជំនាញ</u>[១៨]៖ អ្នកធ្វើកោសលវិច័យ បានក្លែងដោយចេតនា នូវទិន្នន័យ ឬ លទ្ធផលនៃកោសលវិច័យ នៅក្នុងសេចក្តីថ្លែងការណ៍ ដោយផ្ទាល់មាត់ ឬ របាយការណ៍ជាលាយលក្ខណ៍អក្សរ ដែលក្លាយជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកា ។
- <u>បទស៊ីសំណូករបស់អ្នកបកប្រែ</u>[១៩] ៖ ដើមចោទ ជាជនបរទេស បានប្តឹងចុងចម្លើយជាជនជាតិខ្មែរ ហើយដើម្បីឱ្យដើមចោទជាជនបរទេសនោះចាញ់ក្តី ចុងចម្លើយបានសូកប៉ាន់អ្នកបកប្រែឱ្យក្លែងខ្លឹមសារនៃភាសាក្នុងសេចក្តីថ្លែងការណ៍ ដែលជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកា ។
- <u>អំពើក្លែងបន្លំសេចក្តីថ្លែងការណ៍</u>[២០] ៖ ភាគីដែលបានស្បថ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ដែលបានស្បថ បានក្លែងបន្លំសេចក្តីថ្លែងការណ៍របស់ខ្លួន ដែលក្លាយជាមូលដ្ឋាននៃការចេញសាលក្រម ឬ សាលដីកា ។

**ជ- បើសាលក្រម ឬ សាលដីកា ឬសេចក្តីសម្រេចឯទៀត ផ្នែករដ្ឋប្បវេណី ឬ ផ្នែកព្រហ្មទណ្ឌ ឬការចាត់ចែងរដ្ឋបាល ដែលជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកា ត្រូវបានផ្លាស់ប្តូរ ដោយសារសេចក្តីសម្រេច ឬ ការចាត់ចែងផ្នែករដ្ឋបាលនៅពេលក្រោយ ។**

ករណីនេះ ទាមទារដាច់ខាតឱ្យការផ្លាស់ប្តូរនៃសេចក្តីសម្រេច ឬ ការចាត់ចែងរដ្ឋបាលនោះ មានឥទ្ធិពលទៅលើលទ្ធផលនៃសាលក្រម ឬ សាលដីកាដែលចូលជាស្ថាពរ ។

---

[១៧] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៥៤៥។

[១៨] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៥៥១។

[១៩] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៥៥៣។

[២០] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៩០ កថាខណ្ឌទី៣ និងមាត្រា១៩២។

ឧទាហរណ៍៖

– ដើមចោទ បានដាក់ពាក្យបណ្ដឹងទាមទារសំណងការខូចខាតពីអំពើអនីត្យានុកូល[២១] ដោយយកសាលក្រមព្រហ្មទណ្ឌដែលផ្ដន្ទាទោសលើចុងចម្លើយមកធ្វើជាមូលដ្ឋានក្នុងការទាមទារក្នុងរឿងក្ដីរដ្ឋប្បវេណី ហើយតុលាការបានទទួលស្គាល់ការទាមទារនោះ ។ តែក្រោយមក ចុងចម្លើយបានប្ដឹងសើរើ[២២] លើរឿងក្ដីព្រហ្មទណ្ឌ នោះហើយតុលាការក៏បានចេញសាលដីកាថ្មី លុបចោលសាលក្រមព្រហ្មទណ្ឌដែលផ្ដន្ទាទោស និងសម្រេចថាចុងចម្លើយគ្មានពិរុទ្ធភាព ។ ដូចនេះ ចុងចម្លើយនៃសាលក្រមរដ្ឋប្បវេណីដែលទទួលស្គាល់ការទាមទារសំណងការខូចខាត អាចប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីលើសាលក្រមដែលបានចូលជាស្ថាពរនេះបាន ។

### ១.៣ ករណីដែលមានការភ្លេចបញ្ចូលការវិនិច្ឆ័យ[២៣]

ចំណុចសំខាន់ ដែលមានកំណត់ក្នុងចំណុច **ឈ** នៃមាត្រា ៣០៧ កថាខណ្ឌទី១ សំដៅដល់មធ្យោបាយតទល់ និងមធ្យោបាយការពារខ្លួន ដែលភាគីបានអះអាង នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដែលមានឥទ្ធិពលទៅលើលទ្ធផលនៃសាលក្រម ឬ សាលដីកា ។ ចំណុចសំខាន់ទាំងនេះ ទាមទារឱ្យតុលាការធ្វើការវិនិច្ឆ័យ និងបង្ហាញពីការវិនិច្ឆ័យរបស់ខ្លួន ក្នុងសំអាងហេតុនៃសាលក្រម ឬ សាលដីកា ។ ដូចនេះ ក្នុងករណីដែលតុលាការមិនបានធ្វើការវិនិច្ឆ័យលើមធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួនរបស់ភាគីណាមួយ ដែលនាំឱ្យមានការប្រែប្រួលនូវខ្លឹមសារនៃសាលក្រម ឬ សាលដីកា ភាគីដែលខាតបង់ផលប្រយោជន៍ ដោយសារលទ្ធផលនៃសាលក្រម ឬ សាលដីកានេះ អាចធ្វើការទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន ដោយផ្អែកលើមូលហេតុដូចមានកំណត់ក្នុងចំណុច **ឈ** នេះ ។

**ឈ- បើមានការភ្លេចបញ្ចូលសេចក្ដីវិនិច្ឆ័យលើចំណុចសំខាន់ៗ ដែលអាចមានឥទ្ធិពលទៅលើសាលក្រម ឬ សាលដីកា ។**

ឧទាហរណ៍៖

– សញ្ញាណនៃរឿងក្ដីពាក់ព័ន្ធនឹងការទាមទារឱ្យប្រគល់ប្រាក់ ដោយផ្អែកលើកិច្ច-

---

[២១] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៧៤៣។

[២២] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា៤៤៣។

[២៣] Kazuyuki, Higashio., Ryo, Yukawa. និង Jun, Uchiyama, "ការជំនុំជម្រះសាជាថ្មី" (បទបង្ហាញនៅក្នុងសិក្ខាសាលាស្ដីពីបញ្ហានានាដែលមាននៅក្នុងរឿងក្ដីរដ្ឋប្បវេណី, សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ, ១៧ មករា ២០១៨), ៥២។

សន្យាលក់ទិញ[២៤] តែចុងចម្លើយបានអះអាង តាមរយៈការធ្វើសេចក្តីថ្លែងការណ៍ និងការដាក់ភស្តុតាងថាខ្លួនបានសងបំណុលរួចហើយ ប៉ុន្តែតុលាការមិនបានវិនិច្ឆ័យលើការអះអាងរបស់ចុងចម្លើយទេ និងមិនបានបង្ហាញនូវសេចក្តីវិនិច្ឆ័យរបស់ខ្លួនក្នុងសំអាងហេតុ ដោយវិនិច្ឆ័យតែទៅលើការអះអាងរបស់ដើមចោទ និងសម្រេចឱ្យដើមចោទឈ្នះ ។

### ១.៤ ករណីដែលសាលក្រម ឬ សាលដីកាមានខ្លឹមសារផ្ទុយគ្នា[២៥]

ករណីដែលសាលក្រម ឬ សាលដីកាមានខ្លឹមសារខុសគ្នានេះ គឺជាករណីដែលអាជ្ញាអស់ជំនុំនៃសាលក្រម ឬ សាលដីកាដើម មានភាពផ្ទុយគ្នាទៅនឹងអាជ្ញាអស់ជំនុំនៃសាលក្រម ឬ សាលដីកាក្រោយ ។ ស្ថានភាពនេះ អាចបង្កនូវហានិភ័យយ៉ាងធ្ងន់ធ្ងរចំពោះភាគី ហេតុដូចនេះហើយ ទើបករណីនេះ ត្រូវបានរាប់បញ្ចូលថាជាមូលហេតុមួយនៃការជំនុំជម្រះសាជាថ្មី ដែលមានបញ្ញត្តក្នុងចំណុច ៣ នៃ មាត្រា ៣០៧ កថាខណ្ឌទី១ ដើម្បីរំលាយនូវស្ថានភាពគ្មានសង្គតិភាពនេះ ។

**៣- បើសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មានការប៉ះពាល់ដល់សាលក្រម ឬ សាលដីកាមុនដែលបានចូលជាស្ថាពរហើយ ។**

ឧទាហរណ៍៖

- សញ្ញាណនៃរឿងក្តីពាក់ព័ន្ធនឹងការទាមទារឱ្យប្រគល់ប្រាក់ ដោយផ្អែកលើកិច្ចសន្យាលក់ទិញ តែចុងចម្លើយបានអះអាង តាមរយៈការធ្វើសេចក្តីថ្លែងការណ៍ និងការដាក់ភស្តុតាងថាខ្លួនបានសងបំណុលរួចហើយ តុលាការសម្រេចច្រានចោលការទាមទារ ដោយបានវិនិច្ឆ័យ និងបង្ហាញនូវសេចក្តីវិនិច្ឆ័យរបស់ខ្លួនក្នុងសំអាងហេតុបានត្រឹមត្រូវ ។ តែក្រោយមក ចុងចម្លើយបានស្លាប់ ហើយដើមចោទបានដាក់ពាក្យបណ្តឹងដដែលម្តងទៀត ដែលទាមទារឱ្យសន្តតិជន[២៦] ជាកូនរបស់ចុងចម្លើយប្រគល់ប្រាក់ ដោយផ្អែកលើកិច្ចសន្យាលក់ទិញដដែល ដោយសន្តតិជននោះមិនបានដឹងពីអត្ថិភាពនៃសាលក្រមមុន និងមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីដាក់ជូនតុលាការ តុលាការក៏សម្រេចទទួលស្គាល់ការទាមទារ

---

[២៤] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៥១៥។

[២៥] Kazuyuki, Higashio., Ryo, Yukawa. និង Jun, Uchiyama, "ការជំនុំជម្រះសាជាថ្មី" (បទបង្ហាញនៅក្នុងសិក្ខាសាលាស្តីពីបញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី, សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ, ១៧ មករា ២០១៨), ៥៦។

[២៦] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៥៩។

របស់ដើមចោទ ដែលបណ្តាលឱ្យមានស្ថានភាពផ្ទុយគ្នានៃសេចក្តីសម្រេចពីរលើអង្គហេតុតែមួយ ដែលបំពានអានុភាពអាជ្ញាអស់ជំនុំនៃសេចក្តីសម្រេចមុន ។

### ១.៥ ករណីពិសេស

អនុលោមតាមមាត្រា ៣១៨ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយតតិយជន គឺជាករណីពិសេសមួយនៃការទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលមិនចំណុះឱ្យមូលហេតុទាំង ១០ (ដប់) ដូចមានកំណត់ក្នុងមាត្រា ៣០៧ នោះទេ ពោលគឺឱ្យតែលក្ខខណ្ឌដែលមានបញ្ញត្តក្នុងមាត្រា ៣១៨ ត្រូវបានបំពេញ តតិយជនអាចធ្វើការទាមទារឱ្យជំនុំជម្រះសាជាថ្មីលើសាលក្រម ឬ សាលដីកាដែលចូលជាស្ថាពរនោះ បានហើយ ។ តាមរយៈមាត្រា ៣១៨ លក្ខខណ្ឌដែលត្រូវបំពេញមាន ២ (ពីរ) គឺ៖

១-ដើមចោទ និងចុងចម្លើយ បានរួមគំនិតគ្នាដោយទុច្ចរិតក្នុងដំណើរការនៃបណ្តឹង

២-ការរួមគំនិតគ្នានេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងធ្វើឱ្យបាត់បង់សិទ្ធិ ឬ ផលប្រយោជន៍របស់តតិយជន តាមរយៈអានុភាពនៃសាលក្រម ឬ សាលដីកាដែលចូលជាស្ថាពរ ។

ឧទាហរណ៍ [២៧]៖

– ចុងចម្លើយនៃសាលក្រមដើម ដែលមានបំណុលច្រើន បានរួមគំនិតជាមួយដើមចោទដែលជាសាច់ញាតិរបស់ខ្លួន ឱ្យដាក់ពាក្យបណ្តឹងចំពោះចុងចម្លើយ ដែលទាមទារឱ្យបញ្ជាក់អំពីកម្មសិទ្ធិលើអចនវត្ថុ ដែលជាកម្មសិទ្ធិរបស់ចុងចម្លើយ ក្នុងគោលបំណងគេចផុតពីការអនុវត្តដោយបង្ខំពីម្ចាស់បំណុល ហើយចុងចម្លើយបានចាញ់ក្តីដោយចេតនា និងទទួលបានសាលក្រមដែលបានចូលជាស្ថាពរ ។ ករណីនេះ ម្ចាស់បំណុលរបស់ចុងចម្លើយ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសកម្មភាពដែលនាំឱ្យខូចប្រយោជន៍ក្នុងសាលក្រមដែលបានចូលជាស្ថាពរហើយ ដោយយកដើមចោទ និងចុងចម្លើយនៃសាលក្រមដើមនេះធ្វើជាសហចុងចម្លើយនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ។

## កថាខណ្ឌទី២ ភាពបន្ទាប់បន្សំនៃការជំនុំជម្រះសាជាថ្មី

ទោះបីជាបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មានអត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មីក៏ដោយ ក៏ការទាមទារឱ្យធ្វើការជំនុំជម្រះសាជាថ្មី ពុំអាចធ្វើបានឡើយ ប្រសិនបើមានករណី

---

[២៧] មេធាវី អ៊ីវ ប៉ូលី, *មេរៀនសង្ខេបស្តីពីនីតិវិធីរដ្ឋប្បវេណី* (២០១០), ១៤១។

ណាមួយកើតឡើង ដូចខាងក្រោម [២៨] ៖

- ករណីដែលភាគីបានធ្វើការអះអាងអំពីមូលហេតុនោះ នៅពេលធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ (២.១) ឬ
- ករណីដែលភាគីបានដឹងអំពីមូលហេតុនេះហើយ តែមិនបានធ្វើការអះអាង (២.២) ។

លក្ខខណ្ឌខាងលើនេះ ហៅថាភាពបង្គ្រប់កិច្ច ឬ ភាពបំពេញបន្ថែមនៃការជំនុំជម្រះសាជាថ្មី ដែលធានានូវប្រសិទ្ធភាពនៃគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់ ។ ដូចនេះ ជាបឋម ភាគីត្រូវអះអាងអំពីអង្គហេតុដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មី តាមរយៈពាក្យបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដែលមានន័យថា មានតែករណីដែលមិនអាចធ្វើការអះអាងបាននៅក្នុងបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដោយសារខ្លួនមិនបានដឹងពីហេតុនោះ ឬ ដោយសារហេតុនោះកើតឡើងនៅពេលក្រោយប៉ុណ្ណោះ ទើបភាគីអាចយកមកធ្វើការអះអាងនៅក្នុងបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី [២៩] ។

### ២.១ ការបានធ្វើការអះអាង

"ករណីដែលភាគីបានធ្វើការអះអាងអំពីមូលហេតុនោះ នៅពេលធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់" ដែលមានបញ្ញត្តក្នុងមាត្រា ៣០៧ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី សំដៅដល់ករណីដែលភាគីបានដឹងអំពីមូលហេតុណាមួយ ដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មី និងបានលើកយកមូលហេតុនោះមកធ្វើការអះអាង នៅពេលធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ។ ដូចនេះ ភាគីមិនអាចយកមូលហេតុដដែលនោះ មកធ្វើជាមូលដ្ឋានក្នុងការទាមទារឱ្យជំនុំជម្រះសាជាថ្មី លើសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ បាននោះទេ ដោយមូលហេតុថា ភាគីបានលើកយកបញ្ហានោះមកឱ្យតុលាការជាន់ខ្ពស់ធ្វើការវិនិច្ឆ័យលើហេតុនោះរួចរាល់ហើយ ដូច្នេះ ការលើកយកបញ្ហាដដែលមកឱ្យតុលាការធ្វើការជំនុំជម្រះម្តងទៀត គឺជាការមិនសមរម្យឡើយ ។

### ២.២ ការមិនបានធ្វើការអះអាង

ករណីដែលភាគីបានដឹងអំពីមូលហេតុណាមួយ ដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មី តែមិនបានធ្វើការអះអាង អាចស្ថិតនៅក្រោមរូបភាព ០២ (ពីរ) ដូចជា៖ ការមិនបានធ្វើការអះ

---

[២៨] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣០៧ កថាខណ្ឌទី១ វាក្យខណ្ឌទី២។

[២៩] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (២០០៧), ២៨៥។

អាងក្នុងដំណើរការនីតិវិធី (២.២.១) និងការមិនបានធ្វើការអះអាងក្នុងបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ (២.២.១) ។

### ២.២.១ ការមិនបានធ្វើការអះអាងក្នុងដំណើរការនីតិវិធី

នៅក្នុងដំណើរការនីតិវិធីណាមួយរបស់តុលាការ ដូចជានៅនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ជាអាទិ៍ ភាគីបានដឹងអំពីហេតុណាមួយ ដែលអាចនឹងក្លាយជាមូលហេតុនៃការទាមទារឱ្យជំនុំជម្រះសាជាថ្មី ប៉ុន្តែ ខ្លួនពុំបានធ្វើការអះអាងភ្លាមៗអំពីហេតុនោះឡើយ ដោយរង់ចាំរហូតដល់ពេលសាលក្រម ឬ សាលដីកាចូលជាស្ថាពរ ដើម្បីយកហេតុនោះមកធ្វើជាមូលហេតុក្នុងការទាមទារឱ្យជំនុំជម្រះសាជាថ្មី ។ មូលហេតុដែលភាគីមិនបានធ្វើការអះអាងភ្លាមៗនេះ គឺក្នុងគោលបំណងប្រើប្រាស់ហេតុនោះ នៅពេលដែលខ្លួនបាត់បង់ផលប្រយោជន៍ តាមរយៈសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ ។ ករណីបែបនេះ ច្បាប់មិនអនុញ្ញាតឱ្យភាគីធ្វើការទាមទារឱ្យជំនុំជម្រះសាជាថ្មីឡើយ ព្រោះភាគីមិនបានគោរពតាមភាពបំពេញបន្ថែមនៃការទាមទារឱ្យជំនុំជម្រះសាជាថ្មី ដូចមានកំណត់ក្នុងមាត្រា ៣០៧ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នោះទេ ។

### ២.២.២ ការមិនបានធ្វើការអះអាងក្នុងបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

ករណីដែលភាគីណាមួយមានហេតុដែលត្រូវលើកឡើងនៅក្នុងបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ប៉ុន្តែ ខ្លួនពុំបានធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ទេ ក៏ជាការបំពានលើភាពបំពេញបន្ថែមនៃការទាមទារឱ្យជំនុំជម្រះសាជាថ្មីដែរ ។ ដូចនេះ ចំពោះហេតុដែលកើតឡើងហើយដែលភាគីអាចយកទៅអះអាងក្នុងបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ តែខ្លួនមិនព្រមអះអាងដោយទុកសេចក្តីសម្រេចនោះឱ្យចូលជាស្ថាពរ នោះភាគីមិនអាចយកហេតុនេះមកធ្វើការលើកឡើងថាជាមូលហេតុនៃការទាមទារឱ្យជំនុំជម្រះសាជាថ្មីបានឡើយ ។

## កថាខណ្ឌទី៣ ភាគីនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

គ្រប់បុគ្គលដែលតាំងខ្លួនជាភាគីនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវតែជាបុគ្គលដែលមានសមត្ថភាពភាគី និងសមត្ថភាពក្នុងការធ្វើបណ្តឹង ដូចមានកំណត់ក្នុងបទប្បញ្ញត្តិទូទៅស្តីពី "ភាគី" ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ។

ភាគីនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ជាគោលការណ៍ (៣.១) គឺជាភាគីនៃសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃការទាមទារឱ្យជំនុំជម្រះសាជាថ្មី ប៉ុន្តែក៏នៅមានករណីអញ្ញត្រកម្ម (៣.២) ដែលភាគីនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជាតតិយជន ដែលមិនមែនជាភាគីនៃសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃការទាមទារឱ្យជំនុំជម្រះសាជាថ្មីផងដែរ ។ ត្រង់ចំណុច

នេះ ភាគី សំដៅទៅដល់ដើមចោទ និងចុងចម្លើយនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ហើយចំពោះករណីដែលភាគីនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ជាជនណាផ្សេងពីភាគីនៃសាលក្រម ឬ សាលដីកាដើមនោះ ចាំបាច់ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីទំនាក់ទំនងរវាងជននោះជាមួយនឹងភាគីនៃសាលក្រម ឬ សាលដីកាដើមនោះ ។

### ៣.១ គោលការណ៍

ជាគោលការណ៍ ភាគីដែលចាញ់ក្តីក្នុងសាលក្រម ឬ សាលដីកាដើមដែលបានចូលជាស្ថាពរ គឺជាដើមចោទនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី [៣០] ឯចុងចម្លើយនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីវិញ គឺភាគីដែលឈ្នះក្តីក្នុងសាលក្រម ឬ សាលដីកាចុងក្រោយដែលបានចូលជាស្ថាពរនោះ ។ ក្នុងករណីសាលក្រម ឬ សាលដីកាដើមច្រានចោលការទាមទារ ដើមចោទនៃសាលក្រម ឬ សាលដីកាដើម គឺជាដើមចោទនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ។ ប៉ុន្តែ ករណីសាលក្រម ឬ សាលដីកាដើមទទួលស្គាល់ការទាមទារ ដើមចោទនៃសាលក្រម ឬ សាលដីកាដើម ក្លាយជាចុងចម្លើយនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីវិញ ។

### ៣.២ អញ្ញត្រកម្ម

ទោះបីជាយ៉ាងនេះក៏ដោយ ក៏មានករណីខ្លះទៀត បុគ្គលដែលដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជាតតិយជន [៣១] ដែលមានន័យថាជាបុគ្គលផ្សេង ពីដើមចោទ និងចុងចម្លើយនៃសាលក្រម ឬ សាលដីកាដើម តែបុគ្គលនោះទទួលរងអានុភាពពីសាលក្រម ឬ សាលដីកាដើមនោះ ដែលអាចមានជាអាទិ៍៖ តតិយជនដែលជាអ្នកចូលរួមជួយអន្តរាគមន៍ [៣២] តតិយជនដែលទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ចពីភាគីតាមរយៈសន្តតិកម្មជាដើម និងតតិយជនក្នុងករណីដែលភាគីធ្វើជាដើមចោទ ឬ ចុងចម្លើយនៃបណ្តឹងជំនួសតតិយជននោះ [៣៣] ។ ករណីនេះ តតិយជនអាចធ្វើការទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយចាំបាច់លើកពីមូលហេតុណាមួយដូចមានកំណត់ក្នុងមាត្រា ៣០៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

បន្ថែមពីលើតតិយជនដែលរងអានុភាពពីសាលក្រម ឬ សាលដីកាខាងលើ ក៏នៅមានតតិយ-ជនមួយប្រភេទទៀត ដែលហៅថា "តតិយជនដែលពាក់ព័ន្ធផលប្រយោជន៍" ។ អនុលោមតាមមាត្រា

---

[៣០] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣០៧ និងមាត្រា៣០៨។

[៣១] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣១៨។

[៣២] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦។

[៣៣] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *នីតិវិធីបណ្តឹង* (ភាគ១ នៃសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ២០០៨), ២៣៥។

៣១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយតតិយជនដែលពាក់ព័ន្ធផលប្រយោជន៍នេះ ត្រូវបានហៅថា "បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដើម្បីកុំឱ្យមានការខូចខាតផលប្រយោជន៍" [៣៤] ។ បណ្តឹងប្រភេទនេះ ជាករណីពិសេសមួយនៃការទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលមិនចំណុះឱ្យមូលហេតុទាំង ១០ (ដប់) ដូចមានកំណត់ក្នុងមាត្រា ៣០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី នោះទេ ពោលគឺឱ្យតែលក្ខខណ្ឌបញ្ញត្តក្នុងមាត្រា ៣១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានបំពេញ នោះច្បាប់អនុញ្ញាតឱ្យតតិយជនធ្វើការទាមទារឱ្យជំនុំជម្រះសាជាថ្មីលើសាលក្រម ឬ សាលដីកាដែលចូលជាស្ថាពរបានហើយ ។ ក្នុងករណីនេះ តតិយជន គឺជាដើមចោទនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ហើយដើមចោទ និងចុងចម្លើយនៃសាលក្រម ឬ សាលដីកាដើមដែលចូលជាស្ថាពរ ក្លាយជាសហចុងចម្លើយនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ។

### កថាខណ្ឌទី៤ កម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

ជាគោលការណ៍ កម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺសាលក្រម ឬ សាលដីកា (៤.១) តែក៏មានករណីខ្លះ ដីកាសម្រេច (៤.២) ក៏ជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីផងដែរ ។

#### ៤.១ សាលក្រម ឬ សាលដីកា

កម្មវត្ថុចម្បងនៃបណ្តឹងទាមទារឱ្យជំនុំជម្រះជាថ្មី គឺសាលក្រម ឬ សាលដីកាចុងក្រោយដែលចូលជាស្ថាពរ ហើយមានវិការៈធ្ងន់ធ្ងរក្នុងនីតិវិធីបណ្តឹង ។ សាលក្រម ឬ សាលដីកាចុងក្រោយ សំដៅលើសេចក្តីសម្រេចរបស់តុលាការ ដែលបញ្ចប់រឿងក្តីទាំងមូល ឬ មួយភាគ និងដែលមានអានុភាពនៃអាជ្ញាអស់ជំនុំ ដែលក្នុងនោះរួមមាន៖ សាលក្រម ឬ សាលដីកាទទួលស្គាល់ការទាមទារ និងសាលក្រម ឬ សាលដីកាច្រានចោលការទាមទារ [៣៥] ។

ចំណែកឯសាលក្រមរបៀប ដែលជាសេចក្តីសម្រេចជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកានោះ ពុំមែនជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះជាថ្មីដោយឯករាជ្យទេ [៣៦] ប៉ុន្តែភាគីអាចយកមូលហេតុនៃការជំនុំជម្រះសាជាថ្មីតាមមាត្រា ៣០៧ នៃក្រមរដ្ឋប្បវេណី ដែលកើតលើសាលក្រមរបៀបនោះ មកធ្វើការទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះសាលក្រម ឬ សាលដីកាចុងក្រោយដែលចូលជាស្ថាពរបាន ទោះបីសាលក្រម ឬ សាលដីកាចុងក្រោយនោះមាន ឬ គ្មានអត្ថិភាពនៃមូលហេតុនៃ

[៣៤] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (២០០៧), ២៩៧។

[៣៥] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣១៨០។

[៣៦] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *នីតិវិធីបណ្តឹង* (ភាគ១ នៃសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ២០០៨), ២៣៣។

ការជំនុំជម្រះសាជាថ្មីក៏ដោយ ។ ប្រសិនបើសាលក្រមរបៀបជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មី ត្រូវបានលុបចោល និងសម្រេចសាជាថ្មី សាលក្រមរបៀបថ្មីនោះ នឹងក្លាយជាកម្មវត្ថុនៃការកែប្រែសេចក្តីសម្រេចបញ្ចប់នៃសាលក្រម ឬ សាលដីកាចុងក្រោយដែលបានចូលជាស្ថាពរហើយ ។ ស្ថានភាពនេះ អាចនាំឱ្យមានការជំនុំជម្រះសាជាថ្មីលើសាលក្រម ឬ សាលដីកាចុងក្រោយដែលបានចូលជាស្ថាពរនោះសាជាថ្មីម្តងទៀត ស្របតាមមូលហេតុដូចមានកំណត់ក្នុងមាត្រា ៣០៧ កថាខណ្ឌទី១ ចំណុច ជ ដែលនាំឱ្យមានការជំនុំជម្រះសាជាថ្មីចំនួនពីរលើកលើសំណុំរឿងតែមួយ ។ ដូចនេះ ដើម្បីកាត់បន្ថយឱ្យបានជាអតិបរមានូវការចំណាយពេលវេលា និងធនធានឥតប្រយោជន៍ចំពោះការជំនុំជម្រះជាច្រើនលើកច្រើនសារបែបនេះ មាត្រា ៣០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី អនុញ្ញាតឱ្យមានរបបនៃការយកមូលហេតុនៃការជំនុំជម្រះសាជាថ្មីលើសាលក្រមរបៀប ទៅធ្វើការទាមទារលើសាលក្រម ឬ សាលដីកាចុងក្រោយដែលបានចូលជាស្ថាពរតែម្តង ។

### ៤.២ ដីកាសម្រេច

ដីកាសម្រេច ក៏អាចជាកម្មវត្ថុនៃការទាមទារឱ្យជំនុំជម្រះសាជាថ្មីបានដែរ ក្នុងករណីដែលដីកាសម្រេចនោះ គឺជាដីកាសម្រេចដែលអាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដោយបណ្តឹងជំទាស់ និងដែលបានចូលជាស្ថាពរ [៣៧] ។ ការទាមទារឱ្យជំនុំជម្រះសាជាថ្មីលើដីកាសម្រេច អាចចាប់ផ្តើមឡើងដោយឯករាជ្យ តាមរយៈពាក្យសុំទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលត្រូវអនុវត្តដូចគ្នាទៅនឹងបញ្ញត្តិស្តីពីពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលមានកំណត់ចាប់ពីមាត្រា ៣០៧ ដល់មាត្រា៣១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ដីកាសម្រេចដូចមានកំណត់ក្នុងមាត្រា ៣១៧ មានជាអាទិ៍៖ ដីកាសម្រេចដែលសម្រេចថាការដកហូត ឬ បណ្តឹងជិតចិត្តពុំត្រឹមត្រូវ (មាត្រា ៣០ កថាខណ្ឌទី៦) និងដីកាសម្រេចអំពីការបដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សី (មាត្រា ១៣៥ កថាខណ្ឌទី២) ជាដើម ។

បន្ថែមពីនេះ ដីកាសម្រេចដែលជាសេចក្តីសម្រេចបញ្ចប់ដូចមានកំណត់ក្នុងច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ក៏អាចជាកម្មវត្ថុនៃពាក្យសុំទាមទារឱ្យជំនុំជម្រះសាជាថ្មីតាមមាត្រា ៣១៧ ខាងលើនេះដែរ ប្រសិនបើដីកាសម្រេចនោះមានមូលហេតុជំនុំជម្រះសាជាថ្មី ។

---

[៣៧] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣១៧។

## កថាខណ្ឌទី៥ ការកម្រិតអំឡុងពេល

បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវធ្វើឡើងនៅក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃដែលភាគីបានដឹងពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី ក្រោយពេលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរហើយ [៣៨] ។

អំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតពីថ្ងៃដែលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរ ឬ ថ្ងៃដែលមូលហេតុនៃការជំនុំជម្រះសាជាថ្មីកើតមានឡើង ក្រោយពេលដែលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរហើយ ដោយមិនមានពាក់ព័ន្ធនឹងការដឹង ឬ មិនដឹងរបស់ភាគីទេ[៣៩] ។

ជាអញ្ញត្រកម្មនៃការកម្រិតអំឡុងពេលខាងលើ ចំពោះបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលផ្អែកលើមូលហេតុខ្វះសិទ្ធិតំណាង (ចំណុច **គ** នៃមាត្រា ៣០៧ កថាខណ្ឌទី១) ឬ មូលហេតុដែលសាលក្រម ឬ សាលដីកាថ្មីបំពានសាលក្រម ឬ សាលដីកាមុនដែលបានចូលជាស្ថាពរ (ចំណុច **ញ** នៃមាត្រា ៣០៧ កថាខណ្ឌទី១) អំឡុងពេល ៣០ (សាមសិប) ថ្ងៃ ឬ ៥ (ប្រាំ) ឆ្នាំ ដូចបានកំណត់ក្នុង មាត្រា ៣១១ កថាខណ្ឌទី១ និងទី៣ មិនត្រូវបានកម្រិតឡើយ ពោលគឺ ភាគីអាចដាក់ពាក្យបណ្ដឹងនៅពេលណាក៏បាន ដោយមិនចាំបាច់គោរពតាមអំឡុងពេលខាងលើនេះទេ ដោយផ្អែកលើមូលហេតុថា ក្នុងករណីដែលយកការខ្វះសិទ្ធិតំណាង មកធ្វើជាមូលហេតុនៃការជំនុំជម្រះសាជាថ្មី បណ្ដឹងដែលមានសាលក្រម ឬ សាលដីកាហើយនោះ ត្រូវបានធ្វើឡើងក្នុងពេលដែលសាមីភាគី និងអ្នកតំណាងដែលច្បាប់បានកំណត់មិនបានដឹងសោះ ហើយតុលាការបានចេញសាលក្រម ឬ សាលដីកា ដោយមិនធានានូវសិទ្ធិមូលដ្ឋាននៃនីតិវិធីចំពោះភាគី ហេតុដូច្នេះ ការកម្រិតអំឡុងពេលសម្រាប់បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបែបនេះ គឺផ្ទុយនឹងយុត្តិធម៌ ។ ម្យ៉ាងទៀត ក្នុងករណីដែលសាលក្រម និងសាលដីកាដែលតុលាការបានចេញមុន និងចេញក្រោយនោះមានការប៉ះពាល់គ្នា ការកម្រិតអំឡុងពេលសម្រាប់បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី នឹងនាំឱ្យមានភាពច្របូកច្របល់ ដោយហេតុថា គ្មានភាពច្បាស់លាស់ក្នុងការកំណត់ទំនាក់ទំនងគតិយុត្តរវាងភាគី ដោយសាលក្រម ឬ សាលដីកាណាមួយទេ ដូច្នេះ មិនត្រូវធ្វើការកម្រិតនូវអំឡុងពេលប្ដឹងទាមទារសុំឱ្យជំនុំជម្រះសាជាថ្មីទេ [៤០] ។

ក្នុងករណីដែលភាគីបានដាក់ពាក្យបណ្ដឹង ក្រោយពីអំឡុងពេលដែលបានកំណត់ក្នុងមាត្រា ៣១១ បានកន្លងផុត ពាក្យបណ្ដឹងនោះ នឹងក្លាយជាកម្មវត្ថុនៃការលើកចោលដោយដីកាសម្រេច

[៣៨] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣១១ កថាខណ្ឌទី១ វាក្យខណ្ឌទី១ ។

[៣៩] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣១១ កថាខណ្ឌទី៣ វាក្យខណ្ឌទី១ ។

[៤០] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *នីតិវិធីបណ្ដឹង* (ភាគ១ នៃសេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ២០០៨), ២៣៤។

ស្របតាមមាត្រា ៣១៩ កថាខណ្ឌទី១ ព្រោះវាជាពាក្យបណ្តឹងដែលមានភាពផ្ទុយនឹងច្បាប់ ។

## ផ្នែកទី២ លក្ខខណ្ឌទម្រង់

ពាក្យបណ្តឹងជំនុំជម្រះសាជាថ្មី ត្រូវគោរពតាមលក្ខខណ្ឌទម្រង់ ដែលចាំបាច់តម្រូវឱ្យភាគីនៃបណ្តឹងប្រតិបត្តិតាម បន្ថែមពីលើលក្ខខណ្ឌសារធាតុដូចបានរៀបរាប់នៅក្នុងផ្នែកទី១ (លក្ខខណ្ឌសារធាតុ) ខាងលើ ។ នៅក្នុងករណីដែលមានភាពខ្វះខាតក្នុងការសរសេរចំណុចចាំបាច់ ជាអាទិ៍ តុលាការនឹងបង្គាប់ឱ្យកែតម្រូវលើចំណុចខ្វះខាតនោះ យោងទៅតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងពាក្យបណ្តឹងធម្មតា ហើយប្រសិនបើភាគីមិនគោរពប្រតិបត្តិតាមនោះទេ ពាក្យបណ្តឹងនោះនឹងត្រូវក្លាយជាកម្មវត្ថុនៃការលើកចោលដោយដីកាសម្រេច ដែលពុំនាំឱ្យមានការជំនុំជម្រះសាជាថ្មីលើសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ ដូចអ្វីដែលដើមចោទចង់បានឡើយ ។ ហេតុដូចនេះហើយ ភាគីដើមចោទនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចាំបាច់ត្រូវយល់ដឹងអំពីរបៀបនៃការសរសេរពាក្យបណ្តឹង (កថាខណ្ឌទី១) និង ការដាក់ពាក្យបណ្តឹង (កថាខណ្ឌទី២) ទៅតុលាការដែលមានសមត្ថកិច្ច រួមទាំងការបង់ពន្ធដាក់ពាក្យសុំ ដែលមានលក្ខណៈត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ទើបតុលាការទទួលស្គាល់ ។

### កថាខណ្ឌទី១ ការសរសេរពាក្យបណ្តឹង

ការសរសេរពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានត្រឹមត្រូវ មានសារសំខាន់ជាអនេកចំពោះដើមចោទនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ពីព្រោះភាពត្រឹមត្រូវនៃពាក្យបណ្តឹងជាកត្តាដែលជម្រុញឱ្យមានការចាប់ផ្តើមនីតិវិធីនៃការជំនុំជម្រះសាជាថ្មីទៅដោយរលូន ។ ពាក្យបណ្តឹងដែលមានភាពត្រឹមត្រូវ គឺជាពាក្យបណ្តឹងដែលមាន៖ ចំណុចដែលត្រូវសរសេរគ្រប់គ្រាន់ (១.១) និង ឯកសារភ្ជាប់ត្រឹមត្រូវ (១.២) ។ បន្ទាប់ពីពេលដែលពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវបានសរសេរដោយមានលក្ខណៈត្រឹមត្រូវ និងពេញលេញ ភាគីអាចយកពាក្យបណ្តឹងនោះទៅដាក់ជូនតុលាការបានហើយ ។

#### ១.១ ចំណុចដែលត្រូវសរសេរ[៦១]

ចំណុចចាំបាច់ដែលទាមទារឱ្យភាគីសរសេរក្នុងពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមានជាអាទិ៍៖

- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី

[៦១] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣១២ កថាខណ្ឌទី១។

* និងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ករណីដែលមានអ្នកតំណាងដែលច្បាប់បានកំណត់ ។

- សញ្ញាណនៃសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មី ដែលអាចត្រូវបានបញ្ជាក់តាមរយៈអត្តសញ្ញាណនៃភាគី និងលេខនៃសំណុំរឿងជាដើម[៤២] ។
- សេចក្តីទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះសាលក្រម ឬ សាលដីកានោះ ដែលអាចស្ថិតនៅក្នុងរូបភាពពីរគឺ៖ ទី១-ទាមទារឱ្យច្រានចោលការទាមទាររបស់ចុងចម្លើយនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ក្នុងករណីដែលសាលក្រម ឬ សាលដីកាដើមទទួលស្គាល់ការទាមទារ និងទី២-ទាមទារដូចក្នុងពាក្យបណ្តឹងនៃសាលក្រម ឬ សាលដីកាដើមមួយផ្នែក ឬ ទាំងស្រុង ក្នុងករណីដែលសាលក្រម ឬ សាលដីកាដើមច្រានចោលការទាមទារ ។
- អង្គហេតុដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មី ។

### ១.២ ឯកសារភ្ជាប់

យោងតាមមាត្រា ៣១២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឯកសារដែលភាគីចាំបាច់ត្រូវភ្ជាប់មកជាមួយនឹងពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី នៅពេលដាក់ពាក្យបណ្តឹងនេះទៅតុលាការមានសមត្ថកិច្ច គឺឯកសារចម្លងនៃសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មី ។

## កថាខណ្ឌទី២ ការដាក់ពាក្យបណ្តឹង

បន្ទាប់ពីត្រូវបានបំពេញបែបបទបានត្រឹមត្រូវក្នុងការសរសេរពាក្យបណ្តឹងតាមកថាខណ្ឌទី១ខាងលើហើយ ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះ ត្រូវយកទៅដាក់នៅលេខាធិការដ្ឋាននៃតុលាការដែលមានសមត្ថកិច្ច (២.១) ហើយស្របពេលជាមួយគ្នានេះ ត្រូវភ្ជាប់ជាមួយនឹងការបង់ពន្ធដាក់ពាក្យសុំ (២.២) តាមការកំណត់របស់ច្បាប់ ទើបអាចឱ្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះ បង្កើតអានុភាពគតិយុត្តបាន ។

[៤២] Kazuyuki, Higashio., Ryo, Yukawa. និង Jun, Uchiyama, "ការជំនុំជម្រះសាជាថ្មី" (បទបង្ហាញនៅក្នុងសិក្ខាសាលាស្តីពីបញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី, សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ, ១៧ មករា ២០១៨), ១៥។

### ២.១ តុលាការមានសមត្ថកិច្ច

តុលាការ ដែលមានសមត្ថកិច្ចផ្ដាច់មុខ[៤៣] ក្នុងការទទួល និងធ្វើចំណាត់ការលើបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺតុលាការដែលបានចេញសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មីនោះ[៤៤] ។

ជាគោលការណ៍ ក្នុងករណីដែលមិនមានបណ្ដឹងឧបាស្រ័យចំពោះសាលក្រមនៃតុលាការជាន់ទាប ដែលបានចូលជាស្ថាពរដែលជាកម្មវត្ថុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី តុលាការតែមួយគត់ដែលមានសមត្ថកិច្ច គឺតុលាជាន់ទាប ដែលសំដៅដល់សាលាដំបូងរាជធានី-ខេត្ត ។

ដោយឡែក បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះសាលក្រម ឬ សាលដីកាអំពីរឿងតែមួយដែលត្រូវបានចេញដោយតុលាការច្រើនដែលមានថ្នាក់ខុសគ្នា តុលាការដែលមានសមត្ថកិច្ចរួមបញ្ចូលសាលក្រម ឬ សាលដីកាទាំងនោះ គឺតុលាការជាន់ខ្ពស់ ដែលសំដៅដល់សាលាឧទ្ធរណ៍ ឬ តុលាការកំពូល[៤៥] ។

ក្នុងករណីដែលមានការប្ដឹងឧទ្ធរណ៍ចំពោះសាលក្រមនៃសាលាដំបូង ហើយតុលាការនៃបណ្ដឹងឧទ្ធរណ៍ បានធ្វើការវិនិច្ឆ័យលើអង្គសេចក្ដី និងបានចេញសាលដីកាចុងក្រោយ ដែលបានចូលជាស្ថាពរ ហើយប្រសិនបើមានការទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះសាលក្រម និងសាលដីកាទាំងពីរ នោះសាលដីកានៃសាលាឧទ្ធរណ៍ ដែលជាសេចក្ដីសម្រេចរបស់តុលាការដែលមានថ្នាក់ខ្ពស់ជាង ត្រូវក្លាយជាកម្មវត្ថុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ហើយតុលាការដែលមានសមត្ថកិច្ច គឺសាលាឧទ្ធរណ៍ ។ ប៉ុន្តែ បន្ថែមពីលើករណីខាងលើ ប្រសិនបើមានការប្ដឹងសាទុក្ខចំពោះសាលដីកានៃសាលាឧទ្ធរណ៍ ហើយតុលាការកំពូល បានចេញសាលដីកាចុងក្រោយដែលចូលជាស្ថាពរ នោះសាលដីកានៃតុលាការកំពូល ដែលជាសេចក្ដីសម្រេចរបស់តុលាការដែលមានថ្នាក់ខ្ពស់ជាងគេ ត្រូវក្លាយជាកម្មវត្ថុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ហើយតុលាការដែលមានសមត្ថកិច្ច គឺតុលាការកំពូល ។ មូលហេតុនៃការផ្ដល់សមត្ថកិច្ចផ្ដាច់មុខនេះជូនដល់តុលាការជាន់ខ្ពស់ គឺដើម្បីបញ្ចៀសនូវភាពច្របូកច្របល់ពាក់ព័ន្ធនឹងបញ្ហាអាជ្ញាអស់ជំនុំនៃអង្គហេតុ ដែលអាចកើតមានឡើង ដោយការជំនុំជម្រះច្រើនដង ដោយតុលាការថ្នាក់ខុសគ្នាលើរឿងតែមួយ ។ ដូច្នេះ តុលាការដែលមានថ្នាក់ខ្ពស់ គឺជាតុលាការមានសមត្ថកិច្ចក្នុងការដោះស្រាយបញ្ហាសាំញ៉ាំបែបនេះ[៤៦] ។

---

[៤៣] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៥។

[៤៤] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣០៩ កថាខណ្ឌទី១។

[៤៥] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣០៩ កថាខណ្ឌទី២។

[៤៦] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (២០០៧), ២៨៧។

(រូបទី២) តុលាការដែលមានសមត្ថកិច្ចចំពោះបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី




ចៅក្រម ដែលបានចេញសាលក្រម ឬ សាលដីកា ដែលជាកម្មវត្ថុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវបានហាមឃាត់មិនឱ្យចូលរួមក្នុងការវិនិច្ឆ័យ និងចេញសេចក្ដីសម្រេចណាមួយលើបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានទេ [៤៧] ដើម្បីជៀសវាងនូវស្ថានភាពបុរេវិនិច្ឆ័យ ។

[៤៧] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣០៩ កថាខណ្ឌទី៣។

**២.២ ពន្ធដាក់ពាក្យសុំ**

ពន្ធដាក់ពាក្យសុំនេះ គឺជាប្រាក់ពន្ធដែលភាគីត្រូវបង់នៅពេលដាក់ពាក្យបណ្ដឹងទៅតុលាការដែលមានសមត្ថកិច្ច ដើម្បីឱ្យមានចំណាត់ការរបស់តុលាការលើបណ្ដឹងរបស់ខ្លួន ដោយត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ ។

អនុលោមតាមមាត្រា ៦១ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដើមបណ្ដឹងនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវបង់ពន្ធដាក់ពាក្យសុំចំពោះបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនេះនូវចំនួនទឹកប្រាក់ ១០.០០០៛ (មួយម៉ឺនរៀល) ទៅតុលាការ ដើម្បីឱ្យមានចំណាត់ការលើពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនេះ ។

# ជំពូកទី៣

## ចំណាត់ការលើបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

## ជំពូកទី៣ ចំណាត់ការលើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

នៅពេលដែលបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីត្រូវបានបង្កើតអានុភាព តុលាការត្រូវធ្វើការចាប់ផ្តើមចំណាត់ការលើបណ្តឹង ដោយគ្មានការយឺតយ៉ាវ ។ ចំណាត់ការរបស់តុលាការលើបណ្តឹង សំដៅទៅលើការវិនិច្ឆ័យ និងសម្រេចសេចក្តីរបស់តុលាការចំពោះបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ។ ដំណាក់កាលនៃការជំនុំជម្រះសាជាថ្មី អាចធ្វើឡើងតាមការអនុវត្តតាមនីតិវិធីធំៗចំនួនពីរបន្តបន្ទាប់គ្នាគឺ ដំបូង តុលាការត្រូវធ្វើការជំនុំជម្រះលើភាពត្រឹមត្រូវនៃបណ្តឹង (ផ្នែកទី១) ហើយបើពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មានលក្ខណៈត្រឹមត្រូវ និងបំពេញគ្រប់លក្ខខណ្ឌដែលច្បាប់កំណត់អស់ហើយ តុលាការត្រូវបន្តនីតិវិធីលើការជំនុំជម្រះលើអង្គសេចក្តី (ផ្នែកទី២) ។

### ផ្នែកទី១ ការវិនិច្ឆ័យ និងសម្រេចសេចក្តីលើភាពត្រឹមត្រូវនៃបណ្តឹង

នីតិវិធីនៃការជំនុំជម្រះលើភាពត្រឹមត្រូវនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជាការវិនិច្ឆ័យ និងសម្រេចសេចក្តីថាអនុញ្ញាត ឬ មិនអនុញ្ញាតឱ្យប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី[៤៨] ដោយពិចារណាទៅលើលក្ខខណ្ឌចំនួន ០២ (ពីរ) គឺ អំពីភាពស្របច្បាប់នៃបណ្តឹង (កថាខណ្ឌទី១) និងអំពីអត្ថិភាព ឬ នត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី (កថាខណ្ឌទី២) ។

#### កថាខណ្ឌទី១ ភាពស្របច្បាប់នៃបណ្តឹង

ដំណាក់កាលនៃនីតិវិធីនេះ ជាដំណាក់កាលនៃនីតិវិធីនៃដីកាសម្រេច ដូចនេះការទាញហេតុផលដោយផ្ទាល់មាត់ មិនមានភាពចាំបាច់ត្រូវធ្វើ មុនពេលតុលាការចេញដីកាសម្រេចនោះទេ[៤៩] ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីហើយ តុលាការត្រូវវិនិច្ឆ័យដោយគ្មានការយឺតយ៉ាវ អំពីភាពស្របច្បាប់នៃបណ្តឹងថាតើពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះមានលក្ខខណ្ឌគ្រប់គ្រាន់ ស្របតាមការកំណត់របស់ច្បាប់ដែរឬទេ ។

ការវិនិច្ឆ័យទៅលើលក្ខខណ្ឌស្របច្បាប់នៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចធ្វើឡើងដោយផ្អែកតាមការពិចារណាទៅលើ ០៤ (បួន) ចំណុចសំខាន់ៗ មានជាអាទិ៍៖ ភាពបង្គ្រប់កិច្ចភាគីនៃបណ្តឹង កម្មវត្ថុនៃបណ្តឹង និងការកម្រិតអំឡុងពេលនៃការទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលជាលក្ខខណ្ឌសារធាតុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ។ គួរឱ្យកត់សម្គាល់ផងដែរ លក្ខខណ្ឌ

---

[៤៨] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (២០០៧), ២៩៣។

[៤៩] Kazuyuki, Higashio., Ryo, Yukawa. និង Jun, Uchiyama, "ការជំនុំជម្រះសាជាថ្មី" (បទបង្ហាញនៅក្នុងសិក្ខាសាលាស្តីពីបញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី, សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ, ១៧ មករា ២០១៨), ៣៣។

សារធាតុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជាលក្ខខណ្ឌដែលមិនអាចកែប្រែបានឡើយ ដែលវាមានលក្ខណៈខុសពីលក្ខខណ្ឌទម្រង់ ដូចនេះ ប្រសិនបើមានភាពមិនត្រឹមត្រូវលើលក្ខខណ្ឌសារធាតុ តុលាការមិនអាចបង្គាប់ឱ្យភាគីធ្វើការកែតម្រូវ ដូចទៅនឹងលក្ខខណ្ឌទម្រង់នោះទេ ។ ហេតុដូចនេះបានជានៅពេលដែលបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មិនមានភាពត្រឹមត្រូវពាក់ព័ន្ធនឹងលក្ខខណ្ឌសារធាតុទាំង ០៤ (បួន) ខាងលើនេះ បណ្តឹងនោះនឹងក្លាយជាកម្មវត្ថុនៃការលើកចោលដោយដីកាសម្រេច តាមមាត្រា ៣១៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ប៉ុន្តែ ស្របពេលជាមួយគ្នានេះផងដែរ មាត្រា ៣១៤ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ក៏បើកសិទ្ធិឱ្យភាគីធ្វើការប្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនេះបានដែរ ។

ដោយឡែក ចំពោះលក្ខខណ្ឌទម្រង់នៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីវិញ ដែលមានដូចជាការសរសេរពាក្យបណ្តឹងឱ្យបានត្រឹមត្រូវគ្រប់ចំណុចដែលច្បាប់កំណត់ រួមទាំងមានភ្ជាប់មកជាមួយនូវសេចក្តីចម្លងនៃសេចក្តីសម្រេចដែលជាកម្មវត្ថុនៃការទាមទារ និងការដាក់ពាក្យបណ្តឹងទៅតុលាការដែលមានសមត្ថកិច្ច ព្រមទាំងការបង់ពន្ធដាក់ពាក្យសុំឱ្យបានត្រឹមត្រូវតាមច្បាប់ ជាអាទិ៍ គឺត្រូវអនុវត្តតាមបទប្បញ្ញត្តិទូទៅ ដោយសារតែនត្ថិភាពនៃបទប្បញ្ញត្តិពិសេស ។ ជាឧទាហរណ៍ ក្នុងករណីដែលពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមានលក្ខណៈមិនត្រឹមត្រូវ ឬ មិនគ្រប់គ្រាន់ តាមចំណុចដែលត្រូវសរសេរ ដូចមានកំណត់ក្នុងមាត្រា ៣១២ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការត្រូវចាត់ចែងឱ្យកែតម្រូវដូចករណីបណ្តឹងធម្មតាដែរ ។ ប្រសិនបើមានការកំណត់អំឡុងពេលសមរម្យ និងបង្គាប់ឱ្យកែតម្រូវនូវចំណុចខ្វះខាតដោយតុលាការ តែភាគីដើមចោទនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី នៅតែមិនបានកែតម្រូវ នៅក្នុងអំឡុងពេលនោះទៀត តុលាការត្រូវចេញដីកាសម្រេចលើកចោលពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី តាមមាត្រា ៣១០ និងមាត្រា ៧៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ប្រសិនបើពាក្យបណ្តឹង មានភាពត្រឹមត្រូវស្របតាមច្បាប់កំណត់ហើយ តុលាការត្រូវបន្តនីតិវិធី ដោយវិនិច្ឆ័យពីអត្ថិភាព ឬ នត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី ដូចមានរៀបរាប់ក្នុងចំណុចបន្ទាប់ ។

### កថាខណ្ឌទី២ អត្ថិភាព ឬ នត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី

ការទាញហេតុផលផ្ទាល់មាត់នៅក្នុងដំណាក់កាលនៃនីតិវិធីនេះ ក៏មិនមានភាពចាំបាច់ដែរ ព្រោះការជំនុំជម្រះពីអត្ថិភាព ឬ នត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មីនេះ គឺជាដំណាក់កាលនៃការចេញដីកាសម្រេច ដែលដូចគ្នាទៅនឹងដំណាក់កាលនៃនីតិវិធីជំនុំជម្រះពីភាពស្របច្បាប់នៃបណ្តឹងដែរ ។ ក្នុងដំណាក់កាលនេះ តុលាការត្រូវធ្វើការវិនិច្ឆ័យលើមូលហេតុដែលដើមចោទនៃ

បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី បានសរសេរក្នុងពាក្យបណ្តឹងរបស់ខ្លួន និងធ្វើការសម្រេចថា មូលហេតុនោះមានភាពអត្ថិភាព ឬ នត្ថិភាព ដូចមូលហេតុណាមួយ ក្នុងចំណោមមូលហេតុទាំង ១០ (ដប់) នៃការជំនុំជម្រះសាជាថ្មី ដែលមានបញ្ញត្តក្នុងមាត្រា ៣០៧ កថាខណ្ឌទី១ ឬ មូលហេតុពិសេស ដូចមានកំណត់ក្នុងមាត្រា ៣១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ក្នុងករណីដែលពុំមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី តុលាការត្រូវចេញដីកាសម្រេចច្រានចោលនូវការទាមទារឱ្យជំនុំជម្រះសាជាថ្មី តាមមាត្រា៣១៤ កថាខណ្ឌទី២ ។

ផ្ទុយទៅវិញ ក្នុងករណីដែលមានអត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មីវិញ តុលាការត្រូវចេញដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី តាមមាត្រា ៣១៥ កថាខណ្ឌទី១ ដោយត្រូវសួរចុងចម្លើយជាមុន ប៉ុន្តែការសួរនេះ មិនមែនជានីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ទេ ដូចនេះ តុលាការអាចធ្វើតាមលិខិតជាលាយលក្ខណ៍អក្សរបាន [៥០] ។ ការសួរចុងចម្លើយជាមុននេះ គឺជាលក្ខខណ្ឌដែលត្រូវបំពេញ មុននឹងតុលាការចេញដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី ដែលផ្ទុយពីការចេញដីកាសម្រេចលើកចោល និងដីកាសម្រេចច្រានចោល ដែលមិនចំណុះឱ្យលក្ខខណ្ឌនៃការសួរចុងចម្លើយជាមុននោះទេ ។ មូលហេតុនៃការកំណត់លក្ខខណ្ឌបែបនេះ ដោយហេតុថា ដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី អាចនឹងប៉ះពាល់ដល់ផលប្រយោជន៍របស់ចុងចម្លើយនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដូចនេះភាគីចុងចម្លើយនេះ គប្បីដឹងពីអត្ថិភាពនៃការចាប់ផ្តើមនីតិវិធីដើម្បីឱ្យខ្លួនមានឱកាសត្រៀមលក្ខណៈគ្រប់គ្រាន់ ក្នុងការចូលរួមនីតិវិធីនៃអង្គសេចក្តីនោះជាដើម ។

មាត្រា ៣១៤ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី អនុញ្ញាតឱ្យមានការប្តឹងជំទាស់ចំពោះដីកាសម្រេចច្រានចោលបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ហើយមាត្រា ៣១៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ក៏អនុញ្ញាតឱ្យមានការប្តឹងជំទាស់ផងដែរ ចំពោះដីកាសម្រេចចាប់ផ្តើមការជំនុំជម្រះសាជាថ្មី ។

## ផ្នែកទី២ ការវិនិច្ឆ័យ និងសម្រេចសេចក្តីលើអង្គសេចក្តី

បន្ទាប់ពីដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មីបានចូលជាស្ថាពរ តុលាការត្រូវធ្វើការជំនុំជម្រះសាជាថ្មីលើអង្គសេចក្តី ដែលរួមមានការវិនិច្ឆ័យលើអង្គសេចក្តី (កថាខណ្ឌទី១) និងការចេញសាលក្រម ឬ សាលដីកាសាជាថ្មី (កថាខណ្ឌទី២) ។

[៥០] Kazuyuki, Higashio., Ryo, Yukawa. និង Jun, Uchiyama, "ការជំនុំជម្រះសាជាថ្មី" (បទបង្ហាញនៅក្នុងសិក្ខាសាលាស្តីពីបញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី, សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ, ១៧ មករា ២០១៨), ៣៧។

**កថាខណ្ឌទី១ ការវិនិច្ឆ័យលើអង្គសេចក្តី**

អនុលោមតាមមាត្រា ៣១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ការវិនិច្ឆ័យសាជាថ្មីលើអង្គសេចក្តី ត្រូវអនុវត្តទៅតាមលំដាប់ថ្នាក់នៃសាលក្រម ឬ សាលដីកា ដែលជាកម្មវត្ថុនៃការជំនុំជម្រះនីមួយៗ ។ ការជំនុំជម្រះសាជាថ្មីលើសាលក្រមរបស់សាលាដំបូង ត្រូវធ្វើតាមនីតិវិធីនៃការជម្រះក្តីលើកទី១ ឬ នីតិវិធីនៃការជម្រះក្តីរបស់សាលាដំបូង ។ ការជំនុំជម្រះសាជាថ្មីលើសាលដីកានៃការជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ត្រូវធ្វើតាមនីតិវិធីនៃការជម្រះក្តីលើកទី២ ឬ នីតិវិធីនៃការជម្រះក្តីលើបណ្តឹងឧទ្ធរណ៍ ។ ចំណែកឯ ការជំនុំជម្រះសាជាថ្មីលើសាលដីកានៃការជំនុំជម្រះបណ្តឹងសាទុក្ខ ត្រូវធ្វើតាមនីតិវិធីនៃការជម្រះក្តីលើកទី៣ ឬ នីតិវិធីនៃការជម្រះក្តីលើបណ្តឹងសាទុក្ខ ។ ការវិនិច្ឆ័យនេះ គឺជាការបន្តនូវនីតិវិធីនៃបណ្តឹងមុន ដោយមានការផ្លាស់ប្តូរនូវសមាសភាពនៃចៅក្រម ។

**កថាខណ្ឌទី២ សាលក្រម ឬ សាលដីកា**

លទ្ធផលនៃការវិនិច្ឆ័យលើអង្គសេចក្តី គឺសាលក្រម ឬ សាលដីកា ដែលអាចស្ថិតនៅក្រោមរូបភាពពីរគឺៈ ការច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី (២.១) និងការលុបចោលសេចក្តីសម្រេចដើម និងសម្រេចសាជាថ្មី (២.២) ។

**២.១ ការច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី**

បន្ទាប់ពីតុលាការបានធ្វើការវិនិច្ឆ័យសាជាថ្មីលើអង្គសេចក្តីរួចមក ប្រសិនបើតុលាការយល់ឃើញថាសាលក្រម ឬ សាលដីកាដើមដែលបានចូលជាស្ថាពរមានលក្ខណៈត្រឹមត្រូវ ដោយសារតែលទ្ធផលនៃការវិនិច្ឆ័យដើម និងលទ្ធផលនៃការវិនិច្ឆ័យសាជាថ្មី ដូចគ្នាដដែល នោះតុលាការត្រូវចេញសាលក្រម ឬ សាលដីកាច្រានចោលការទាមទារ ស្របតាមមាត្រា៣១៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលមានខ្លឹមសារច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី ហើយតម្កល់អត្ថិភាពនៃសាលក្រម ឬ សាលដីកាដើមដែលចូលជាស្ថាពរទុកជាបានការដដែល ។ ស្ថានភាពបែបនេះ ជាទូទៅ កើតឡើងនៅពេលភាគីលើកយកមូលហេតុពាក់ព័ន្ធនឹងការបំពាននីតិវិធីធ្ងន់ធ្ងរដូចមានកំណត់ក្នុងមាត្រា ៣០៧ កថាខណ្ឌទី១ ចំណុច **ក** ចំណុច **ខ** និងចំណុច **គ** ដោយហេតុថាការបំពាននីតិវិធីពុំសូវជាមានឥទ្ធិពលលើការទាមទារលើអង្គសេចក្តី ដែលអាចនាំឱ្យលទ្ធផលនៃការវិនិច្ឆ័យមានការផ្លាស់ប្តូរនោះទេ [៥១] ។ គួរបញ្ជាក់ផងដែរថា ការច្រានចោលការទាមទារឱ្យជំនុំ

[៥១] Kazuyuki, Higashio., Ryo, Yukawa. និង Jun, Uchiyama, "ការជំនុំជម្រះសាជាថ្មី" (បទបង្ហាញនៅក្នុងសិក្ខាសាលាស្តីពីបញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី, សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ, ១៧ មករា ២០១៨), ៧០។

ជម្រះសាជាថ្មីនេះ ពុំមែនជាការច្រានចោលការទាមទាររបស់ដើមចោទនៃសាលក្រម ឬ សាលដីកាដើមឡើយ ។

## ២.២ ការលុបចោលសេចក្តីសម្រេចដើម និងសម្រេចសាជាថ្មី

ផ្ទុយទៅវិញ ក្នុងករណីដែលតុលាការយល់ឃើញថា លទ្ធផលនៃការវិនិច្ឆ័យដើម និងលទ្ធផលនៃការវិនិច្ឆ័យសាជាថ្មីមានលក្ខណៈផ្ទុយគ្នា តុលាការត្រូវចេញសាលក្រម ឬ សាលដីកាថ្មី ដែលមានខ្លឹមសារសម្រេចលុបចោលសាលក្រម ឬ សាលដីកាដើមដែលបានចូលជាស្ថាពរ និងសម្រេចសាជាថ្មីលើការទាមទារក្នុងអង្គសេចក្តីរបស់ដើមបណ្តឹងនៃសាលក្រម ឬ សាលដីកាដើមស្របតាមមាត្រា ៣១៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ជាក់ស្តែង ចំពោះសាលក្រម ឬ សាលដីកាដើមដែលទទួលស្គាល់ការទាមទារ តុលាការត្រូវចេញសាលក្រម ឬ សាលដីកាថ្មី ដែលនៅក្នុងសេចក្តីសម្រេចបញ្ចប់ត្រូវសរសេរបញ្ជាក់ថា លុបចោលសាលក្រម ឬ សាលដីកាដើម និងច្រានចោលការទាមទារក្នុងអង្គសេចក្តី ។ ប៉ុន្តែ ចំពោះសាលក្រម ឬ សាលដីកាដើមដែលច្រានចោលការទាមទារវិញ តុលាការត្រូវចេញសាលក្រម ឬ សាលដីកាថ្មី ដែលនៅក្នុងសេចក្តីសម្រេចបញ្ចប់ត្រូវសរសេរបញ្ជាក់ថា លុបចោលសាលក្រម ឬ សាលដីកាដើម និងទទួលស្គាល់ការទាមទារក្នុងអង្គសេចក្តី [៥២] ។

ភាគីដែលទទួលអានុភាពពីសាលក្រម ឬ សាលដីកាថ្មីនេះ អាចប្តឹងឧទ្ធរណ៍ចំពោះសាលក្រមនៃការជំនុំជម្រះលើកទី១ ឬ ប្តឹងសាទុក្ខចំពោះសាលដីកានៃបណ្តឹងឧទ្ធរណ៍បាន ដោយគោរពតាមបទប្បញ្ញត្តិនៃការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ តាមលំដាប់ថ្នាក់នៃការជំនុំជម្រះនីមួយៗ ស្របតាមការអនុញ្ញាតដែលមានចែងក្នុងមាត្រា ៣១០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

[៥២] Kazuyuki, Higashio., Ryo, Yukawa. និង Jun, Uchiyama, "ការជំនុំជម្រះសាជាថ្មី" (បទបង្ហាញនៅក្នុងសិក្ខាសាលាស្តីពីបញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី, សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ, ១៧ មករា ២០១៨), ៧២ ដល់ ៧៦។

# សេចក្ដីសន្និដ្ឋាន

ជាគោលការណ៍ ដំណោះស្រាយចំពោះវិវាទរវាងបុគ្គលឯកជន អាចត្រូវបានធ្វើទៅបានតាមពីរមធ្យោបាយ គឺដំណោះស្រាយតាមផ្លូវឯកជន ដែលហៅថាដំណោះស្រាយក្រៅផ្លូវតុលាការ និងដំណោះស្រាយតាមផ្លូវតុលាការ ។ នៅពេលដែលវិវាទ មិនអាចត្រូវបានដោះស្រាយដោយបុគ្គលឯកជនជាភាគីខ្លួនឯងបានទេ ភាគីដែលកើតទុក្ខមិនសុខចិត្ត អាចសុំឱ្យស្ថាប័នមានសមត្ថកិច្ច ដែលជាតុលាការទាំងបីថ្នាក់ ធ្វើអន្តរាគមន៍ចំពោះវិវាទនោះតាមផ្លូវបណ្ដឹង ដែលបង្កើតឱ្យមានការជំនុំជម្រះក្ដីក្នុងរឿងរដ្ឋប្បវេណី តាមទម្រង់ជាក់លាក់ដែលមានបញ្ញត្តក្នុងច្បាប់ ។ ការកំណត់អំពីទម្រង់បែបនេះ គឺដើម្បីធានាដំណើរការនៃការជំនុំជម្រះឱ្យមានសុក្រឹត្យភាព និងតម្លាភាព រវាងភាគីវិវាទ និងដើម្បីទទួលបាននូវលទ្ធផលនៃសម្រេចសេចក្ដីមួយដ៏យុត្តិធម៌ ប្រកបដោយសុគតិគមនំ សម្រាប់ជនដែលត្រូវបានបំពានសិទ្ធិ និងផលប្រយោជន៍ ។ ដូច្នេះ ការកែប្រែសេចក្ដីសម្រេចរបស់ តុលាការ គឺជារឿងមួយដែលមិនសមនឹងធ្វើឡើងនោះឡើយ ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើក្នុងចំណាត់ការរបស់តុលាការមានហេតុណាមួយកើតឡើងដែលមានវិការៈធ្ងន់ធ្ងរ ច្បាប់ក៏នៅតែអនុញ្ញាតឱ្យភាគីធ្វើការតវ៉ាតាមផ្លូវតុលាការទៀតបាន តាមរយៈនីតិវិធីនៃបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និងនីតិវិធីបណ្ដឹងឧបាស្រ័យពិសេស ឬ អាចហៅម៉្យាងទៀតថា នីតិវិធីនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលជាប្រធានបទនៃសារណានេះ ។

សរុបសេចក្ដីមក នីតិវិធីនៃការជំនុំជម្រះសាជាថ្មី គឺជានីតិវិធីដែលមានភាពស្មុគស្មាញជាខ្លាំង ដោយទាមទារឱ្យមានការឆ្លងកាត់នូវដំណាក់កាលនៃនីតិវិធីបន្តបន្ទាប់គ្នា ចាប់តាំងពីដំណាក់កាលនៃពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលមានពាក់ព័ន្ធនឹងប្រធាននៃបណ្ដឹង កម្មវត្ថុនៃបណ្ដឹង មូលហេតុនៃការជំនុំជម្រះសាជាថ្មី ការសរសេរពាក្យបណ្ដឹង និងការដាក់ពាក្យបណ្ដឹង រហូតដល់ដំណាក់កាលនៃការជំនុំជម្រះសាជាថ្មី ដែលរួមមានការជំនុំជម្រះលើភាពត្រឹមត្រូវនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និងការជំនុំជម្រះលើអង្គសេចក្ដីសាជាថ្មី ។ ភាពស្មុគស្មាញនៃនីតិវិធីនៃការជំនុំជម្រះសាជាថ្មី អាចឱ្យអ្នកសិក្សា ក៏ដូចជា អ្នកអនុវត្តច្បាប់យល់ពីតម្លៃដ៏សំខាន់នៃពាក្យបណ្ដឹង និងការដោះស្រាយវិវាទតាមផ្លូវតុលាការ ដែលជាកាតាលីករជម្រុញឱ្យមានការផ្ដល់តម្លៃដល់នីតិវិធីនៃការជំនុំជម្រះសាជាថ្មី ក៏ដូចជានីតិវិធីនៃបណ្ដឹងរដ្ឋប្បវេណីផ្សេងទៀត និងជម្រុញឱ្យការអនុវត្តកាន់តែមានប្រសិទ្ធភាពថែមមួយកម្រិតទៀត ។

# អនុសាសន៍

យោងតាមការសិក្សាស្រាវជ្រាវលើប្រធានបទ "**ការជំនុំជម្រះសាជាថ្មី**" យើងខ្ញុំសង្កេតឃើញថា ប្រធានបទនេះ ពិតជាមានសារៈសំខាន់ជាខ្លាំង ដែលនាំឱ្យយើងខ្ញុំជឿជាក់ថា អ្នកវិជ្ជាជីវៈ អ្នកអនុវត្តច្បាប់ និងបុគ្គលមកពីគ្រប់មជ្ឈដ្ឋានទូទៅ ប្រាកដជាចង់ដឹង ចង់យល់ ចង់ចេះ អំពីប្រធានបទដ៏មានអត្ថប្រយោជន៍មួយនេះ ។

ជាការពិតណាស់ ការអភិវឌ្ឍវិស័យគតិយុត្តនៅប្រទេសកម្ពុជា ត្រូវបានទទួលជំនួយពីប្រទេសបារាំង និងប្រទេសជប៉ុន លើការបកប្រែ ក៏ដូចជាការចងក្រងលិខិតបទដ្ឋានគតិយុត្តឡើង ។ ជាក់ស្តែង លិខិតបទដ្ឋានគតិយុត្តនានាដែលទាក់ទងទៅនឹងការអនុវត្តច្បាប់ឯកជន ដែលរួមមានៈ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ជាអាទិ៍ ភាគច្រើនត្រូវបានយកលំនាំពីច្បាប់របស់បរទេស ហេតុដូចនេះហើយ ខ្លឹមសារច្បាប់សំខាន់មួយចំនួនមានលក្ខណៈពិបាកយល់ ដែលបង្កការលំបាកដល់អ្នកសិក្សាស្រាវជ្រាវ ជាពិសេសនិស្សិត ក្នុងការស្វែងយល់ឱ្យបានច្បាស់ពីខ្លឹមសារនៃមាត្រានីមួយៗ ក៏ដូចជាក្នុងការស្រាវជ្រាវ ដើម្បីចងក្រងមេរៀន ជាដើម ។ ដោយហេតុនេះហើយ យើងខ្ញុំសូមផ្តល់អនុសាសន៍បន្តិចបន្តួច ក្នុងន័យកែលម្អ និងស្ថាបនា ដើម្បីចូលរួមជួយជាប្រយោជន៍ដល់ការអភិវឌ្ឍប្រព័ន្ធច្បាប់នៃប្រទេសកម្ពុជា ។

ក្រសួងយុត្តិធម៌ និងស្ថាប័នដែលពាក់ព័ន្ធ គប្បីសហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីបង្កើតកម្មវិធីពន្យល់ច្បាប់ឱ្យមានភាពទូលំទូលាយ ទាំងផ្នែកទ្រឹស្តី ទាំងការអនុវត្ត ។ បន្ថែមពីនេះទៀត ក្រសួងយុត្តិធម៌ គប្បីធ្វើសិក្ខាសាលាឱ្យបានញឹកញាប់តាមដែលអាចធ្វើទៅបាន ដើម្បីបំផុសស្មារតីដល់អ្នកវិជ្ជាជីវៈទាំងឡាយ យល់ឱ្យបានប្រត្យក្ស និងអនុវត្តប្រកបដោយសង្គតិភាព អំពីនីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណី ជាពិសេសគឺពាក់ព័ន្ធនឹងនីតិវិធីដែលមានលក្ខណៈស្មុគស្មាញដូចជា នីតិវិធីនៃការជំនុំជម្រះសាជាថ្មីនេះ ជាដើម ។ ពិសេសជាងនេះទៅទៀត ទោះបីជាក្រសួងយុត្តិធម៌បានធ្វើការផ្សព្វផ្សាយរយៈពេលមួយឆ្នាំមុននឹងក្រមនីតិវិធីរដ្ឋប្បវេណីនេះ ត្រូវបានដាក់ឱ្យអនុវត្តក៏ដោយ ក៏ក្រសួងយុត្តិធម៌ ក៏ដូចជាស្ថាប័នពាក់ព័ន្ធ គប្បីយកចិត្តទុកដាក់បន្ថែម តាមរយៈការលើកទឹកចិត្តដល់បុគ្គលដែលមានសមត្ថភាព និងសណ្តានចិត្តក្នុងការចែករំលែកចំណេះដឹងផ្នែករដ្ឋប្បវេណី និងតាមរយៈការផ្សព្វផ្សាយច្បាប់ឱ្យកាន់តែមានភាពទូលំទូលាយ ដើម្បីឱ្យអ្នកវិជ្ជាជីវៈ ដែលជាអ្នកអនុវត្តច្បាប់ដោយផ្ទាល់ គោរពតាម និងអនុវត្តស្របគ្នា ដែលញ៉ាំងឱ្យពួកគាត់អាចផ្តល់សេចក្តីសម្រេចជូនដល់ប្រជាពលរដ្ឋ ដោយសុគតិគមនំ គឺសុចរិត និងយុត្តិធម៌ ដែលចាកឆ្ងាយផុតពីឆន្ទាគតិ ទោសាគតិ ភយាគតិ និងមោហាគតិ ដែលជាអគតិធម៌ទាំងបួន ទើបធ្វើឱ្យសង្គមកម្ពុជាទទួលបានភាពរីកចម្រើនលូតលាស់រហូតក្លាយទៅជានីតិរដ្ឋ ៕

# ឯកសារយោង

❖ **លិខិតបទដ្ឋានគតិយុត្ត**


- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ។
- ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ។
- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ។
- ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។
- ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ។
- ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០ ។


❖ **សៀវភៅ**


- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និង គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី. ២០០៧. សេចក្តីកំណត់ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី. ភ្នំពេញៈ ក្រសួងយុត្តិធម៌ ។
- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី. ២០០៨. នីតិវិធីបណ្តឹង. ភាគ១ នៃសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី. ភ្នំពេញៈ ក្រសួងយុត្តិធម៌ ។
- គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការ, ក្រសួងយុត្តិធម៌, រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និង សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច. ២០១៧. មេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ៣. ភ្នំពេញៈ គម្រោងអភិវឌ្ឍប្រព័ន្ធច្បាប់ និងតុលាការដំណាក់កាលទី៤ របស់

ក្រសួងយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន ។

– សាស្ត្រាចារ្យ កេត សុជាតិ. ២០១៥. សៀវភៅមេរៀននីតិវិធីរដ្ឋប្បវេណីសម្រាប់និស្សិតនីតិសាស្ត្រ . ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។
– សាស្ត្រាចារ្យ ហ៊ី សោភា. គ្មានកាលបរិច្ឆេទ. នីតិវិធីរដ្ឋប្បវេណី. ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។
– មេធាវី អ៊ុំ ប៉ូលី. ២០១០. មេរៀនសង្ខេបស្តីពីនីតិវិធីរដ្ឋប្បវេណី. ភ្នំពេញ៖ សាកលវិទ្យាល័យបញ្ញាសាស្ត្រ ។
– បណ្ឌិត ហាប់ ផល្លី. ២០១៦. វិធីសាស្ត្រ និងការសរសេរបែបសិក្សា. ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

- **ឯកសារធ្វើបទបង្ហាញ**

– Kazuyuki, Higashio., Ryo, Yukawa. និង Jun, Uchiyama. ២០១៨. ការជំនុំជម្រះសាជាថ្មី. បទបង្ហាញនៅក្នុងសិក្ខាសាលាស្តីពីបញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី, សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ, ១៧ មករា ។

# បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធ១** ៖ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយតតិយជន

**ឧបសម្ព័ន្ធ២** ៖ ដីកាសម្រេចច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី

**ឧបសម្ព័ន្ធ៣** ៖ នីតិវិធីមុនចេញដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី

**ឧបសម្ព័ន្ធ៤** ៖ ដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី

**ឧបសម្ព័ន្ធ៥** ៖ សាលក្រមច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី

# ឧបសម្ព័ន្ធ១

## បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយគតិយុត្តជន

- ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី
- សាលក្រមដែលជាកម្មវត្ថុនៃការទាមទារឱ្យជំនុំជម្រះសាជាថ្មី
- បង្កាន់ដៃបង់ពន្ធដាក់ពាក្យសុំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
ថ្ងៃទី......ខែ.....ឆ្នាំ

# ពាក្យបណ្ដឹងទាមទារឲ្យជំនុំជំរះសាជាថ្មី

**ដើមចោទ:** ជាធនាគារដែលចុះបញ្ជីស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា តំណាងដោយលោក ជាអគ្គនាយកនៃធនាគារ មានទីស្នាក់ការអាគារលេខ ផ្លូវ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**ចុងចម្លើយ:** ១. ក្រុមហ៊ុន មានទីស្នាក់ការ ផ្ទះលេខ វិថី សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

២. ឈ្មោះ អាយុ ឆ្នាំ សញ្ជាតិ អាសយដ្ឋានផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

សាលាដំបូងរាជធានីភ្នំពេញ
ចប់ពាក្យ
ថ្ងៃទី......ខែ.....ឆ្នាំ

ថ្ងៃ.......... ..........
.....ខែ. .....ឆ្នាំ

## សូមគោរពចូលមក
## ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ

**សូមទានជ្រាប។**

**កម្មវត្ថុ:** សំណើសុំឲ្យតុលាការសម្រេចដូចខាងក្រោម:

១-ជំនុំជំរះសាជាថ្មីចំពោះសាលក្រមលេខ ភ.ព.រ.វ ចុះថ្ងៃទី២០-១០- របស់សាលាដំបូងរាជធានីភ្នំពេញលើសេចក្ដីសម្រេចទាំងមូល។

២-ច្រានចោលពាក្យបណ្ដឹងចុះថ្ងៃទី ខែ ឆ្នាំ របស់ក្រុមហ៊ុន )។

៣-បង្គាប់ឲ្យចុងចម្លើយ សងការខូចខាត រួមមានជម្ងឺចិត្ត ការខាតបង់ផ្សេងៗ និងសេវាមេធាវី ចំនួន ឲ្យមកដើមចោទ។

៤-ឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្ដី។

**យោង:** -មាត្រា៣១៨ និងមាត្រាផ្សេងៗទៀត នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សាលក្រមលេខ ភ.ព.រ.វ ចុះថ្ងៃទី២០-១០- របស់សាលាដំបូងរាជធានីភ្នំពេញ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូនឯកឧត្តមប្រធានមេត្តាជ្រាបថា:

**អង្គហេតុជាមូលហេតុនៃការជំនុំជំរះសាជាថ្មី:**

កាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ លោក បានខ្ចីប្រាក់ធនាគារខ្ញុំបាទ នូវទឹកប្រាក់ចំនួន ដុល្លាអាមេរិក) ដោយគិតការប្រាក់ ៧.៥%(ប្រាំពីរក្បៀសប្រាំភាគរយ)ប្រចាំឆ្នាំថេរ តាមកិច្ចព្រមព្រៀងខ្ចីចងការ និងកិច្ចសន្យាដាក់បញ្ចាំ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ ដោយបានដាក់បញ្ចាំនូវបន្ទប់ខុនដូរលេខ ស្ថិតនៅផ្ទះលេខ ផ្លូវលេខ និងផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ដើម្បីធានាសងបំណុលឲ្យធនាគារខ្ញុំបាទ។

បន្ទាប់មកនៅថ្ងៃទី០៦ ខែសីហា ឆ្នាំ លោក បានខ្ចីប្រាក់ពីធនាគារខ្ញុំបាទ បន្ថែមទៀតនូវទឹកប្រាក់ចំនួន ដុល្លាអាមេរិក) ដោយគិតការប្រាក់ ៨%(ប្រាំបីភាគរយ)ប្រចាំឆ្នាំថេរ តាមកិច្ចព្រមព្រៀងខ្ចីចងការ និងកិច្ចសន្យាដាក់បញ្ចាំ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ ដោយបានដាក់បញ្ចាំបន្ថែមទៀតនូវបន្ទប់ខុនដូរលេខ ស្ថិតនៅផ្ទះលេខ ផ្លូវលេខ និងផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ដើម្បីសងបំណុលឲ្យធនាគារខ្ញុំបាទ។

ក្រោយពីបានខ្ចីប្រាក់ខាងលើរួច ចាប់តាំងពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ មក លោក ក៏ពុំបានបង់ការប្រាក់ដូចកំណត់ក្នុងកិច្ចសន្យាខ្ចីចងការប្រាក់ទេ ទោះជាធនាគារខ្ញុំបាទព្យាយាមដាស់តឿនឲ្យអនុវត្តកាតព្វកិច្ចយ៉ាងណាក៏ដោយ ក៏លោកមិនបានអើពើទេ ហើយបានគេចខ្លួនបាត់តែម្តង។ លុះដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ ធនាគារខ្ញុំបាទក៏បានដាក់ពាក្យបណ្តឹងទាមទារប្រាក់កម្ចីខាងលើទាំងអស់ពីលោក វិញ ទៅសាលាដំបូងរាជធានីភ្នំពេញ។

លុះដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ទើបសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចចេញសាលក្រមលេខ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ដោយបង្គាប់ឲ្យលោក សងប្រាក់កម្ចីទាំងអស់ដល់ធនាគារខ្ញុំបាទវិញ។

ក្នុងនោះដែរ ក្រុមហ៊ុន ក៏បានដឹងថា លោក បានខ្ចីប្រាក់ធនាគារខ្ញុំបាទ ដោយយកបន្ទប់ខុនដូរទាំង១០ ខាងលើទៅដាក់បញ្ចាំឲ្យធនាគារខ្ញុំបាទ ដោយក្រុមហ៊ុនបានទាក់ទងជាមួយធនាគារខ្ញុំបាទតាំងពីខែតុលា ឆ្នាំ មកម្ល៉េះ ហើយនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ធនាគារខ្ញុំបាទចេញលិខិតមួយច្បាប់ជូនទៅលោក ប្រធានក្រុមហ៊ុន ដោយបញ្ជាក់អំពីបំណុលរបស់លោក និងការដាក់បញ្ចាំបន្ទប់ខុនដូរទាំង១០ខាងលើដើម្បីធានាបំណុលខាងលើ ។

ខ្ញុំបាទសូមបញ្ជាក់ថា លោក បានខ្ចីប្រាក់ពីធនាគារខ្ញុំបាទចំនួន ០៣ លើករួចមកហើយ ដោយយកបន្ទប់ទាំង១០ខាងលើដាក់បញ្ចាំឲ្យធនាគារខ្ញុំបាទ និងបានទូទាត់សងប្រាក់ធនាគារខ្ញុំបាទវិញដែរគឺ

លើកទី១. ខ្ចីប្រាក់នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ រយៈពេល ១ ឆ្នាំ ចំនួន សងវិញនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ ។

លើកទី២. ខ្ចីប្រាក់នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ រយៈពេល ១ ឆ្នាំ ចំនួន សងវិញនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ។

លើកទី៣. ខ្ចីប្រាក់នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ រយៈពេល ១ ឆ្នាំ ចំនួន សងវិញបង្គ្រប់នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ ។

បន្ទាប់ពីសាលក្រមលេខ ភ.ព.រ.រ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញខាងលើបានចូលជាស្ថាពរ។ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ ធនាគារខ្ញុំបាទបានដាក់ពាក្យសុំអនុវត្តដោយបង្ខំលើសាលក្រមស្ថាពរខាងលើ ទៅលើទ្រព្យដាក់បញ្ចាំរបស់លោក ។

ក្នុងនោះតុលាការអនុវត្តនៃសាលាដំបូងរាជធានីភ្នំពេញ បានចេញដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំលេខ ភ.ព.អ.នុ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ និងបានបញ្ជូនដល់ទៅអាសយដ្ឋានរបស់លោក ស្ថិតនៅផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ក្នុងនោះបុគ្គលិករបស់ក្រុមហ៊ុនបានទទួលជំនួសផងដែរ តែមិនឃើញក្រុមហ៊ុនប្រតិកម្ម ឬជូនដំណឹងអំពីសេចក្តីតវ៉ារបស់គេឡើយ។

លុះដល់តុលាការចុះទៅពិនិត្យស្ថានភាពបច្ចុប្បន្ននៃបន្ទប់ខុនដូរទាំង ១០ របស់លោក ទើបក្រុមហ៊ុនអះអាងថា កិច្ចសន្យាទិញលក់របស់លោក និងក្រុមហ៊ុន ដែលលោក បានយកទៅដាក់បញ្ចាំឲ្យធនាគារខ្ញុំបាទ ត្រូវបានតុលាការសម្រេចរំលាយចោលហើយតាមសាលក្រមលេខ ភ.ព.រ.រ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ ឯសាលក្រមនេះបានចូលស្ថាពរហើយ ដែលធ្វើឲ្យធនាគារខ្ញុំបាទមានការភ្ញាក់ផ្អើលជាខ្លាំង ព្រោះធនាគារខ្ញុំបាទមិនដែលបានទទួលដំណឹងអំពីការនីតិវិធីនៃសំណុំរឿងនេះទេ ដោយហេតុថាក្រុមហ៊ុនបានដឹងថា បន្ទប់ខុនដូរទាំង១០ ខាងលើបានដាក់បញ្ចាំនៅធនាគារខ្ញុំបាទ នោះធនាគារខ្ញុំបាទមានផលប្រយោជន៍ក្នុងសំណុំរឿងនេះដែរ ហើយការសម្រេចសេចក្តីក្នុងសំណុំរឿងនេះ គឺប៉ះពាល់ផលប្រយោជន៍យ៉ាងខ្លាំងរបស់ធនាគារខ្ញុំបាទ ដោយសារសាលក្រមនេះបានធ្វើឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិ ដែលបានដាក់បញ្ចាំនៅនឹងធនាគារខ្ញុំបាទ។ ហេតុនេះ ក្នុងនីតិវិធីនៃបណ្តឹងរបស់ក្រុមហ៊ុន ត្រូវជូនដំណឹងទៅតុលាការ អំពីផលប្រយោជន៍របស់ធនាគារខ្ញុំបាទ ដើម្បីឲ្យធនាគារខ្ញុំបាទបានចូលរួមការពារផលប្រយោជន៍របស់ខ្លួនផងដែរ តាមមាត្រា ៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ក្រោយពីទទួលដំណឹងខាងលើភ្លាម ធនាគារខ្ញុំបាទបានប្រគល់ឲ្យមេធាវី ដើម្បីស្នើសុំថតចម្លងឯកសារនៃសំណុំរឿងរបស់ក្រុមហ៊ុនខាងលើមកសិក្សា ហើយឃើញថា សិទ្ធិជាមូលដ្ឋាន និងគោលការណ៍ចំពោះមុខ ដែលត្រូវធានាដោយតុលាការមិនត្រូវបានអនុវត្តដោយត្រឹមត្រូវតាមក្រមនីតិវិធីរដ្ឋប្បវេណីទេ ហើយតុលាការក៏ពុំបានសម្រេចសេចក្តីដោយត្រឹមត្រូវ និងផ្អែកលើភស្តុតាងទេ គួយ៉ាងឃើញថាៈ

ក. អំពីដំណើរការនីតិវិធីរបស់តុលាការ:

១. ចុងចម្លើយលោក នៃសំណុំរឿងរបស់ក្រុមហ៊ុន តុលាការមិនបានជូនដំណឹងឲ្យបានត្រឹមត្រូវ ដើម្បីធានាថា ចុងចម្លើយអាចបានទទួលដំណឹងអំពីសំណុំរឿងនេះទេ។

២. តុលាការគឺមិនអាចចេញសាលក្រមកំបាំងមុខបានឡើយ ប្រសិនបើខ្លឹមសារនៃសេចក្ដីថ្លែងការណ៍ ដែលដើមចោទបានធ្វើនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលចុងចម្លើយមិនបានបង្ហាញខ្លួន ហើយខ្លឹមសារនៃសេចក្ដីថ្លែងការណ៍នោះមិនបានជូនដំណឹងទៅចុងចម្លើយមុនកាលបរិច្ឆេទនោះ តាមមាត្រា ២០២ នៃក្រមនីតិវិធីរដ្ឋប្បវេណី តែតុលាការបែរជាចេញសាលក្រមទៀត។

៣. ចុងក្រោយ តុលាការមិនបានធានាសិទ្ធិប្ដឹងតវ៉ា(ប្ដឹងទាស់) ស្របតាមមាត្រា ២០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីទេ ដោយមិនបានបើកផ្លូវប្ដឹងទាស់លើសាលក្រមខាងលើទេ ព្រោះសាលក្រមនេះបានចេញដោយកំបាំងមុខចុងចម្លើយ ដោយសារចុងចម្លើយអវត្តមាន តែបែរជាបើកផ្លូវឲ្យគូភាគីប្ដឹងឧទ្ធរណ៍តែម្ដង។

ខ. អំពីខ្លឹមសារនៃសេចក្ដីសម្រេចរបស់តុលាការ:

តុលាការសម្រេចសេចក្ដីដោយរំលាយកិច្ចសន្យាទិញលក់ខាងលើ គឺផ្អែកលើការអះអាងរបស់ដើមចោទទាំងស្រុង តែមិនបានផ្អែកលើភស្ដុតាងទេ ដែលជាហេតុធ្វើឲ្យមូលហេតុនៃសេចក្ដីសម្រេចរបស់តុលាការគឺមិនសមហេតុផល និងអាចទទួលយកបានទេ តួយ៉ាងដូចជា:

១. តើអ្វីជាការផ្ដល់កិច្ចសន្យាទិញលក់ពិសេសដល់អតិថិជនរបស់គេ? តើការផ្ដល់កិច្ចសន្យាទិញលក់ពិសេសមានអ្វីប៉ះពាល់ដល់ការរំលាយកិច្ចសន្យានេះ។

២. តើកិច្ចសន្យាដែលមិនបានចុះហត្ថលេខាដោយអាជ្ញាធរមូលដ្ឋាន ជាមូលហេតុនៃការរំលាយកិច្ចសន្យានេះដែរឬទេ?

ខ្ញុំបាទមានភស្ដុតាងបញ្ជាក់ថា កិច្ចសន្យាទិញលក់របស់ក្រុមហ៊ុនភាគច្រើន មិនដែលមានចុះហត្ថលេខាដោយអាជ្ញាធរមូលដ្ឋានទេ ក៏នៅតែមានប្រសិទ្ធិភាពអនុវត្ត ហើយក្រុមហ៊ុនបានកាត់ផ្ទេរប្លង់កម្មសិទ្ធិ ឬប្លង់រឹងឲ្យអ្នកទិញដែរ។

ម្យ៉ាងវិញទៀត កាតព្វកិច្ចយកកិច្ចសន្យាទិញលក់ទៅឲ្យអាជ្ញាធរមូលដ្ឋានចុះហត្ថលេខាជាកាតព្វកិច្ចរបស់ក្រុមហ៊ុនទេ បើក្រុមហ៊ុនមិនយកកិច្ចសន្យានេះទៅឲ្យអាជ្ញាធរមូលដ្ឋាន ហើយផ្ដល់កិច្ចសន្យាទិញលក់ដល់អថិតិជន នោះបញ្ជាក់ថាជាកំហុសរបស់ក្រុមហ៊ុនទេ។

មួយវិញទៀត ដោយសារការចុះហត្ថលេខាដោយអាជ្ញាធរមូលដ្ឋានលើកិច្ចសន្យាទិញលក់មិនត្រូវបានអនុវត្ត ទើបកិច្ចសន្យាទិញលក់ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ក៏លែងទាមទារឲ្យមានការចុះហត្ថលេខា ដោយចៅសង្កាត់ទៀតហើយ។

៣. តើកិច្ចសន្យាដែលមិនបានចុះជាភាសាខ្មែរ និងជាភាសាអង់គ្លេស គឺមិនមានសុពលភាពឬ? តើកិច្ចសន្យាដែលចុះតែភាសាអង់គ្លេសមិនអាចអនុវត្តបានមែនទេ?

តាមប្រការ នៃកិច្ចសន្យាទិញលក់ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ បានចែងថា ...សំណៅភាសាអង់គ្លេស និងខ្មែរ នៃកិច្ចព្រមព្រៀងនេះមានតម្លៃស្មើគ្នាចំពោះមុខច្បាប់។

តាមប្រការ នៃកិច្ចសន្យាទិញលក់ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ បានចែងថា កិច្ចព្រមព្រៀងនេះ បកប្រែជាសំណៅភាសាខ្មែរ។ ទោះបីជាយ៉ាងណា សំណៅជាភាសាអង់គ្លេសត្រូវយកជាសំណៅគោល។

ផ្អែកតាមកិច្ចសន្យាខាងលើឃើញថា ការធ្វើកិច្ចសន្យាទិញលក់ជាភាសាអង់គ្លេស ក៏នៅតែមានសុពលភាពដែរ។ ម្យ៉ាងវិញទៀត ខ្ញុំបាទជឿថាកិច្ចសន្យាទិញលក់ជាមួយលោក នេះមិនអាចធ្វើជាភាសាខ្មែរ ដោយសារអ្នកទិញជាជនបរទេស ហើយមិនយល់ពីខ្លឹមសារនៃកិច្ចសន្យាជាភាសាខ្មែរដែរ។ ហើយការរៀបចំកិច្ចសន្យាទិញលក់គឺត្រូវរៀបចំដោយក្រុមហ៊ុន ហេតុនេះ តើការមិនធ្វើជាភាសាខ្មែរជាកំហុសរបស់អ្នកណា?

៩. ដើមចោទ (ភាគី ក្រុមហ៊ុន) ពុំរកឃើញថាមានលិខិតប្រគល់ទទួលប្រាក់ពីការទិញលក់របស់ចុងចម្លើយ។ តើត្រូវការលិខិតប្រគល់ទទួលប្រាក់ដែរឬទេ? ប្រសិនបើកិច្ចសន្យាទិញលក់ទាំង១០ បន្ទប់ខាងលើ ក្រុមហ៊ុនបានបញ្ជាក់ច្បាស់ថា បានបង់ប្រាក់គ្រប់ចំនួន ១០០% ហើយនោះ និងមានប្រថាប់ត្រាក្រុមហ៊ុនទៀតផង។ ហេតុនេះទើបគ្មានហេតុផលត្រូវបង់ប្រាក់តាមដំណាក់កាលណាមួយទៀតទេ ហើយក្នុងកិច្ចសន្យាក៏មិនបានកំណត់ពីដំណាក់កាលបង់ប្រាក់ដែរ។

<u>សរុបសេចក្តីមក</u> ហេតុផលនៃការរំលាយកិច្ចសន្យាទិញលក់ខាងលើ ថា គ្មានសុពលភាពរបស់ តុលាការ គឺមិនសមស្របទេ។

ខ្ញុំបាទសូមបញ្ជាក់ជូនឯកឧត្តមបន្ថែមទៀតថា:

ដំបូងឡើយ លោក បានទិញបន្ទប់របស់ក្រុមហ៊ុនតែប្រាំបន្ទប់តែប៉ុណ្ណោះ គឺបន្ទប់លេខ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ ដោយបញ្ជាក់ថាបានបង់ប្រាក់គ្រប់ចំនួន ១០០%។ ប្រសិនបើលោក មិនបានបង់ប្រាក់ថ្លៃទិញបន្ទប់ ហេតុអ្វីបានជាជាង ១ ឆ្នាំក្រោយទៀត នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ ក្រុមហ៊ុននៅបន្តលក់បន្ទប់ប្រាំ ទៀតឲ្យទៅលោក គឺបន្ទប់លេខ ដោយបញ្ជាក់ថាបង់ប្រាក់គ្រប់ចំនួនទៀត? ជាងនេះទៅទៀត រហូតដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ និងបន្ទាប់ពីលោក គេចខ្លួនបាត់ ទើបក្រុមហ៊ុនចាប់ផ្តើមប្តឹងរំលាយកិច្ចសន្យាទិញលក់ខាងលើ តើក្រុមហ៊ុនខ្លាចលោក ចេញមុខបកអាក្រាតរឿងពិត ឬបកអាក្រាតលើការអះអាងរបស់ក្រុមហ៊ុនទៅតុលាការខាងលើជារឿងពុំពិត ព្រោះការអះអាងនេះហាក់ដូចជាមិនសមហេតុផលសោះ?

ជាងនេះទៅទៀត ប្រសិនបើលោក មិនបានបង់ប្រាក់គ្រប់ចំនួន ហេតុអ្វីបានជាក្រុមហ៊ុនបញ្ជាក់យ៉ាងច្បាស់ក្នុងកិច្ចសន្យាទិញលក់ថា លោក បានបង់ប្រាក់គ្រប់ចំនួនហើយ។ ហើយប្រគល់កិច្ចសន្យានេះចប់ដើមឲ្យលោក ប្រើប្រាស់។

ប្រសិនបើក្រុមហ៊ុនមិនបានបញ្ជាក់ច្បាស់ថា អ្នកទិញ(លោក
បានបង់ប្រាក់គ្រប់ចំនួនទេ និងក្រុមហ៊ុនមិនបានផ្តល់កិច្ចសន្យាទិញលក់ច្បាប់ដើម ដល់លោក
ទេ ក៏ធនាគារខ្ញុំបាទមិនផ្តល់ប្រាក់កម្ចីដែរ។

ម្យ៉ាងវិញទៀត ប្រសិនដូចសេចក្តីអះអាងរបស់ក្រុមហ៊ុនថាលោក
ជាអតិថិជនពិសេស ទើបផ្តល់នូវទំរង់នៃកិច្ចសន្យាទិញលក់ពិសេសខាងលើដល់លោក
នោះមានន័យថា ក្រុមហ៊ុនគឺបានសមគំនិត ឬបានជួយសម្រួលដល់
លោក រួចទៅហើយ ដើម្បីយកកិច្ចសន្យាទិញលក់ខាងលើទៅប្រើ
ប្រាស់ ទោះបីជាលោក មិនទាន់បានបង់ប្រាក់ដល់ក្រុមហ៊ុនក៏ដោយ
ដោយសារលោក ជាអតិថិជនពិសេស ហេតុនេះ ក្រុមហ៊ុននៅតែត្រូវ
ទទួលខុសត្រូវចំពោះការខូចខាតរបស់ធនាគារខ្ញុំបាទដែរ ដោយសារការសមគំនិត ឬការសម្រួល
របស់ក្រុមហ៊ុនខាងលើ។

**<u>អង្គហេតុចាំបាច់បញ្ជាក់ការទាមទារៈ</u>**

១-កិច្ចសន្យាទិញលក់បន្ទប់ខុនដូរលេខ
ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ ជាភាសាអង់គ្លេស និងឯកសារ
បកប្រែជាភាសាខ្មែរ (ថតចំលង) ចំនួន ០១ច្បាប់។

២-កិច្ចសន្យាទិញលក់បន្ទប់ខុនដូរលេខ
ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ជាភាសាអង់គ្លេស និងឯកសារបក
ប្រែជាភាសាខ្មែរ (ថតចំលង) ចំនួន ០១ច្បាប់។

៣-កិច្ចព្រមព្រៀងខ្ចីចងការប្រាក់ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ និងកិច្ចសន្យាដាក់
បញ្ចាំ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ ដោយដាក់បញ្ចាំបន្ទប់ខុនដូរលេខ
ជាភាសាអង់គ្លេស និងខ្មែរ (ថតចំ
លង) ចំនួន ០១ច្បាប់។

៤-កិច្ចព្រមព្រៀងខ្ចីចងការប្រាក់ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ និងកិច្ចសន្យាដាក់
បញ្ចាំ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ ដោយដាក់បញ្ចាំបន្ទប់ខុនដូរលេខ
ជាភាសាអង់គ្លេស និងខ្មែរ
(ថតចំលង) ចំនួន ០១ច្បាប់។

៥-កិច្ចព្រមព្រៀងខ្ចីចងការប្រាក់ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ និងកិច្ចសន្យា
ដាក់បញ្ចាំ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ ដោយដាក់បញ្ចាំបន្ទប់ខុនដូរលេខ
ជាភាសាអង់គ្លេស និងខ្មែរ
(ថតចំលង) ចំនួន ០១ច្បាប់។

៦-កិច្ចព្រមព្រៀងខ្ចីចងការប្រាក់ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ និងកិច្ចសន្យាដាក់បញ្ចាំ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ ដោយដាក់បញ្ចាំបន្ទប់ខុនដូរលេខ ជាភាសាអង់គ្លេស និងខ្មែរ (ថតចំលង) ចំនួន ០១ច្បាប់។

៧-កិច្ចព្រមព្រៀងខ្ចីចងការប្រាក់ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ និងកិច្ចសន្យាដាក់បញ្ចាំ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ ដោយដាក់បញ្ចាំបន្ទប់ខុនដូរលេខ ជាភាសាអង់គ្លេស និងខ្មែរ (ថតចំលង) ចំនួន ០១ច្បាប់។

៨-ពាក្យបណ្តឹងរបស់ធនាគារ ចុះថ្ងៃទី៣១-០៣- (ថតចំលង) ចំនួន ០១ច្បាប់។

៩-សាលក្រមលេខ ភ.ព.រ.វ ចុះថ្ងៃទី៣០-០៧- របស់សាលាដំបូងរាជធានីភ្នំពេញ (ថតចំលង) ចំនួន ០១ច្បាប់។

១០-លិខិតបញ្ជាក់ការចូលស្ថាពរនៃសាលក្រមលេខ រ.វ.ស្ថា និងរបមន្តអនុវត្តសាលក្រមលេខ រ.វ.រូ ចុះថ្ងៃទី១២-០៣- (ថតចំលង) ចំនួន ០២សន្លឹក។

១១-លិខិតជូនដំណឹងចុះថ្ងៃទី២២ ខែតុលា ឆ្នាំ របស់មេធាវីក្រុមហ៊ុន ចំនួន ០១ច្បាប់។

១២-លិខិតឆ្លើយយតប ចុះថ្ងៃទី១៥-០២- របស់សាជីវកម្មធនាគារ (ថតចំលង) ចំនួន ០១ច្បាប់។

១៣-ពាក្យបណ្តឹង របស់ក្រុមហ៊ុន ចុះថ្ងៃទី ២២-០៨- របស់សាលាដំបូងរាជធានីភ្នំពេញ (ថតចំលង) ចំនួន ០១ច្បាប់។

១៤-សាលក្រមលេខ ភ.ព.រ.វ ចុះថ្ងៃទី២០-១០ និងលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមលេខ រ.វ.ស្ថា ចុះថ្ងៃទី១៦-០២- (ថតចំលង) ចំនួន ០១ច្បាប់។

១៥-ដីកាបញ្ជូនលេខ ដ.ប ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

១៦-របាយការណ៍អំពីការបញ្ជូន ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ (ថតចំលង) ចំនួន ០១ច្បាប់។

**<u>សំណូមពរ:</u>**

សុំឲ្យតុលាការជួយរកយុត្តិធម៌ឲ្យធនាគារខ្ញុំបាទដោយ:

១-ជំនុំជំរះសាជាថ្មីចំពោះសាលក្រមលេខ ភ.ព.រ.វ ចុះថ្ងៃទី២០-១០- របស់សាលាដំបូងរាជធានីភ្នំពេញលើសេចក្តីសម្រេចទាំងមូល។

២-ច្រានចោលពាក្យបណ្តឹងចុះថ្ងៃទី២២ ខែសីហា ឆ្នាំ របស់ក្រុមហ៊ុន

។

៣-បង្គាប់ឲ្យចុងចម្លើយសងការខូចខាត រួមមានជម្ងឺចិត្ត ការខាតបង់ផ្សេងៗ និងសេវាមេធាវី ចំនួន ដុល្លាអាមេរិក) ឲ្យមកដើមចោទ។

៤-ឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាទទួលនូវពាក្យបណ្តឹងរបស់ខ្ញុំបាទដោយក្តីអនុគ្រោះ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ភ្នំពេញ, ថ្ងៃទី... ...ខែ... ... ឆ្នាំ

សាជីវកម្មធនាគារ:

អគ្គនាយក

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

រឿងក្ដីលេខ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ
សញ្ញាណរឿងក្ដី ប្ដឹងសុំរំលាយកិច្ចសន្យាទិញ-លក់អគារខុនដូ
បញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ថ្ងៃទី២០ ខែតុលា ឆ្នាំ
សាលក្រមលេខ **ត.ព.រ.ខ**
ថ្ងៃប្រកាសសាលក្រម ថ្ងៃទី២០ ខែតុលា ឆ្នាំ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ
## ចេញសាលក្រមដែលមានខ្លឹមសារដូចតទៅ

ដើមចោទឈ្មោះ **ក្រុមហ៊ុន** មានអាសយដ្ឋានចុះបញ្ជីនៅផ្ទះលេខ វិថី សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ តំណាងដោយឈ្មោះ ( ) សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ មានទីលំនៅអចិន្ត្រៃយ៍ផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

អ្នកតំណាងដោយអាណត្តិលោកមេធាវី ការិយាល័យផ្ទះលេខ ៧៨ ផ្លូវលេខ ១៩៩ សង្កាត់ទួលស្វាយព្រៃ២ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ចុងចម្លើយឈ្មោះ កើតថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ជនជាតិ កាន់អត្តសញ្ញាណប័ណ្ណលេខ អាសយដ្ឋានផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

## អង្គហេតុ និងចំណុចវិវាទ

**១. ការទាមទាររបស់ដើមចោទ**

១. សុំរំលាយកិច្ចសន្យាទិញ-លក់អគារខុនដូ ចំនួន ១០ Units ដែលមានលេខ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ និងលេខ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ រវាងក្រុមហ៊ុន និងលោក ។

២. បង្គាប់ឱ្យចុងចម្លើយ បង់ថ្លៃសេវាមេធាវីចំនួន ដុល្លារអាមេរិក និងសងការខូចខាត និងជម្ងឺចិត្តទៅឱ្យក្រុមហ៊ុន ចំនួន ដុល្លារអាមេរិក ។

៣. បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ប្រដាប់ក្ដី និងពន្ធផ្សេងៗ

៤. សុំប្រកាសសាលក្រមមានអានុភាពអនុវត្តជាបណ្ដោះអាសន្ន ។

**២. ការពន្យល់ត្រួសៗអំពីរឿងក្ដី**

២.១. ក្នុងរឿងក្តីនេះដើមចោទសុំទាមទារដូចក្នុងចំណុចទី១ (ការទាមទាររបស់ដើមចោទ) ខាងលើដោយហេតុថា នៅពេលក្រុមហ៊ុនចាប់ផ្តើមនូវគម្រោងសាងសង់ដំបូង ក្រុមហ៊ុនបានផ្តល់នូវទម្រង់កិច្ចសន្យាលក់ទិញដែលមានត្រា និងចុះហត្ថលេខា ជូនទៅអតិថិជនប្រមាណជា ៣០ ទៅ ៤០ ករណី ការផ្តល់នូវទម្រង់កិច្ចសន្យាទៅឱ្យអតិថិជនពិសេសបែបនេះ គឺដើម្បីបង្ហាញពីបែបបទនៃការលក់ទិញដល់អតិថិជនដែលត្រូវបានចាត់ទុកជាអតិថិជនពិសេស ។ បន្ទាប់ពីគម្រោងសាងសង់ជិត បានបញ្ចប់ ក្រុមហ៊ុនបានរកឃើញនូវទម្រង់កិច្ចសន្យាទិញលក់ ចំនួន ១០ ជាមួយនឹងព័ត៌មានដែលបានបំពេញដោយបុគ្គលម្នាក់ដែលក្រុមហ៊ុនពុំដែលបានជួប នៅពេលក្រុមហ៊ុនធ្វើសេចក្តីជូនដំណឹងជាសាធារណៈទៅកាន់អតិថិជនរបស់ខ្លួនដើម្បីមកជួបពួកយើង បន្ទាប់ពីការពិនិត្យទៅលើទម្រង់កិច្ចព្រមព្រៀងដែលត្រូវបានគេបំពេញរួចមក ក្រុមហ៊ុនបានរកឃើញថាទម្រង់កិច្ចព្រមព្រៀងចំនួន១០ដែលត្រូវបានបំពេញរួច រួមមានខុនដូរលេខ ; ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ និង លេខ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ ។

ក្រុមហ៊ុនបានផ្តល់ព័ត៌មានទៅអតិថិជនថា ប្រតិបត្តិការទិញលក់ខុនដូទាំង ១០ ខាងលើនេះ ពុំកើតមានឡើយដោយហេតុថា ក្រុមហ៊ុនមិនដែលស្គាល់ឈ្មោះ និងមិនដែលជួបបុគ្គលម្នាក់នេះឡើយ ទោះបីជាឈ្មោះ ត្រូវបានសរសេរក្នុងកិច្ចព្រមព្រៀងទាំងនេះក្តី តែកិច្ចព្រមព្រៀងទាំង១០ខាងលើ គឺពុំមានសុពលភាពឡើយ សម្រាប់ប្រតិបត្តិការលក់ទិញដែលកើតមានជាហូរហែរ គឺតម្រូវឱ្យក្រុមហ៊ុនចេញនូវលិខិតប្រគល់ទទួលប្រាក់ កិច្ចសន្យាទិញលក់ជាភាសាខ្មែរ និងធ្វើការបញ្ជាក់ឯកសារពីអាជ្ញាធរមូលដ្ឋាន ។ ម្យ៉ាងវិញទៀតតាមទម្រង់នៃកិច្ចសន្យាទិញលក់ ដែលផ្តល់ឱ្យ ហើយត្រូវបានបំពេញឈ្មោះ នៅក្នុងទម្រង់កិច្ចសន្យា ចុងចម្លើយពុំបានប្រគល់ ប្រាក់ថ្លៃទិញខុនដូ មកឱ្យក្រុមហ៊ុនតាមកាលបរិច្ឆេទដូចមានចែងក្នុងកិច្ចសន្យាឡើយ ។

ដើម្បីជៀសវាងការយកនូវទម្រង់នៃកិច្ចសន្យាលក់ទិញខុនដូទាំងនេះ ពីសំណាក់អ្នកទិញទៅប្រើប្រាស់ក្នុងគោលបំណងបោកប្រាស់អ្នកដទៃ និងធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុន នៅពេលដែលប្រតិបត្តិការលក់ទិញពុំទាន់កើតមានរវាងក្រុមហ៊ុន និងចុងចម្លើយ ក្រុមហ៊ុនក៏សម្រេចដាក់ពាក្យបណ្តឹងរំលាយកិច្ចសន្យាលក់ទិញខុនដូទាំង ១០ ខាងលើមកតុលាការតែម្តង ។

**២.២ ចំណុចវិវាទ**

នៅក្នុងរឿងក្តីនេះមិនមានចំណុចវិវាទទេ ។

**២.៣ ការអះអាងរបស់គូភាគី**

ក. <u>ការអះអាងរបស់ដើមចោទ</u>

អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ បានធ្វើសេចក្តីថ្លែងការណ៍ដូចមានក្នុងចំណុច ២.១ (ការពន្យល់ត្រួសៗអំពីរឿងក្តី) គឺសុំទាមទារដូចមាននៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ និងសូមបញ្ជាក់បន្ថែមថា ទម្រង់នៃកិច្ចសន្យាទិញលក់ខុនដូនោះក្នុងប្រការ១ បានចែងថា ក្នុងករណីអ្នកទិញខកខានក្នុងការបង់ប្រាក់លើសពី ២ខែ អ្នកទិញត្រូវចាត់ទុកបំពានកិច្ចសន្យានេះ ក្នុងករណីនេះអ្នកលក់មានសិទ្ធិបញ្ចប់កិច្ចសន្យា ហើយកិច្ចសន្យានេះត្រូវចាត់ទុកជាមោឃៈបន្ទាប់ពីកាលបរិច្ឆេទជូនដំណឹងដោយអ្នកលក់ ហើយអ្នកទិញត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់ពិន័យដែលកើតមានហេតុដល់កិច្ចសន្យានេះត្រូវបានចាត់ទុកជាមោឃៈ ចំណែកផ្នែកទី២ នៃប្រការដដែលនេះបាន

ចែងថា ក្នុងករណីដែលមានការរំលោភបំពានកិច្ចសន្យានេះ ដោយសារការធ្វេសប្រហែសរបស់អ្នកទិញដូចមានកំណត់ក្នុងអាស័យដ្ឋានទំនាក់ទំនង អ្នកលក់រក្សាសិទ្ធិក្នុងការកាន់កាប់ និងលក់ឡើងវិញនូវ Unit នេះទៅឱ្យអតិថិជនថ្មី តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរផ្ញើជូនទៅអាស័យដ្ឋានទំនាក់ទំនងដែលបានផ្តល់ឱ្យដោយអ្នកទិញ លើសពីនេះទៀតប្រការ១១ និងប្រការ១៥ ផ្នែកទី១ នៃកិច្ចសន្យាបានតម្រូវឱ្យកិច្ចសន្យាត្រូវធ្វើជា២ភាសា គឺភាសាខ្មែរ និងភាសាអង់គ្លេស និងបោះត្រាទទួលស្គាល់ដោយចៅសង្កាត់ ហេតុនេះទោះបីជាទម្រង់នៃកិច្ចសន្យាទិញលក់ខុនដូទាំង១០ខាងលើបានបំពេញឈ្មោះចុងចម្លើយជាអ្នកទិញនៅក្នុងកិច្ចសន្យា តែចុងចម្លើយឥតបានបង់ប្រាក់ឱ្យដើមចោទ ជាមូលហេតុនាំឱ្យរំលាយកិច្ចសន្យាដោយយោងតាមមាត្រា ៤០៧ មាត្រា ៤០៨ និងមាត្រា ៥៥៥ នៃក្រមរដ្ឋប្បវេណី ។

ខ. ការអះអាងរបស់ចុងចម្លើយ

ចុងចម្លើយអវត្តមាន ។

## សំអាងហេតុ

១. អ្នកតំណាងដោយអាណត្តិរបស់ដើមចោទបានថ្លែងថា នៅពេលដែលក្រុមហ៊ុនចាប់ផ្តើមនូវគម្រោងសាងសង់ដំបូង ក្រុមហ៊ុនបានផ្តល់នូវទម្រង់កិច្ចសន្យាលក់ទិញដែលមានត្រា និងហត្ថលេខាជូនទៅអតិថិជនប្រមាណជា ៣០ ទៅ ៤០ ករណី ការផ្តល់នូវទម្រង់កិច្ចសន្យាទៅឱ្យអតិថិជនពិសេសបែបនេះ គឺដើម្បីបង្ហាញពីបែបបទនៃការលក់ទិញ ដល់អតិថិជនដែលត្រូវបានចាត់ទុកជាអតិថិជនពិសេស ។ បន្ទាប់ពីគម្រោងសាងសង់ជិតបានបញ្ចប់ ក្រុមហ៊ុនបានរកឃើញនូវទម្រង់កិច្ចសន្យាទិញលក់ចំនួន ១០ ជាមួយនឹងព័ត៌មានដែលបានបំពេញដោយបុគ្គលម្នាក់ ដែលក្រុមហ៊ុនពុំដែលបានជួបនៅពេលក្រុមហ៊ុនធ្វើសេចក្តីជូនដំណឹង ជាសាធារណៈទៅកាន់អតិថិជនរបស់ខ្លួនដើម្បីមកជួប ។

២. ក្នុងទម្រង់នៃកិច្ចសន្យាទិញលក់អគារខុនដូរ ប្រការ១១ ចំណុចទី១ បានចែងថា កិច្ចសន្យាទិញលក់អគារខុនដូរត្រូវមានចុះហត្ថលេខា និងបោះត្រាទទួលស្គាល់ពីចៅសង្កាត់បឹងកេងកងទី១ ប៉ុន្តែកិច្ចសន្យាទិញលក់អគារខុនទាំងដប់ដែលបំពេញព័ត៌មានដោយឈ្មោះ គឺពុំមានការបញ្ជាក់អំពីការទទួលស្គាល់ពីអាជ្ញាធរមូលដ្ឋាន លើកិច្ចសន្យាទិញលក់អគារខុនដូរទាំងនោះទេ ។

ដោយឡែកក្នុងប្រការ១៥ ចំណុចទី១ នៃទម្រង់កិច្ចសន្យាទិញលក់អគារខុនដូរនេះក៏បានចែងដែរថា កិច្ចសន្យាទិញលក់អគារខុនដូរនេះត្រូវធ្វើឡើងជាពីរភាសា គឺភាសាខ្មែរ និងភាសាអង់គ្លេស ប៉ុន្តែកិច្ចសន្យាទិញលក់ដែលដើមចោទបានទទួលគឺមានតែជាភាសាអង់គ្លេសប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀតដើមចោទ ពុំបានរកឃើញថាមានលិខិតប្រគល់ទទួលប្រាក់ពីការទិញលក់របស់ចុងចម្លើយ ទៅតាមដំណាក់កាលដូចមានចែងក្នុងទម្រង់នៃកិច្ចសន្យាទិញលក់អគារខុនដូឡើយ ។

៣. តាមសំអាងហេតុខាងលើបានបញ្ជាក់គួរឱ្យតុលាការជឿបានថា ប្រតិបត្តិការទិញលក់ខុនដូចំនួន ១០ Units ដែលមានលេខ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ និងលេខ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ រវាងក្រុមហ៊ុន និងលោក គឺពុំបានកើតមានឡើយ ហើយក៏ពុំមានសុពលភាពដែរ ដូច្នេះការទាមទាររបស់ដើមចោទគឺមានហេតុផលសមរម្យ ដែលតុលាការគប្បីសម្រេចទទួលស្គាល់ការទាមទារនេះ ។

៤. ការទាមទាររបស់ដើមចោទឱ្យចុងចម្លើយបង់សងថ្លៃសេវាមេធាវីចំនួន ( ) ដុល្លារអាមេរិក និងសងការខូចខាត និងជម្ងឺចិត្តចំនួន ដុល្លារអាមេរិក គប្បីតុលាការសម្រេចទៅតាមភាពសមរម្យ ។

៥. ការប្តឹងសុំរបស់ដើមចោទឱ្យមានការអនុវត្តសាលក្រមជាបណ្តោះអាសន្ន គឺមានហេតុផលសមរម្យស្របទៅនឹងមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បីតុលាការពិចារណា និងសម្រេច ។

៦. ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## ហេតុដូច្នេះសម្រេច

១. រំលាយកិច្ចសន្យាទិញលក់អគារខុនដូចំនួន ១០ Units ដែលមានលេខ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ និងលេខ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ~~២០១២~~ រវាងដើមចោទក្រុមហ៊ុន និងចុងចម្លើយឈ្មោះ

២. ឱ្យចុងចម្លើយឈ្មោះ សងការខូចខាត ជំងឺចិត្ត និងការចំណាយមេធាវីចំនួន ( ) ដុល្លារអាមេរិក ទៅឱ្យក្រុមហ៊ុន តំណាងដោយឈ្មោះ ។ ច្រានចោលការទាមទារលើសពីនេះ ។

៣. សាលក្រមនេះអាចអនុវត្តបណ្តោះអាសន្នបានលើចំណុចទី១ នៃសេចក្តីសម្រេច ។

៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះគូភាគីអាចប្តឹងឧទ្ធរណ៍តាមមាត្រា ២៦០ និងមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ចៅក្រម

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ:...... .......រ.រ.រ

## <u>រូបមន្តអនុវត្តសាលក្រម</u>

យើង ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ រ.ក.ព.រ.វ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ- របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញពាក្យសុំចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ របស់លោក ជាមេធាវីតំណាងដោយអណត្តិឲ្យឈ្មោះ ជាតំណាងក្រុមហ៊ុន មានមានអាស័យដ្ឋានផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

**<u>សូមបញ្ជាក់អំពីខ្លឹមសារនៃការអនុវត្តមានដូចខាងក្រោមនេះ</u>**

ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ ជាតំណាងក្រុមហ៊ុន មានមានអាស័យដ្ឋានផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ មានលោក ជាមេធាវីតំណាងដោយអណត្តិ ។

អាចអនុវត្តដោយបង្ខំ តាមសាលក្រមរដ្ឋប្បវេណីលេខ ក.ព.រ.វ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទី ១ សេចក្តីសម្រេច ។

ពីកូនបំណុលនៃការអនុវត្តឈ្មោះ ភេទប្រុស ជនជាតិ កាន់អត្តសញ្ញាណប័ណ្ណលេខ មានទីលំនៅសព្វថ្ងៃផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកស្ថាប័ននៃការអនុវត្តដោយបង្ខំ ឲ្យសម្រេចតាមសាលក្រមស្ថាពរនេះ និងឲ្យអាជ្ញាធរសាធារណៈជួយអនុវត្តសាលក្រមនេះបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី ......ខែ វិច្ឆិកា ឆ្នាំ

ក្រឡាបញ្ជី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

## លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រម

លេខៈ រ.ស្ថា

យើង ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើ តាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ របស់សាលាដំបូង រាជធានីភ្នំពេញ។

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ក.ព.រ.វ ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ របស់សាលាដំបូង រាជធានីភ្នំពេញ។

-បានឃើញពាក្យសុំចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ របស់ឈ្មោះ មេធាវីតំណាងដោយអាណត្តិឈ្មោះ មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ដែលមាន ខ្លឹមសារស្នើសុំលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមរដ្ឋប្បវេណី លេខ ក.ព.រ.វ ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ របស់សាលាដំបូង រាជធានីភ្នំពេញ។

### សូមបញ្ជាក់ថា

១-សាលក្រមរដ្ឋប្បវេណីលេខ ក.ព.រ.វ ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ បានចូលជាស្ថាពរចាប់ពីថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ រួចហើយ។

២-លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលក្រមនេះ ចេញឲ្យសាមីខ្លួនដើម្បីយកទៅប្រើប្រាស់តាមច្បាប់។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ

ក្រឡាបញ្ជី

ក្រសួងយុត្តិធម៌

# បង្កាន់ដៃបង់ប្រាក់

អង្គភាព............ (ក្បាលបណ្ណរៀង)

ទទួលពី............ អង្គភាព............

ចំនួនទឹកប្រាក់ជាលេខ....10000....

ជាអក្សរ............

អត្ថន័យចំណូល............ មាតិកាថវិកា............

ថ្ងៃទី...... ខែ...... ឆ្នាំ......

អ្នកប្រមូលចំណូល

MINISTRY OF ECONOMY AND FINANCE

បង្កាន់ដៃនេះត្រូវបានបោះពុម្ព និងគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្របតាមអនុក្រឹត្យលេខ៨២អនក្រ. ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥

# ឧបសម្ព័ន្ធ២

## ដីកាសម្រេចច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណីនៃបណ្តឹង
ពិសេសលេខ
ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ
ដីកាសម្រេចលេខ
ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ

# ដីកាសម្រេច

យើង ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញមាត្រា ៣០៧, មាត្រា ៣០៨, មាត្រា ៣១៤ និងមាត្រាពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណី ។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីនៃបណ្តឹងពិសេសលេខ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមាន៖

**ដើមចោទ**

-ឈ្មោះ ភេទ អាយុ ឆ្នាំ និងប្រពន្ធឈ្មោះ អាយុ ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

-មេធាវីតំណាងដោយអាណត្តិលោក ។

**ចុងចម្លើយ**

-ធនាគារ , មានអាស័យដ្ឋានផ្ទះលេខ ផ្លូវ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

**ការទាមទាររបស់ដើមចោទ ៖**

-ប្តឹងសុំឲ្យជំនុំជម្រះសារជាថ្មីនូវសាលក្រមស្ពាតរលេខ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានជំនុំជម្រះកំបាំងមុខ ហើយបានចូលជាស្ថាពរ។

**សេចក្តីថ្លែងការណ៍របស់ដើមចោទ ៖**

-ដើមចោទឈ្មោះ បានធ្វើសេចក្តីថ្លែងការណ៍ថា ៖ ខ្លួនសូមរក្សាសេចក្តីថ្លែងការណ៍ដូចមានក្នុងពាក្យបណ្តឹងសុំឲ្យជំនុំជម្រះសារជាថ្មីចុះថ្ងៃទី០១ ខែវិច្ឆកា ឆ្នាំ និងពាក្យសុំកែប្រែមូលហេតុនៃការសុំជំនុំជម្រះសារជាថ្មីចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ ទុកជាបានការដដែល។ ខ្លួនសូមបញ្ជាក់បន្ថែមថា កាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ខ្លួន និងប្រពន្ធ បានខ្ចីប្រាក់ពីធនាគារ ចំនួន USD ដោយការប្រាក់ ៩% ក្នុងមួយឆ្នាំនៃប្រាក់ដើមដោយក្នុងនោះមានឈ្មោះអ្នកធានាឈ្មោះ

មានផ្តិតមេដៃនៅលើកិច្ចសន្យាបង់ការប្រាក់។ ក្នុងការខ្ចីការប្រាក់នេះ គឺខ្លួនចុះកិច្ចសន្យាខ្ចីប្រាក់បង់រំលោះចំនួន ១២០ ខែ (១០ឆ្នាំ) ក្នុងការបង់រំលោះនោះគឺខ្លួន បានបង់ជាទៀងរាល់ខែជាទៀតទាត់។ ប៉ុន្តែក្រោយមកដល់ឆ្នាំ ខ្លួនមានការរាំងស្ទះប្រាក់ ទើបខ្លួនខកខានពុំបានបង់ប្រាក់តាមការកំណត់របស់ធនាគារទេ ទើបជាហេតុបណ្តាលឲ្យធនាគារប្តឹងខ្លួន។ ក្នុងអំឡុងពេលដំណើរការនីតិវិធីនៃរឿងក្តីនោះ ពួកខ្លួនពុំដែលទទួលបានដីកាកោះពីតុលាការទាល់តែសោះ ជាហេតុធ្វើឲ្យតុលាការធ្វើការជំនុំជម្រះកំបាំងមុខ ហើយបានចូលជាស្ថាពរតែម្តង។ ម្យ៉ាងទៀតនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ ពួកខ្លួនបានយកប្រាក់ទៅសងធនាគារចំនួន USD នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ ពួកខ្លួនបានដាក់ប្រាក់ចូលសងធនាគារចំនួន USD

និងនៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ពួកខ្លួនបានដាក់ចូលធនាគារចំនួន USD សរុបទាំងអស់គឺ USD ដូចមានឯកសារជូនភ្ជាប់។ ប៉ុន្តែខាងធនាគារបែរជាពុំបានយកទូទាត់ដកសាច់ប្រាក់ចេញពីប្រាក់ដែលជំពាក់កន្លងមកទេ បែរជាធ្វើការសម្រេចទៅតាមតែការអះអាងរបស់ភាគីធនាគារតែប៉ុណ្ណោះ។

ម៉្យាងទៀត ដោយហេតុតែពួកខ្លួន មិនបានទទួលដំណឹងពីដីកាកោះរបស់តុលាការ ជាហេតុធ្វើឲ្យពួកខ្លួនខ្វះសិទ្ធិតំណាងដោយអាណត្តិដែលច្បាប់បានកំណត់ ក្នុងការចូលរួមក្នុងសកម្មភាពបណ្ដឹងតាមនីតិវិធី (មាត្រា ៣០៧ ចំណុច គ)។ ការសម្រេចសេចក្ដីក្នុងសាលក្រមស្ថាពរលេខ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ បានធ្វើការសម្រេចដោយឯកឯង ហើយផ្អែកលើភស្តុតាង ដែលភាគីធនាគារបានដាក់ជូនតុលាការតែប៉ុណ្ណោះ ហើយក្នុងសេចក្ដីសម្រេចនេះ បានសម្រេចឲ្យពួកខ្លួនបង់ការប្រាក់ ២៤ % ក្នុងមួយឆ្នាំ ដែលជាការសម្រេចលើសច្បាប់កំណត់ ហើយថែមទាំងសម្រេចឲ្យពួកខ្លួនសងការខូចខាតអំពីព្យសនកម្មបន្ថែមទៀតចំនួន USD ទៀតផង។

ពួកខ្លួន សូមលោកចៅក្រមធ្វើការជំនុំជម្រះជាថ្មីដោយមូលហេតុដូចខាងក្រោម ៖

១/ ចំពោះប្រាក់ដើមចំនួន USD ដែលបានទូទាត់សងធនាគារចំនួន USD តែតុលាការសម្រេចឲ្យខ្លួនសងប្រាក់ដើមដល់ទៅ USD ដោយមិនបានកាត់ប្រាក់ដែលពួកខ្លួនបានសង។ ដូចនេះពួកខ្លួននៅជំពាក់ធនាគារតែ USD ប៉ុណ្ណោះ។

២/ការប្រាក់ក្នុងកិច្ចសន្យាខ្ចីប្រាក់ដើមបានកំណត់តែ ៩ % ទេ តែតុលាការសម្រេចរហូត ២៤ % ដែលខុសពីច្បាប់កំណត់ ១៨ % ក្នុង ១ ឆ្នាំ។ ដូច្នេះ ខ្លួនសូមលោកចៅក្រមមេត្តាសម្រេចលើចំណុចការប្រាក់នេះតែ ៩ % បានហើយ ដោយយោងតាមការព្រមព្រៀងក្នុងកិច្ចសន្យា។

៣/សាលក្រមស្ថាពរពួកខ្លួនមិនដែលបានដឹង មិនដែលទទួលបានដីកាកោះ ឬលិខិតស្នាមអ្វីពីតុលាការក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ការដាក់ភស្តុតាង និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឡើយ។

ខ្លួនសំណូមពរ សូមលោកក្រមទទួលយកបណ្ដឹងជំនុំជម្រះសារជាថ្មីរបស់ខ្លួន ចាត់ការតាមនីតិវិធីដោយក្ដីអនុគ្រោះ។ ខ្លួនសូមលោកចៅក្រមមេត្តាផ្អាកការអនុវត្តសំណុំរឿងអនុវត្តដោយបង្ខំលេខ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ, សូមគិតការប្រាក់តែ ៩ %ដូចមានចែងក្នុងកិច្ចសន្យា, និងសូមកុំឲ្យមានការកំណត់ប្រាក់ពិន័យ ឬសំណងជម្ងឺចិត្តអ្វីឡើយ។

-លោក មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ បានធ្វើសេចក្ដីថ្លែងការណ៍ថា ៖ ខ្លួនសូមលោកចៅក្រមសម្រេចយកសំណុំរឿងខាងលើទៅជំនុំជម្រះសារជាថ្មីដោយក្ដីអនុគ្រោះ ព្រោះថាការប្ដឹងសុំជំនុំជម្រះសារជាថ្មីរបស់កូនក្ដីខ្លួននេះ ពិតជាមានមូលហេតុត្រឹមត្រូវដូចមានចែងក្នុងមាត្រា ៣០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលក្នុងនោះ ៖

១/ក្នុងចំណាត់ការរបស់ចៅក្រមលើសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ ចាប់ពីនីតិវិធីត្រៀម រហូតដល់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ កូនក្ដីខ្លួនពុំបានទទួលដំណឹងជាក់លាក់ណាមួយពីតុលាការដើម្បីចូលរួមក្នុងនីតិវិធីនោះទេ ដូច្នេះកូនក្ដីរបស់ខ្លួនបានបាត់បង់សិទ្ធិក្នុងការជូនភស្តុតាង និងមិនបានរកអ្នកតំណាង ដើម្បីជួយការពារផលប្រយោជន៍ស្របច្បាប់របស់កូនក្ដីខ្លួនដែរ។ ការមិនបានទទួលព័ត៌មានពីតុលាការនេះហើយទើបកូនក្ដីខ្លួន បានយកលុយទៅបង់

ឲ្យធនាគារជាបន្តបន្ទាប់សរុប USD ដូចដែលកូនក្តីរបស់ខ្លួនបានអះអាងរួចហើយ ដែលកាលបរិច្ឆេទនៃការបង់ប្រាក់នេះ សុទ្ធតែនៅក្រោយពេលដែលតុលាការចេញសាលក្រម ដែលនេះបញ្ជាក់ឲ្យឃើញថាកូនក្តីរបស់ខ្លួនមិនបានដឹងពីសាលក្រមកំបាំងមុខចំពោះខ្លួននោះទេ បើពុំនោះទេក៏មិនយកប្រាក់ទៅសងធនាគារនោះដែរ គួរណាស់តែយកមកបង់នៅតុលាការ ទើបជាការត្រឹមត្រូវ។

២/ភស្តុតាងដែលជាមូលហេតុសម្រាប់ការវិនិច្ឆ័យរបស់តុលាការ គឺពុំបានគ្រប់ជ្រុងជ្រោយនៅឡើយ ដោយហេតុថាកូនក្តីខ្លួនបានខ្លោះសិទ្ធិក្នុងការដាក់ជូនតុលាការ។

៣/សាលក្រម ដែលជាកម្មវត្ថុនៃបណ្តឹងទាមទាឲ្យជំនុំជម្រះជាថ្មី របស់កូនក្តីខ្លួន មានការប៉ះពាល់ដល់សាលក្រមមុនដែលចូលជាស្ថាពរហើយ ព្រោះថាប្រសិនបើតុលាការទទួលបានភស្តុតាងពីកូនក្តីរបស់ខ្លួនយកទៅវិនិច្ឆ័យនោះ តុលាការនឹងមិនចេញសេចក្តីសម្រេចបែបនោះឡើយ។

អាស្រ័យហេតុនេះ សូមលោកចៅក្រម មេត្តាសម្រេចតាមការស្នើសុំរបស់កូនក្តីខ្លួន ទទួលយកសំណុំរឿងនេះទៅជំនុំជម្រះសារជាថ្មី ដោយក្តីអនុគ្រោះ។

## **សំអាងហេតុ**

-ដើមចោទឈ្មោះ និងប្រពន្ធឈ្មោះ បានដាក់ពាក្យបណ្តឹងសុំឲ្យជំនុំជម្រះសារជាថ្មីនូវសាលក្រមស្ថាពរលេខ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ សំអាងលើមូលហេតុមួយចំនួនដូចជា ខ្លួនបានសងប្រាក់ចំនួន ដុល្លារអាមេរិកឲ្យទៅខាងធនាគាររួចទៅហើយ, ធនាគារធ្វើការគណនាការប្រាក់លើសពីច្បាប់កំណត់, ខ្លួនមិនដែលបានដឹងមិនដែលទទួលបានដីកាកោះ ឬ លិខិតស្នាមអ្វីពីតុលាការក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ការដាក់ភស្តុតាង និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឡើយ។ រាល់មូលហេតុដែលបានអះអាងដោយដើមចោទមិនមែនជាមូលហេតុដែលអាចឲ្យតុលាការលើកយកសំណុំរឿងមកធ្វើការជំនុំជម្រះជាថ្មី ដូចមានចែងក្នុងមាត្រា ៣០៧ និងមាត្រា ៣០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីទេ។ ហេតុដូចនេះ គប្បីតុលាការច្រានចោលការទាមទារជំនុំជម្រះសារជាថ្មីរបស់ដើមចោទ តាមបញ្ញត្តិមាត្រា ៣១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## **សេចក្តីសម្រេចបញ្ចប់**

-ច្រានចោលបណ្តឹងសុំជំនុំជម្រះសារជាថ្មីចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ និងពាក្យសុំកែប្រែមូលហេតុនៃការសុំជំនុំជម្រះសារជាថ្មីចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ របស់ដើមចោទឈ្មោះ និងឈ្មោះ ។

**ចៅក្រម**

ហត្ថលេខា និងត្រា:

........................................ ........................................

បានឃើញ
**ចៅក្រម**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ
**ក្រឡាបញ្ជី**

# ឧបសម្ព័ន្ធ៣

## នីតិវិធីមុនចេញដីកាសម្រេចចាប់ផ្ដើមជំនុំជម្រះសាជាថ្មី

- ដីកាកោះ លិខិតអញ្ជើញមេធាវី និងរបាយការណ៍អំពីការបញ្ជូន
- កំណត់ហេតុសាកសួរដើមចោទ
- កំណត់ហេតុសាកសួរចុងចម្លើយ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ជាន់ទី បន្ទប់

**សាលាដំបូងរាជធានីភ្នំពេញ**

# ដីកាកោះ

យើង ចៅក្រម នៃសាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី

លេខៈ ចុះថ្ងៃទី

៣១. ១២.

អញ្ជើញលោក អគ្គនាយកនៃធនាគារ

ជាដើមចោទ ។

ទីស្នាក់ការអគាររលេខ ផ្លូវ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

ឲ្យចូលមកកាន់សាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី ១១ -០១ វេលាម៉ោង ១៤,៣០ នាទី ដើម្បី ធ្វើសេចក្តីបញ្ជាក់ដំបូង ពីដំណើររឿងប្តឹងសុំឲ្យតុលាការសម្រេចដូចខាងក្រោមៈ

១-ជំនុំជម្រះសាជាថ្មីចំពោះសាលក្រមលេខ ចុះថ្ងៃទី ២០ -១០ - របស់សាលាដំបូងរាជធានីភ្នំពេញលើសេចក្តីសម្រេចទាំងមូល។

២-ច្រានចោលពាក្យបណ្តឹងចុះថ្ងៃទី ១២ -៨ របស់ក្រុមហ៊ុន ( ) ។

៣-បង្គាប់ឲ្យចុងចម្លើយសងការខូចខាតរួមមានជម្ងឺចិត្ត ការខាតបង់ផ្សេងៗ និងសេវាមេធាវីចំនួន ដុល្លាអាមេរិក ឲ្យមកដើមចោទ។

៤-ឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឲ្យបានទាន់ពេលវេលា និងយក លិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មករា ឆ្នាំ

**ចៅក្រម**

ថ្ងៃទី ០៦ - ០១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី
លេខៈ ចុះថ្ងៃទី
៣១.១២.

## ដីកាកោះ

យើង ចៅក្រម នៃសាលាដំបូងរាជធានីភ្នំពេញ

អញ្ជើញលោក ( ) ភេទប្រុស អាយុ ឆ្នាំ សញ្ជាតិ ជាចុងចម្លើយ ។

ទីលំនៅផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

ឲ្យចូលមកកាន់សាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី ១៨ -០១ - វេលាម៉ោង ១៤,៣០ នាទី ដើម្បី ធ្វើសេចក្តីបញ្ជាក់ដំបូង ពីដំណើររឿង តំណាងដោយលោក ប្តឹងសុំឲ្យតុលាការសម្រេចដូចខាងក្រោមៈ

១-ជំនុំជម្រះសាជាថ្មីចំពោះសាលក្រមលេខ ចុះថ្ងៃទី ២០ -១០ - របស់សាលាដំបូងរាជធានីភ្នំពេញលើសេចក្តីសម្រេចទាំងមូល។

២-ច្រានចោលពាក្យបណ្តឹងចុះថ្ងៃទី ១២ -៨ - របស់ក្រុមហ៊ុន ។

៣-បង្គាប់ឲ្យចុងចម្លើយសងការខូចខាតរួមមានជម្ងឺចិត្ត ការខាតបង់ផ្សេងៗ និងសេវាមេធាវីចំនួន ដុល្លាអាមេរិក ឲ្យមកដើមចោទ។

៤-ឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឲ្យបានទាន់ពេលវេលា និងយក លិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ

ចៅក្រម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

## របាយការណ៍អំពីការបញ្ជូន

ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី

កាលបរិច្ឆេទផ្ញើចេញ: ថ្ងៃទី 06 ខែ 01 ឆ្នាំ ..........

លេខសំណុំរឿង [illegible] /31/12

ឈ្មោះឯកសារដែលត្រូវបានបញ្ជូន: [illegible]

ឈ្មោះអ្នកទទួលបន្ទុកកិច្ចការបញ្ជូន: ..........

អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន: សាលាដំបូងរាជធានីភ្នំពេញ ..........

ឈ្មោះជនដែលត្រូវទទួលការបញ្ជូន: ..........

ហត្ថលេខា ឬស្នាមមេដៃអ្នកទទួលឯកសារដាក់ស្តែង: [illegible]

ប្រអប់ខាងក្រោមត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន (កត្តាប្រៃសណីយ៍ អាជ្ញាសាលា ឬក្រឡាបញ្ជី)

ទីកន្លែងដែលបានធ្វើការបញ្ជូន: ..........

កាលបរិច្ឆេទនៃការបញ្ជូននេះ: ថ្ងៃទី 14 ខែ 01 ឆ្នាំ .......... ម៉ោង 3415 ព្រឹក រសៀល

**វិធីដាក់ស្តែងក្នុងការបញ្ជូន**

| | |
|---|---|
| ☐ ១ | បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ<br>ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលដីកាបញ្ជូននូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូនពីព្រោះនៃជននោះមិនចេះអានអក្សរ |
| ☐ ២ | បានប្រគល់ឯកសារទៅដល់អ្នកដែលមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់នៅទីកន្លែងដែលត្រូវបញ្ជូននោះទេ<br>☐ អ្នកបំរើ ☐ អ្នកជេរ្យងដែលធ្វើការនៅទីនោះ ☐ អ្នកនៅជាមួយ<br>ឈ្មោះ: |
| ☐ ៣ | ឯកសារត្រូវបានទុកនៅឯកន្លែងដែលត្រូវធ្វើការបញ្ជូនដោយហេតុថាបុគ្គលខាងក្រោមនេះមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល<br>☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបំរើ<br>☐ អ្នកនៅជាមួយ ☐ អ្នកជេរ្យងដែលធ្វើការនៅទីនោះ<br>ឈ្មោះ: |

☐ ខ្ញុំបានបញ្ជូនឯកសារតាមវិធីដូចខាងលើ

☐ ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូនខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនេះ ។

កាលបរិច្ឆេទធ្វើរបាយការណ៍: ថ្ងៃទី 14 ខែ 01 ឆ្នាំ ..........

ឈ្មោះ និងហត្ថលេខាអ្នកធ្វើរបាយការណ៍: [signature]

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី
លេខៈ ចុះថ្ងៃទី
៣១. ១២.

# ដីកាកោះ

យើង ចៅក្រម នៃសាលាដំបូងរាជធានីភ្នំពេញ

អញ្ជើញលោក - ជាតំណាងក្រុមហ៊ុន ជាចុងចម្លើយ ។

ទីស្នាក់ការផ្ទះលេខ វិថី សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

ឲ្យចូលមកកាន់សាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី ១៨ -០១ វេលាម៉ោង ១៤,៣០ នាទី ដើម្បី ធ្វើសេចក្តីបញ្ជាក់ដំបូង ពីដំណើររឿង សាជីវកម្មធនាគារ - តំណាងដោយលោក ប្តឹងសុំឲ្យតុលាការសម្រេចដូចខាងក្រោមៈ

១-ជំនុំជម្រះសាជាថ្មីចំពោះសាលក្រមលេខ -ចុះថ្ងៃទី ២០ -១០ - របស់សាលាដំបូងរាជធានីភ្នំពេញលើសេចក្តីសម្រេចទាំងមូល។

២-ច្រានចោលពាក្យបណ្តឹងចុះថ្ងៃទី ១២ -៨ - របស់ក្រុមហ៊ុន ។

៣-បង្គាប់ឲ្យចុងចម្លើយសងការខូចខាតរួមមានជម្ងឺចិត្ត ការខាតបង់ផ្សេងៗ និងសេវាមេធាវីចំនួន ដុល្លាអាមេរិក ឲ្យមកដើមចោទ។

៤-ឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឲ្យបានទាន់ពេលវេលា និងយក លិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ

**ចៅក្រម**

ក.៣៣៣ -12- 01-

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# របាយការណ៍អំពីការបញ្ជូន

ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី

| |
|---|
| កាលបរិច្ឆេទផ្ញើចេញ: ថ្ងៃទី 06 ខែ 01 ឆ្នាំ ............ |
| លេខសំណុំរឿង /... /31/12/ |
| ឈ្មោះឯកសារដែលត្រូវបានបញ្ជូន: ............ |
| ឈ្មោះអ្នកទទួលបន្ទុកកិច្ចការបញ្ជូន: ............ |
| អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូនៈ សាលាដំបូងរាជធានីភ្នំពេញ ............ |
| ឈ្មោះជនដែលត្រូវទទួលការបញ្ជូន: ............ |

ហត្ថលេខា ឬស្នាមមេដៃអ្នកទទួលឯកសារជាក់ស្តែង ............

ប្រអប់ខាងក្រោមត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន (កត្តាប្រៃសណីយ៍ អាជ្ញាសាលា ឬក្រឡាបញ្ជី)

| | | |
|---|---|---|
| ទីកន្លែងដែលបានធ្វើការបញ្ជូន: ............ | | |
| ការបរិច្ឆេទនៃការបញ្ជូននេះថ្ងៃទី 12 ខែ 01 ឆ្នាំ ... ម៉ោង 2h30 ព្រឹក រសៀល | | |
| វិធីជាក់ស្តែងក្នុងការបញ្ជូន | | |
| ☐ | ១ | បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ |
| | | ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលដីកាបញ្ជូននូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូនពីព្រោះនៃជននោះមិនចេះអានអក្សរ |
| ☐ | ២ | បានប្រគល់ឯកសារទៅដល់អ្នកដែលមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់នៅទីកន្លែងដែលត្រូវបញ្ជូននោះទេ |
| | | ☐ អ្នកបំរើ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ ☐ អ្នកនៅជាមួយ |
| | | ឈ្មោះ: |
| ☐ | ៣ | ឯកសារត្រូវបានទុកនៅឯកន្លែងដែលត្រូវធ្វើការបញ្ជូនដោយហេតុថាបុគ្គលខាងក្រោមនេះមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល |
| | | ☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបំរើ |
| | | ☐ អ្នកនៅជាមួយ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ: |
| | | ឈ្មោះ: |
| ☐ ខ្ញុំបានបញ្ជូនឯកសារតាមវិធីដូចខាងលើ | | |
| ☐ ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូនខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនេះ ។ | | |
| កាលបរិច្ឆេទធ្វើរបាយការណ៍: ថ្ងៃទី 12 ខែ 01 ឆ្នាំ ............ | | |
| ឈ្មោះ និងហត្ថលេខាអ្នកធ្វើរបាយការណ៍: | | |

កំណត់សំគាល់សម្រាប់អ្នកប្រតិបត្តិការបញ្ជូន:

១-ប្រសិនបើជនដែលទទួលឯកសារជាក់ស្តែង (ជនដែលត្រូវទទួលការបញ្ជូន ឬ បុគ្គលផ្សេង) មិនចេះសរសេរ ឬចុះហត្ថលេខា ឬមិនអាចផ្តិតម្រាមដៃបានទេ អ្នកប្រតិបត្តិការបញ្ជូនត្រូវចុះនិទ្ទេសពីការណ៍នោះនៅកន្លែង "ហត្ថលេខា ឬស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែង"

២-ទីកន្លែងដែលបានធ្វើការបញ្ជូន "ត្រូវតែសរសេរឱ្យបានច្បាស់ៗ និងត្រឹមត្រូវ" ។

៣-ប្រសិនបើការបញ្ជូនបានធ្វើឡើងតាមចំណុចលេខ ១ អ្នកបញ្ជូនត្រូវគូស ☐ ហើយប្រសិនបើបានពន្យល់ជូនពីខ្លឹមសារសង្ខេប ត្រូវគូស ☐ នៅក្នុងប្រអប់ដែរ ។ ប្រសិនបើការបញ្ជូនបានធ្វើឡើងតាមចំណុចលេខ២ ត្រូវគូស ☐ នៅក្នុងប្រអប់មុខលេខ២ ហើយត្រូវបញ្ជាក់ពីបុគ្គលទទួលដោយគូស ☐ នៅក្នុងប្រអប់កំណត់បុគ្គលទទួល និងសរសេរឈ្មោះបុគ្គលដែលបានទទួលនោះផង ។ ប្រសិនបើការបញ្ជូនបានធ្វើឡើងតាមចំណុចលេខ៣ អ្នកបញ្ជូនត្រូវគូស ☐ នៅក្នុងប្រអប់មុខលេខ៣ ហើយត្រូវបញ្ជាក់ពីបុគ្គលដែលមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផលនេះ ដោយការគូស ☐ នៅក្នុងប្រអប់កំណត់បុគ្គលដែលមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផលនោះ ដោយការគូស ☐ នៅក្នុងប្រអប់កំណត់បុគ្គលដែលមិនព្រមទទួលការបញ្ជូន ហើយត្រូវសរសេរឈ្មោះបុគ្គលដែលមិនព្រមទទួលការបញ្ជូននោះចូលផង ។

៤-ក្នុងករណីដែលអ្នកធ្វើរបាយការណ៍មិនអាចធ្វើការបញ្ជូនឯកសារបានសម្រេច អ្នកធ្វើរបាយការណ៍នោះត្រូវគូស ☐ នៅក្នុងប្រអប់នៅពីមុខឃ្លាដែលសរសេរថា "ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូន ខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមស្របក្នុងការទទួលឯកសារនេះ" ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# លិខិតអញ្ជើញ

យើង ចៅក្រម នៃសាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី

លេខៈ ចុះថ្ងៃទី

៣១. ១២ .

អញ្ជើញលោកស្រី និងលោក ជាមេធាវីតំណាងដោយអាណត្តិឲ្យ លោក ( ) ជាចុងចម្លើយ ។ ការិយាល័យតាំងនៅផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

ឲ្យចូលមកកាន់សាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី ២៦-០១- វេលាម៉ោង ១៤,៣០ នាទី ដើម្បី សាកសួរបំភ្លឺ ពីដំណើររឿង

ប្តឹងសុំឲ្យតុលាការសម្រេចដូចខាងក្រោមៈ

១-ជំនុំជម្រះសាជាថ្មីចំពោះសាលក្រមលេខ ចុះថ្ងៃទី ២០ -១០ របស់សាលាដំបូងរាជធានីភ្នំពេញលើសេចក្តីសម្រេចទាំងមូល។

២-ច្រានចោលពាក្យបណ្តឹងចុះថ្ងៃទី ១២ -៨- របស់ក្រុមហ៊ុន ។

៣-បង្គាប់ឲ្យចុងចម្លើយសងការខូចខាតរួមមានជម្ងឺចិត្ត ការខាតបង់ផ្សេងៗ និងសេវាមេធាវីចំនួន ដុល្លាអាមេរិក ឲ្យមកដើមចោទ។

៤-ឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះឲ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

រាជធានីភ្នំពេញ ថ្ងៃទី ខែ មករា ឆ្នាំ

ចៅក្រម

Date: 20 01.

[illegible]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

# របាយការណ៍អំពីការបញ្ជូន

ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី

កាលបរិច្ឆេទផ្ញើចេញ៖ ថ្ងៃទី 18 ខែ 01 ឆ្នាំ ..........

លេខសំណុំរឿង [illegible] 131/12

ឈ្មោះឯកសារដែលត្រូវបានបញ្ជូន៖ [illegible]

ឈ្មោះអ្នកទទួលបន្ទុកកិច្ចការបញ្ជូន៖ ..........

អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន៖ សាលាដំបូងរាជធានីភ្នំពេញ

ឈ្មោះជនដែលត្រូវទទួលការបញ្ជូន៖ [illegible]

ហត្ថលេខា ឬស្នាមមេដៃអ្នកទទួលឯកសារផ្ទាល់ស្លែង៖ [illegible]

ប្រអប់ខាងក្រោមត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន (តុលាការប្រៃសណីយ៍ អាជ្ញាសាលា ឬក្រឡាបញ្ជី)

ទីកន្លែងដែលបានធ្វើការបញ្ជូន៖ ..........

កាលបរិច្ឆេទនៃការបញ្ជូននេះ៖ ថ្ងៃទី ២០ ខែ 01 ឆ្នាំ .......... ម៉ោង 8:50 ព្រឹក ~~រសៀល~~

**វិធីជាក់ស្តែងក្នុងការបញ្ជូន**

☐ ១ បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ
ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលដីកាបញ្ជូននូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូនពីព្រោះនៃជននោះមិនចេះអានអក្សរ

☐ ២ បានប្រគល់ឯកសារទៅដល់អ្នកដែលមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់នៅទីកន្លែងដែលត្រូវបញ្ជូននោះទេ
☐ អ្នកបំរើ ☐ អ្នកជិតខាងដែលធ្វើការនៅទីនោះ ☐ អ្នកនៅជាមួយ
ឈ្មោះ៖

☐ ៣ ឯកសារត្រូវបានទុកនៅឯកន្លែងដែលត្រូវធ្វើការបញ្ជូនដោយហេតុថាបុគ្គលខាងក្រោមនេះមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផល
☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបំរើ
☐ អ្នកនៅជាមួយ ☐ អ្នកជិតខាងដែលធ្វើការនៅទីនោះ៖
ឈ្មោះ៖

☐ ខ្ញុំបានបញ្ជូនឯកសារតាមវិធីដូចខាងលើ

☐ ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូនខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនេះ ។

កាលបរិច្ឆេទធ្វើរបាយការណ៍៖ ថ្ងៃទី ២០ ខែ 01 ឆ្នាំ ..........

ឈ្មោះ និងហត្ថលេខាអ្នកធ្វើរបាយការណ៍៖ [signature]

កំណត់សំគាល់សម្រាប់អ្នកប្រតិបត្តិការបញ្ជូន:

១-ប្រសិនបើជនដែលទទួលឯកសារជាក់ស្តែង (ជនដែលត្រូវទទួលការបញ្ជូន ឬ បុគ្គលផ្សេង) មិនចេះសរសេរ ឬចុះហត្ថលេខា ឬមិនអាចផ្តិតម្រាមដៃបានទេ អ្នកប្រតិបត្តិការបញ្ជូនត្រូវចុះនិទ្ទេសពីការណ៍នោះនៅកន្លែង "ហត្ថលេខា ឬស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែង"

២-ទីកន្លែងដែលបានធ្វើការបញ្ជូន "ត្រូវតែសរសេរឱ្យបានច្បាស់ៗ និងត្រឹមត្រូវ" ។

៣-ប្រសិនបើការបញ្ជូនបានធ្វើឡើងតាមចំណុចលេខ ១ អ្នកបញ្ជូនត្រូវគូស ☐ ហើយប្រសិនបើបានពន្យល់ជូនពីខ្លឹមសារសង្ខេប ត្រូវគូស ☐ នៅក្នុងប្រអប់ដែរ ។ ប្រសិនបើការបញ្ជូនបានធ្វើឡើងតាមចំណុចលេខ២ ត្រូវគូស ☐ នៅក្នុងប្រអប់មុខលេខ២ ហើយត្រូវបញ្ជាក់ពីបុគ្គលទទួលដោយគូស ☐ នៅក្នុងប្រអប់កំណត់បុគ្គលទទួល និងសរសេរឈ្មោះបុគ្គលដែលបានទទួលនោះផង ។ ប្រសិនបើការបញ្ជូនបានធ្វើឡើងតាមចំណុចលេខ៣ អ្នកបញ្ជូនត្រូវគូស ☐ នៅក្នុងប្រអប់មុខលេខ៣ ហើយត្រូវបញ្ជាក់ពីបុគ្គលដែលមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផលនេះ ដោយការគូស ☐ នៅក្នុងប្រអប់កំណត់បុគ្គលដែលមិនព្រមទទួលការបញ្ជូនដោយគ្មានហេតុផលនោះ ដោយការគូស ☐ នៅក្នុងប្រអប់កំណត់បុគ្គលដែលមិនព្រមទទួលការបញ្ជូន ហើយត្រូវសរសេរឈ្មោះបុគ្គលដែលមិនព្រមទទួលការបញ្ជូននោះចូលផង ។

៤-ក្នុងករណីដែលអ្នកធ្វើរបាយការណ៍មិនអាចធ្វើការបញ្ជូនឯកសារបានសម្រេច អ្នកធ្វើរបាយការណ៍នោះត្រូវគូស ☐ នៅក្នុងប្រអប់នៅពីមុខឃ្លាដែលសរសេរថា "ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើនេះបានសម្រេចទេ ពីព្រោះនៅទីកន្លែងដែលត្រូវបញ្ជូន ខ្ញុំមិនបានជួបជនដែលត្រូវទទួលការបញ្ជូន ឬជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនេះ" ។

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី
លេខៈ ចុះថ្ងៃ
ទី ៣១-១២-

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## កំណត់ហេតុសាកសួរសាមីភាគី

សញ្ញាណរឿងក្តី

កម្មវត្ថុៈប្តឹងសុំជំនុំជំរះជាថ្មីពោះសាលក្រមលេខ ក.ព.វ.វចុះថ្ងៃទី២០-១០-

លោក ជាចៅក្រមសាលាដំបូងសាលាដំបូងរាជធានីភ្នំពេញ

លោក ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ឆ្នាំ ខែមករា ថ្ងៃទី ដប់មួយ វេលាម៉ោង ដប់ប្រាំ រសៀល នៅសាលាដំបូងរាជធានីភ្នំពេញ។

ដើមចោទ តំណាងដោយលោក ទីស្នាក់ការអគារលេខ ផ្លូវ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

មានលោក ជាមេធាវីតំណាងដោយអាណត្តិ ។

លោក ជាមេធាវីតំណាងដោយអាណត្តិឲ្យ

បានធ្វើសេចក្តីថ្លែងការណ៍ថាៈ ខ្ញុំបាទសូមរក្សាពាក្យបណ្តឹងទាមទារឲ្យជំនុំជំរះសាជាថ្មី ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ របស់កូនក្តីខ្ញុំបាទទុកជាបានការទាំងមូល។

ស.ឆៈ ខ្ញុំបាទបញ្ជាក់ជូនលោកចៅក្រមមេត្តាជ្រាបថាៈ មូលហេតុដែលកូនក្តីខ្ញុំបាទប្តឹងសុំទាមទារឲ្យជំនុំជំរះសាជាថ្មី ដោយសារកាលពីខែកក្កដា និងខែសីហា ឆ្នាំ លោក បានខ្ចីប្រាក់កូនក្តីខ្ញុំបាទ ចំនួន ដោយគិតការប្រាក់ ក្នុងនោះលោក បានយកដាក់បញ្ចាំនូវបន្ទប់ខុនដូរចំនួន ១០ បន្ទប់គឺលេខ ស្ថិតនៅផ្ទះលេខ ផ្លូវលេខ និងផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ និងបានតំកល់កិច្ចសន្យាទិញលក់អាគារខុនដូ ច្បាប់ដើម ដើម្បីធានាសងបំណុលឲ្យកូនក្តីខ្ញុំបាទ។

ក្រោយពីបានខ្ចីប្រាក់ខាងលើរួច ចាប់តាំងពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ មក លោក ពុំបានបង់ការប្រាក់ដូចកំណត់ក្នុងកិច្ចសន្យាខ្ចីចងការប្រាក់ទេ ទោះជាកូនក្តីខ្ញុំបាទព្យាយាមដាស់តឿនឲ្យអនុវត្តកាតព្វកិច្ចយ៉ាងណាក៏ដោយ ក៏លោកមិនបានអើពើទេ ហើយបានគេចខ្លួនបាត់តែម្តង។

ក្រោយពីកូនក្តីខ្ញុំបាទបានដាស់តឿនឲ្យលោក សងប្រាក់ខាងលើ ស្រាប់តែលោក បានគេចខ្លួនបាត់ ហើយពេលនោះ ក្រុមហ៊ុន

ក៏បានទាក់ទងជាមួយធនាគារខ្ញុំបាទតាំងពីខែតុលា ឆ្នាំ មកម្លេះ តាមរយៈលិខិតចុះថ្ងៃទី២២ ខែតុលា ឆ្នាំ របស់លោកស្រីមេធាវី មេធាវីតំណាងឲ្យក្រុមហ៊ុន បានបញ្ជាក់ចំណុចមួយថា «...

*បានទទួលកម្ចីក្រោមឈ្មោះ (សំណើកម្ចីចំនួនពីរផ្សេងគ្នា), និង (សំណើកម្ចីចំនួន ពីរផ្សេងគ្នា)។*

*កម្ចីក្រោមឈ្មោះ និង ត្រូវបានបង់ផ្តាច់រួចរាល់អស់ហើយ កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ តាមរយៈជំនួបបង់សងផ្តាច់ចុងក្រោយរវាង និង ធនាគារ (ដែលក្រោយមកប្តូរជាឈ្មោះ ធនាគារកូនក្តីខ្ញុំបាទបច្ចុប្បន្ន) ជាមួយនឹងអត្រាការប្រាក់បន្ថែមចំនួន ដុល្លាអាមេរិក។ គិតចាប់ពីខែធ្នូ ឆ្នាំ មក បានព្យាយាមចងបង់សងផ្តាច់កម្ចីដែលនៅមានក្រោម ឈ្មោះ ប៉ុន្តែធនាគារ បានបដិសេធដោយមិនមានយុត្តិកម្មសមរម្យឡើយ។..»*

ហើយនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ កូនក្តីខ្ញុំបាទចេញលិខិតមួយច្បាប់ជូនទៅលោក ប្រធានក្រុមហ៊ុន ដោយបញ្ជាក់អំពីបំណុលរបស់លោក និងការដាក់បញ្ចាំបន្ទប់ខុនដូរទាំង១០ខាងលើ ដើម្បីធានាបំណុលខាងលើ។

ការចរចារនេះក៏ពុំបានលទ្ធផលអ្វីជាដុំកំភួនទេ តែអ្វីដែលកូនក្តីខ្ញុំបាទចាប់អារម្មណ៍គឺបន្ទាប់ពីលោក បានគេចខ្លួនបាត់ហើយ ទើបក្រុមហ៊ុន ចេញមុខចរចារជាមួយកូនក្តីខ្ញុំបាទ។

លុះដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ កូនក្តីខ្ញុំបាទក៏បានដាក់ពាក្យបណ្តឹងទាមទារប្រាក់កម្ចីខាងលើទាំងអស់ពីលោក វិញ ទៅសាលាដំបូងរាជធានីភ្នំពេញ។

លុះដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ទើបសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចចេញសាលក្រមលេខ ភ.ព.រ.វ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ ដោយបង្គាប់ឲ្យលោក សងប្រាក់កម្ចីទាំងអស់ដល់កូនក្តីខ្ញុំបាទវិញ។

ស្រាប់តែថ្ងៃទី២២ ខែសីហា ឆ្នាំ ក្រុមហ៊ុន បានដាក់ពាក្យបណ្តឹងទៅសាលាដំបូងរាជធានីភ្នំពេញ ទាមទាររំលាយកិច្ចសន្យាទិញលក់អាគារខុនដូរទាំង១០របស់លោក ដែលបានធ្វើរវាងលោក និងក្រុមហ៊ុន ចោល ដោយមិនបានជូនដំណឹងដល់កូនក្តីខ្ញុំបាទដើម្បីចូលរួមក្នុងនីតិវិធីនៃបណ្តឹងរបស់ក្រុមហ៊ុនទេ ទោះបីក្រុមហ៊ុនបានដឹងថាកូនក្តីខ្ញុំបាទជាម្ចាស់បំណុលរបស់លោក ហើយបណ្តឹងនេះនឹងប៉ះពាល់ផលប្រយោជន៍កូនក្តីខ្ញុំបាទយ៉ាងណាក៏ដោយ មិនតែប៉ុណ្ណោះក្រុមហ៊ុនបានព្យាយាមលាក់បាំងតុលាការនូវបញ្ហានេះទៀតផង រហូតដល់តុលាការចេញសាលក្រមលេខ ភ.ព.រ.វ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលធ្វើឲ្យប៉ះពាល់ផលប្រយោជន៍កូនក្តីខ្ញុំបាទយ៉ាងធ្ងន់ធ្ងរ។ ក្នុងនោះ

លោក ក៏ពុំអើពើ ឬចូលដោះស្រាយ ឬតវ៉ា ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ឬជូនដំណឹងដល់កូនក្តីខ្ញុំបាទទេ។

ហើយកូនក្តីខ្ញុំបាទ ទើបតែដឹងអំពីសាលក្រមរបស់ក្រុមហ៊ុនខាងលើ បន្ទាប់ពីតុលាការ អនុវត្ត ចុះទៅពិនិត្យស្ថានភាពបច្ចុប្បន្ននៃបន្ទប់ខុនដូរទាំង ១០ របស់លោក តាមពាក្យសុំអនុវត្តរបស់កូនក្តីខ្ញុំបាទ ទើបក្រុមហ៊ុនអះអាងថា កិច្ចសន្យាទិញលក់របស់លោក និងក្រុមហ៊ុន ដែលលោក បានយកទៅដាក់បញ្ចាំឲ្យធនាគារខ្ញុំបាទ ត្រូវបានតុលាការសម្រេចរំលាយចោលហើយតាមសាលក្រមលេខ ភ.ព.រ.រ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ ឯសាលក្រមនេះបានចូលស្ថាពរហើយ ដែលក្រុមហ៊ុនព្យាយាមលាក់បាំងមិនឲ្យកូនក្តីខ្ញុំបាទដឹងទេ ហើយបានធ្វើឲ្យធនាគារខ្ញុំបាទមានការភ្ញាក់ផ្អើលជាខ្លាំង ព្រោះកូនក្តីខ្ញុំបាទមិនដែលបានទទួលដំណឹងអំពីការនីតិវិធីនៃសំណុំរឿងនេះទេ ដោយហេតុថាក្រុមហ៊ុនបានដឹងថា បន្ទប់ខុនដូរទាំង១០ ខាងលើបានដាក់បញ្ចាំនៅកូនក្តីខ្ញុំបាទ នោះកូនក្តីខ្ញុំបាទមានផលប្រយោជន៍ក្នុងសំណុំរឿងនេះដែរ ហើយការសម្រេចសេចក្តីក្នុងសំណុំរឿងនេះ គឺប៉ះពាល់ផលប្រយោជន៍យ៉ាងខ្លាំងរបស់កូនក្តីខ្ញុំបាទ ដោយសារសាលក្រមនេះបានធ្វើឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិដែលបានដាក់បញ្ចាំនៅនឹងកូនក្តីខ្ញុំបាទ។ ហេតុនេះ ក្នុងនីតិវិធីនៃបណ្តឹងរបស់ក្រុមហ៊ុន ត្រូវជូនដំណឹងទៅតុលាការ អំពីផលប្រយោជន៍របស់កូនក្តីខ្ញុំបាទ ដើម្បីឲ្យកូនក្តីខ្ញុំបាទបានចូលរួមការពារផលប្រយោជន៍របស់ខ្លួនផងដែរ។

ក្រោយពីទទួលដំណឹងខាងលើភ្លាម កូនក្តីខ្ញុំបាទបានប្រគល់សិទ្ធិឲ្យខ្ញុំបាទ ដើម្បីស្នើសុំថតចម្លងឯកសារនៃសំណុំរឿងរបស់ក្រុមហ៊ុនខាងលើមកសិក្សា ហើយឃើញថា សិទ្ធិជាមូលដ្ឋាន និងគោលការណ៍ចំពោះមុខ ដែលត្រូវធានាដោយតុលាការមិនត្រូវបានអនុវត្តដោយត្រឹមត្រូវតាមក្រមនីតិវិធីរដ្ឋប្បវេណីទេ ហើយតុលាការក៏ពុំបានសម្រេចសេចក្តីដោយត្រឹមត្រូវ និងផ្អែកលើភស្តុតាងទេ តួយ៉ាងឃើញថា:

<u>***ក. អំពីដំណើរការនីតិវិធីរបស់តុលាការ:***</u>

១. ចុងចម្លើយលោក នៃសំណុំរឿងរបស់ក្រុមហ៊ុន តុលាការមិនបានជូនដំណឹងឲ្យបានត្រឹមត្រូវ ដើម្បីធានាថា ចុងចម្លើយអាចបានទទួលដំណឹងអំពីសំណុំរឿងនេះទេ។

២. តុលាការគឺមិនអាចចេញសាលក្រមកំបាំងមុខបានឡើយ ប្រសិនបើខ្លឹមសារនៃសេចក្តីថ្លែងការណ៍ ដែលដើមចោទបានធ្វើនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលចុងចម្លើយមិនបានបង្ហាញខ្លួន ហើយខ្លឹមសារនៃសេចក្តីថ្លែងការណ៍នោះមិនបានជូនដំណឹងទៅចុងចម្លើយមុនកាលបរិច្ឆេទនោះ តាមមាត្រា ២០២ នៃក្រមនីតិវិធីរដ្ឋប្បវេណី តែតុលាការបែរជាចេញសាលក្រមទៀត។

៣. ចុងក្រោយ តុលាការមិនបានធានាសិទ្ធិប្តឹងតវ៉ា(ប្តឹងទាស់) ស្របតាមមាត្រា ២០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីទេ ដោយមិនបានបើកផ្លូវប្តឹងទាស់លើសាលក្រមខាងលើទេ ព្រោះសាលក្រមនេះ

បានចេញដោយកំបាំងមុខចុងចម្លើយ ដោយសារចុងចម្លើយអវត្តមាន តែបែរជាបើកផ្លូវឲ្យគូភាគីប្ដឹងឧទ្ធរណ៍តែម្ដង។

ខ. អំពីខ្លឹមសារនៃសេចក្ដីសម្រេចរបស់តុលាការៈ

តុលាការសម្រេចសេចក្ដីដោយរំលាយកិច្ចសន្យាទិញលក់ខាងលើ គឺផ្អែកលើការអះអាងរបស់ដើមចោទទាំងស្រុង តែមិនបានផ្អែកលើភស្តុតាងទេ ដែលជាហេតុធ្វើឲ្យមូលហេតុនៃសេចក្ដីសម្រេចរបស់តុលាការគឺមិនសមហេតុផល និងអាចទទួលយកបានទេ តួយ៉ាងដូចជាៈ

១. តើអ្វីជាការផ្ដល់កិច្ចសន្យាទិញលក់ពិសេសដល់អតិថិជនរបស់គេ? តើការផ្ដល់កិច្ចសន្យាទិញលក់ពិសេសមានអ្វីប៉ះពាល់ដល់ការរំលាយកិច្ចសន្យានេះ។

២. តើកិច្ចសន្យាដែលមិនបានចុះហត្ថលេខាដោយអាជ្ញាធរមូលដ្ឋាន ជាមូលហេតុនៃការរំលាយកិច្ចសន្យានេះដែរឬទេ?

កូនក្ដីខ្ញុំបាទមានភស្តុតាងបញ្ជាក់ថា កិច្ចសន្យាទិញលក់របស់ក្រុមហ៊ុនភាគច្រើន មិនដែលមានចុះហត្ថលេខាដោយអាជ្ញាធរមូលដ្ឋានទេ ក៏នៅតែមានប្រសិទ្ធិភាពអនុវត្ត ហើយក្រុមហ៊ុនបានកាត់ផ្ទេរប្លង់កម្មសិទ្ធិ ឬប្លង់រឹងឲ្យអ្នកទិញដែរ។

ម្យ៉ាងវិញទៀត កាតព្វកិច្ចយកកិច្ចសន្យាទិញលក់ទៅឲ្យអាជ្ញាធរមូលដ្ឋានចុះហត្ថលេខា ជាកាតព្វកិច្ចរបស់ក្រុមហ៊ុនទេ បើក្រុមហ៊ុនមិនយកកិច្ចសន្យានេះទៅឲ្យអាជ្ញាធរមូលដ្ឋាន ហើយ ផ្ដល់កិច្ចសន្យាទិញលក់ដល់អថិតិជន នោះបញ្ជាក់ថាជាកំហុសរបស់ក្រុមហ៊ុនទេ។

មួយវិញទៀត ដោយសារការចុះហត្ថលេខាដោយអាជ្ញាធរមូលដ្ឋានលើកិច្ចសន្យាទិញលក់មិនត្រូវបានអនុវត្ត ទើបកិច្ចសន្យាទិញលក់ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ក៏ពែងទាមទារឲ្យមានការចុះហត្ថលេខា ដោយចៅសង្កាត់ទៀតហើយ។

៣. តើកិច្ចសន្យាដែលមិនបានចុះជាភាសាខ្មែរ និងជាភាសាអង់គ្លេស គឺមិនមានសុពលភាពឬ? តើកិច្ចសន្យាដែលចុះតែភាសាអង់គ្លេសមិនអាចអនុវត្តបានមែនទេ?

តាមប្រការ ១៥ ផ្នែក ១ នៃកិច្ចសន្យាទិញលក់ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ បានចែងថា ...សំណៅភាសាអង់គ្លេស និងខ្មែរ នៃកិច្ចព្រមព្រៀងនេះមានតម្លៃស្មើគ្នាចំពោះមុខច្បាប់។

តាមប្រការ ១១ ចំណុច ៤ នៃកិច្ចសន្យាទិញលក់ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ បានចែងថា កិច្ចព្រមព្រៀងនេះ បកប្រែជាសំណៅភាសាខ្មែរ។ ទោះបីជាយ៉ាងណា សំណៅជាភាសាអង់គ្លេសត្រូវយកជាសំណៅគោល។

ផ្អែកតាមកិច្ចសន្យាខាងលើឃើញថា ការធ្វើកិច្ចសន្យាទិញលក់ជាភាសាអង់គ្លេស ក៏នៅតែមានសុពលភាពដែរ។ ម្យ៉ាងវិញទៀត ខ្ញុំបាទជឿថាកិច្ចសន្យាទិញលក់ជាមួយលោក-

នេះមិនអាចធ្វើជាភាសាខ្មែរ ដោយសារអ្នកទិញជាជនបរទេស ហើយមិនយល់ពីខ្លឹមសារនៃកិច្ចសន្យាជាភាសាខ្មែរដែរ។ ហើយការរៀបចំកិច្ចសន្យាទិញលក់គឺត្រូវរៀបចំដោយក្រុមហ៊ុន ហេតុនេះ តើការមិនធ្វើជាភាសាខ្មែរជាកំហុសរបស់អ្នកណា?

៤. ~~ដើមចោទ~~ (ភាគី ក្រុមហ៊ុន) ពុំរកឃើញថាមានលិខិតប្រគល់ទទួលប្រាក់ពីការទិញលក់របស់ចុងចម្លើយ។ តើត្រូវការលិខិតប្រគល់ទទួលប្រាក់ដែរឬទេ? ប្រសិនបើកិច្ចសន្យាទិញលក់ទាំង

១០ បន្ទប់ខាងលើ ក្រុមហ៊ុនបានបញ្ជាក់ច្បាស់ថា បានបង់ប្រាក់គ្រប់ចំនួន ១០០% ហើយនោះ និងមានប្រថាប់ត្រាក្រុមហ៊ុនទៀតផង។ ហេតុនេះទើបគ្មានហេតុផលត្រូវបង់ប្រាក់តាមដំណាក់កាលណាមួយទៀតទេ ហើយក្នុងកិច្ចសន្យាក៏មិនបានកំណត់ពីដំណាក់កាលបង់ប្រាក់ដែរ។

<u>សរុបសេចក្តីមក</u> ហេតុផលនៃការរំលាយកិច្ចសន្យាទិញលក់ខាងលើ ថា គ្មានសុពលភាពរបស់ តុលាការ គឺមិនសមស្របទេ។

ខ្ញុំបាទសូមបញ្ជាក់ជូនលោកចៅក្រមបន្ថែមទៀតថា:

ដំបូងឡើយ លោក បានទិញបន្ទប់របស់ក្រុមហ៊ុនតែប្រាំបន្ទប់តែប៉ុណ្ណោះ គឺបន្ទប់លេខ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ ដោយបញ្ជាក់ថាបានបង់ប្រាក់គ្រប់ចំនួន ១០០%។ ប្រសិនបើលោក មិនបានបង់ប្រាក់ថ្លៃទិញបន្ទប់ ហេតុអ្វីបានជាជាង ១ ឆ្នាំក្រោយទៀត នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ ក្រុមហ៊ុននៅបន្តលក់បន្ទប់ប្រាំ ទៀតឲ្យទៅលោក គឺបន្ទប់លេខ ដោយបញ្ជាក់ថាបង់ប្រាក់គ្រប់ចំនួនទៀត? ជាងនេះទៅទៀត រហូតដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ និងបន្ទាប់ពីលោក គេចខ្លួនបាត់ ទើបក្រុមហ៊ុនចាប់ផ្តើមប្តឹងរំលាយកិច្ចសន្យាទិញលក់ខាងលើ តើក្រុមហ៊ុនខ្លាចលោក ចេញមុខបកអាក្រាតរឿងពិត ឬបកអាក្រាតលើការអះអាងរបស់ក្រុមហ៊ុនទៅតុលាការខាងលើជារឿងពុំពិត ព្រោះការអះអាងនេះហាក់ដូចជាមិនសមហេតុផលសោះ?

ជាងនេះទៅទៀត ប្រសិនបើលោក មិនបានបង់ប្រាក់គ្រប់ចំនួន ហេតុអ្វីបានជាក្រុមហ៊ុនបញ្ជាក់យ៉ាងច្បាស់ក្នុងកិច្ចសន្យាទិញលក់ថា លោក បានបង់ប្រាក់គ្រប់ចំនួនហើយ។ ហើយប្រគល់កិច្ចសន្យានេះចប់ដើមឲ្យលោក ប្រើប្រាស់។

ប្រសិនបើក្រុមហ៊ុនមិនបានបញ្ជាក់ច្បាស់ថា អ្នកទិញលោក បានបង់ប្រាក់គ្រប់ចំនួនទេ និងក្រុមហ៊ុនមិនបានផ្តល់កិច្ចសន្យាទិញលកច្បាប់ដើម ដល់លោក ទេ ក៏កូនក្តីខ្ញុំបាទមិនផ្តល់ប្រាក់កម្ចីដែរ។

ម្យ៉ាងវិញទៀត ប្រសិនដូចសេចក្តីអះអាងរបស់ក្រុមហ៊ុនថាលោក ជាអតិថិជនពិសេស ទើបផ្តល់នូវទំរង់នៃកិច្ចសន្យាទិញលក់ពិសេសខាងលើដល់លោក នោះមានន័យថា ក្រុមហ៊ុនគឺបានសមគំនិត ឬបានជួយសម្រួលដល់លោក រួចទៅហើយ ដើម្បីយកកិច្ចសន្យាទិញលក់ខាងលើទៅប្រើប្រាស់ ទោះបីជាលោក មិនទាន់បានបង់ប្រាក់ដល់ក្រុមហ៊ុនក៏ដោយ ដោយសារលោក ជាអតិថិជនពិសេស ហេតុនេះ ក្រុមហ៊ុននៅតែត្រូវទទួលខុសត្រូវចំពោះការខូចខាតរបស់កូនក្តីខ្ញុំបាទដែរ ដោយសារការសមគំនិត ឬការសម្រួលរបស់ក្រុមហ៊ុនខាងលើ។

សរុបសេចក្តីមក សេចក្តីអះអាងខាងលើពិតជាបញ្ជាក់ថា ក្រុមហ៊ុន និងលោក ពិតជាមានអាថ៌កំបាំង ឬអាចនិយាយថា មាន

ការរួមគំនិតគ្នា រៀបចំឯកសារផ្សេងៗ ដើម្បីអាចខ្ចីប្រាក់កូនក្តីខ្ញុំបាទ។ ហើយក៏អាចនិយាយថា ពួកគេបានរួមគំនិតគ្នា ក្នុងគោលបំណងធ្វើឲ្យបាត់បង់ផលប្រយោជន៍របស់កូនក្តីខ្ញុំបាទ ដោយទទួលបាននូវសាលក្រមលេខ ភ.ព.រ.វ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ - របស់សាលាដំបូងរាជធានីភ្នំពេញ ដោយឲ្យលោក - . គេចខ្លួន ពុំចូលរួមតតាំងក្នុងនីតិវិធីរបស់តុលាការ ដែលបានបញ្ជាក់ច្បាស់ដូចមានក្នុងលិខិតចុះថ្ងៃទី២២ ខែតុលា ឆ្នាំ របស់លោកស្រីមេធាវី មេធាវីតំណាងឲ្យក្រុមហ៊ុន បានបញ្ជាក់ចំណុចមួយថា "...

*បានទទួលកម្ចីក្រោមឈ្មោះ (សំណើកម្ចីចំនួនពីរផ្សេងគ្នា).*

*និង (សំណើកម្ចីចំនួន ពីរផ្សេងគ្នា)។*

*កម្ចីក្រោមឈ្មោះ និង ត្រូវបានបង់ផ្តាច់រួចរាល់អស់ហើយ កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ តាមរយៈជំនួបបង់សងផ្តាច់ចុងក្រោយរវាង និង ធនាគារ (ដែលក្រោយមកប្តូរជាឈ្មោះ ធនាគារកូនក្តីខ្ញុំបាទបច្ចុប្បន្ន) ជាមួយនឹងអត្រាការប្រាក់បន្ថែមចំនួន ដុល្លាអាមេរិក។ គិតចាប់ពីខែធ្នូ ឆ្នាំ -មក បានព្យាយាមចងបង់សងផ្តាច់កម្ចីដែលនៅមានក្រោម ឈ្មោះ ប៉ុន្តែធនាគារ បានបដិសេធដោយមិនមានយុត្តិកម្មសមរម្យឡើយ។..."*

សំណូមពរសុំឲ្យតុលាការជួយរកយុត្តិធម៌ឲ្យកូនក្តីខ្ញុំបាទដោយសម្រេចៈ

១-ជំនុំជំរះសាជាថ្មីចំពោះសាលក្រមលេខ ភ.ព.រ.វ ចុះថ្ងៃទី២០-១០- របស់សាលាដំបូងរាជធានីភ្នំពេញលើសេចក្តីសម្រេចទាំងមូល។

២-ប្រានចោលពាក្យបណ្តឹងចុះថ្ងៃទី២២ ខែសីហា ឆ្នាំ របស់ក្រុមហ៊ុន- ។

៣-បង្គាប់ឲ្យចុងចម្លើយ ក្រុមហ៊ុន និងលោក សងការខូចខាត រួមមានជម្ងឺចិត្ត ការខាតបង់ផ្សេងៗ និងសេវាមេធាវី ចំនួន ឲ្យមកកូនក្តីខ្ញុំបាទ។

៤-ឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

បញ្ឈប់កំណត់ហេតុនៅវេលាម៉ោងដប់ប្រាំមួយរសៀល នាថ្ងៃខែឆ្នាំដូចខាងលើបានអានឱ្យអ្នកប្តឹងសុំស្តាប់ថាពិតជាត្រឹមត្រូវនិងយល់ព្រមផ្តិតមេដៃជាមួយយើង ។

**មេធាវីដើមចោទ** **ក្រឡាបញ្ជី** **ចៅក្រម**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី

លេខៈ

ចុះថ្ងៃទី ៣១-១២-

# <u>កំណត់ហេតុសាកសួរសាមីភាគី</u>

សញ្ញាណរឿងក្តី

កម្មវត្ថុៈប្តឹងសុំជំនុំជម្រះជាថ្មីចំពោះសាលក្រមលេខ - ភ.ព.រ.រ ចុះថ្ងៃទី២០-១០-

លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

លោក ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ឆ្នាំ ខែមករា ថ្ងៃទីម្ភៃប្រាំមួយ វេលាម៉ោងដប់បួន និងសាមសិបនាទីរសៀល នៅសាលាដំបូងរាជធានីភ្នំពេញ។

ចុងចម្លើយ ក្រុមហ៊ុន មានទីស្នាក់ការផ្ទះលេខ វិថី សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ មានលោក ( ) ជាតំណាង ។

មានលោកស្រី និងលោក ជាមេធាវីតំណាងដោយអាណត្តិ។

លោក ជាមេធាវីតំណាងដោយអាណត្តិឱ្យក្រុមហ៊ុន បានធ្វើសេចក្តីថ្លែងការណ៍ថាៈ ខ្ញុំបាទមិនទាន់អាចធ្វើការថ្លែងការណ៍លំអិតដើម្បីតបចំពោះមូលហេតុនៃការស្នើសុំឲ្យជំនុំជម្រះសារជាថ្មីរបស់ដើមចោទនោះទេ ដោយហេតុថាៈ

១-ពាក់ព័ន្ធនឹងសំណុំរឿងជំនុំជម្រះសាជាថ្មីនេះ ដោយយោងតាមមាត្រា៣១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺត្រូវអនុវត្តតាមបញ្ញត្តិនៃមាត្រា៤១ (បទបញ្ញាស្តីពីការវិនិច្ឆ័យលើសហបណ្តឹងចាំបាច់) ដូច្នេះ គឺជាការចាំបាច់ណាស់ចំពោះការចូលរួមក្នុងនីតិបណ្តឹងរបស់ភាគីសហចុងចម្លើយលោក ប៉ុន្តែ នីតិវិធីនៃការបញ្ជូនដីកាកោះ និងការកោះហៅ ធ្វើឡើងពុំបានត្រឹមត្រូវតាមនីតិវិធីច្បាប់នោះទេ។

២-អាសយដ្ឋានដែលភាគីដើមចោទផ្តល់ជូនតុលាការពេលនេះ គឺពុំមែនជាអាសយដ្ឋានរបស់ភាគីសហចុងបណ្តឹងឈ្មោះ នោះទេ តាមរបាយការណ៍របស់មន្ត្រីទទួលបន្ទុកពីការបញ្ជូនរបស់សាលាដំបូងរាជធានីភ្នំពេញ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ គឺបញ្ជាក់ថា រកពុំឃើញអាសយដ្ឋានដូចមានក្នុងពាក្យបណ្តឹងនោះទេ។

៣-ការបញ្ជូនតាមការផ្សាយជាសាធារណៈតាមពាក្យសុំរបស់មេធាវីតំណាងដោយអាណត្តិឲ្យភាគីដើមចោទ គឺធ្វើឡើងពុំត្រូវតាមនីតិវិធីច្បាប់នោះទេ យោងតាមមាត្រា ២៥៥ (លក្ខខណ្ឌដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ) ការបញ្ជូនតាមការផ្សាយជាសាធារណៈអាចធ្វើទៅបានលុះត្រាតែៈ

-ទោះបីបានខិតខំប្រឹងប្រែងស្រាវជ្រាវរកអាសយដ្ឋាន ហើយនៅតែរកមិនឃើញ

-មិនអាចបញ្ជូនតាមបញ្ញត្តិមាត្រា៥២៥២

-មិនអាចបញ្ជូនតាមបញ្ញត្តិមាត្រា២៥៣ (ការបញ្ជូនដែលត្រូវធ្វើនៅបរទេស)

ប៉ុន្តែដើមចោទពុំបានធ្វើការស្វែងរក ឬកែតម្រូវអាសយដ្ឋានរបស់ភាគីសហចុងចម្លើយដើម្បីឲ្យតុលាការធ្វើការកោះហៅ និងបញ្ជូនតាមនីតិវិធីនោះទេ។

និងយោងតាមមាត្រា ២៥៧ (ពេលដែលការបញ្ជូនតាមការផុព្វាយជាសាធារណៈមាន

ចាប់ពីថ្ងៃបិទប្រកាស តាមបញ្ញត្តិមាត្រា ២៥៦ ដូច្នេះការបញ្ជូនតាមការផ្សាយជាសាធារណៈ ធ្វើឡើងមិនត្រឹមត្រូវតាមនីតិវិធីនោះទេ។

៤-ក្នុងនាមជាមេធាវីតំណាងដោយអាណត្តិឲ្យសហចុងចម្លើយលោក ខ្ញុំបាទ សុំឲ្យតុលាការបង្គាប់ឲ្យដើមចោទកែតម្រូវ និងផ្តល់អាសយដ្ឋានរបស់សហចុងចម្លើយលោក ឲ្យបានច្បាស់លាស់ និងធ្វើការកោះហៅ និងបញ្ជូនឲ្យបានត្រឹមត្រូវតាមនីតិវិធីច្បាប់។

៥-យោងតាមមាត្រា ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការគប្បីគោរពគោលការណ៍ចំពោះមុខ និងយោងតាមមាត្រា ៣១៨ ត្រង់កថាខណ្ឌទី៣ ដែលចែងថា បញ្ញត្តិនៃមាត្រា៤១ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ និងដោយយោងតាមមាត្រា ៤១ កថាខណ្ឌទី៣ ដែលបញ្ញត្តិថា ប្រសិនបើមានមូលហេតុក្នុងការផ្អាក ឬបង្អង់នូវនីតិវិធីនៃបណ្តឹងចំពោះបុគ្គលម្នាក់ក្នុងចំណោមអ្នកធ្វើសហបណ្តឹងការផ្អាក ឬការបង្អង់នោះមានអានុភាពទៅលើបុគ្គលទាំងអស់ ដូច្នេះដោយយោងលើគោលការនេះ តុលាការត្រូវផ្អាក ឬបង្អង់នីតិវិធីនៃបណ្តឹងសិន ព្រោះថា យើងមិនបានដឹងថាសហចុងចម្លើយលោក បាត់ខ្លួន ឬទទួលមរណៈភាព ឬមានហេតុផ្សេងណាមួយ ដែលបណ្តាលឲ្យគាត់មិនអាចទទួលព័ត៌មានអំពីការកោះហៅ និងចូលរួមក្នុងនីតិវិធីបណ្តឹងនេះ។

៦-ក្នុងនាមជាម្ចាស់បំណុលជាធនាគារ គប្បីដឹងច្បាស់អំពីអាសយដ្ឋានរបស់កូនបំណុល ដូច្នេះ ដើមចោទដឹងពិតប្រាកដណាស់អំពីអាសយដ្ឋានរបស់កូនបំណុល ប៉ុន្តែហាក់បីដូចជាមានការលាក់បាំង ដើមចោទពុំមានភាពសុចរិត និងស្មោះត្រង់ក្នុងការអនុវត្តបណ្តឹងរដ្ឋប្បវេណី តាមមាត្រា ៤ នៃក្រមរដ្ឋប្បវេណី ហើយបែរជាចោទកូនក្តីខ្ញុំបាទ ថាបានរួមគំនិតជាមួយសហចុងចម្លើយលោក ធ្វើឲយបាត់បង់ផលប្រយោជន៍ ផ្ទុយទៅវិញ ប្រសិនបើដើមចោទ មានភាពសុចរិតក្នុងការអនុវត្តបណ្តឹងរដ្ឋប្បវេណី ត្រូវផ្តល់អាសយដ្ឋានសហចុងចម្លើយ បើមិនដូច្នោះទេ យើងអាចសន្ទត់បានថា ដើមចោទ និងសហចុងចម្លើយលោក បានរួមគំនិតគ្នាក្នុងគោលបំណងធ្វើឲ្យបាត់បង់ប្រយោជន៍កូនក្តីខ្ញុំបាទ។

ចម្លើយបំភ្លឺតបពាក់ព័ន្ធនឹងការស្នើសុំឲ្យជំនុំជម្រះសាជាថ្មីរបស់សហចុងចម្លើយសហចុងចម្លើយរបស់លោក មានសារសំខាន់បំផុត ព្រោះថាគាត់មានទំនាក់ទំនងគតិយុត្តជាមួយធនាគារ រីឯកូនក្តីខ្ញុំបាទពុំមានទំនាក់ទំនងគតិយុត្តជាមួយនឹងធនាគារ ឬជាមួយសហចុងចម្លើយលោក នោះទេ ដោយខាងក្រុមហ៊ុនពុំដែលបានជួប ឬស្គាល់សហចុងចម្លើយលោក ឡើយ។

បញ្ចប់កំណត់ហេតុនៅវេលាម៉ោងដប់ប្រាំ និងដប់នាទី រសៀល នាថ្ងៃខែឆ្នាំដូចខាងលើ បានអានឲ្យមេធាវីចុងចម្លើយស្តាប់ថាពិតជាត្រឹមត្រូវ និងយល់ព្រមផ្តិតមេដៃជាមួយយើង។

**មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយ　　ក្រឡាបញ្ជី　　ចៅក្រម**

# ឧបសម្ព័ន្ធ៤

## ដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី

បន្ទប់( ) ជាន់ទី

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខៈ រ.រ
ចុះថ្ងៃទី២៣ -០២-

## ដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសារជាថ្មី

យើង ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញមាត្រា ៣១៥ និងមាត្រាពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រ កម្ពុជា។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខៈ ចុះថ្ងៃទី ៣១-១២- របស់សាលាដំបូងរាជធានីភ្នំពេញ។

-រវាងដើមចោទឈ្មោះ ជាធនាគារដែលចុះបញ្ជីស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា តំណាងដោយលោក ជាអគ្គនាយកនៃធនាគារ មានទីស្នាក់ការអគារលេខ ផ្លូវ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

មានលោក ជាមេធាវីតំណាងដោយអាណត្តិ ។

និងសហចុងចម្លើយៈ

-ក្រុមហ៊ុន ) ទីស្នាក់ការផ្ទះលេខ វិថី សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ មានលោក ជាតំណាង។

មានលោកស្រី និងលោក ជាមេធាវីតំណាងដោយអាណត្តិ។

-ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ សញ្ជាតិ ទីលំនៅផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

<u>ដែលមានកម្មវត្ថុនៃបណ្តឹង</u>ៈ ប្តឹងសុំជំនុំជម្រះសារជាថ្មីចំពោះសាលក្រម ភ.ព.រ.វ ចុះថ្ងៃទី ២០-១០- របស់សាលាដំបូងរាជធានីភ្នំពេញ លើសេចក្តីសម្រេចទាំងមូល ។

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ភ.ព.រ.វ ចុះថ្ងៃទី ២០-១០- របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញកំណត់ហេតុសាកសួរសាមីភាគីដើមចោទចុះថ្ងៃទី ១១-០១- ។

-បានឃើញកំណត់ហេតុសាកសួរសាមីភាគីចុងចម្លើយ ចុះថ្ងៃទី ២៦-០១- ។

## <u>សំអាងហេតុ</u>

តាមលទ្ធផលនៃការសាកសួរសាមីភាគី និងពិនិត្យភស្តុតាងរួចមកឃើញថាៈ

-បណ្តឹងសុំជំនុំជម្រះសារជាថ្មី ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ របស់ដើមចោទឈ្មោះ មានលោក ជាមេធាវីតំណាងដោយអាណត្តិ ចំពោះសាលក្រមរដ្ឋប្បវេណីលេខ រ.ព.រ.វ ចុះថ្ងៃទី ២០-១០- របស់សាលាដំបូងរាជធានីភ្នំពេញ ជាសមត្ថកិច្ចរបស់សាលាដំបូងរាជធានីភ្នំពេញ យោងតាមបញ្ញត្តិ

មាត្រា ៣០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២-តាមសេចក្តីថ្លែងការណ៍របស់លោក- ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ បានថ្លែងថាៈ ខ្លួនប្តឹងសុំឱ្យតុលាការជំនុំជម្រះសារជាថ្មី ចំពោះសាលក្រមរដ្ឋប្បវេណីលេខ ភ.ព.រ.វ ចុះថ្ងៃទី ២០-១០- របស់សាលាដំបូងរាជធានីភ្នំពេញ ដោយហេតុថា ក្រុមហ៊ុន បានដាក់ពាក្យបណ្តឹងទៅសាលាដំបូងរាជធានីភ្នំពេញ ទាមទាររំលាយកិច្ចសន្យាទិញលក់អាគារខុនដូទាំង១០គឺៈបន្ទប់លេខ របស់លោក ជាមួយក្រុមហ៊ុន ចោល ដោយមនបានជូនដំណឹងដល់កូនក្តីខ្លួន ដើម្បីចូលរួមក្នុងនីតិវិធីនៃបណ្តឹងរបស់ក្រុមហ៊ុនទេ ទោះបីក្រុមហ៊ុន -បានដឹងថាអគារខុនដូទាំង១០នោះឈ្មោះ បានយកមកដាក់បញ្ចាំធានាបំណុលជាមួយ កូនក្តីខ្លួន មិនតែប៉ុណ្ណោះក្រុមហ៊ុនបានព្យាយាមលាក់បាំងតុលាការនូវបញ្ហានេះទៀតផង រហូតដល់តុលាការចេញសាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី២០ ខែ តុលា ឆ្នាំ ដែលធ្វើឱ្យប៉ះពាល់ផលប្រយោជន៍កូនក្តីខ្លួនយ៉ាងធ្ងន់ធ្ងរ។ ក្នុងនោះលោក -ក៏ពុំអើពើ ឬចូលដោះស្រាយ ឬតវ៉ា ដើម្បីការពារផលប្រយោជន៍របស់គាត់ ឬជូនដំណឹងដល់កូនក្តីខ្លួនទេ។

ក្រោយពីទទួលដំណឹងខាងលើកូនក្តីខ្លួន បានប្រគល់សិទ្ធិឱ្យខ្លួន ដើម្បីស្នើសុំថតចម្លងឯកសារនៃសំណុំរឿងរបស់ក្រុមហ៊ុនខាងលើមកសិក្សាហើយឃើញថា សិទ្ធិជាមូលដ្ឋាន និងគោលការណ៍ចំពោះមុខ ដែលត្រូវធានាដោយតុលាកាៈមិនត្រូវបានអនុវត្តដោយត្រឹមត្រូវតាមក្រមនីតិវិធីរដ្ឋប្បវេណីទេ ហើយតុលាការក៏ពុំបានសម្រេចសេចក្តីដោយត្រឹមត្រូវ និងផ្អែកលើភស្តុតាងទេ តួយ៉ាងឃើញថាៈ

២-១-ចុងចម្លើយឈ្មោះ នៃសំណុំរឿងរបស់ក្រុមហ៊ុន តុលាការមិនបានជូនដំណឹងឱ្យបានត្រឹមត្រូវ ដើម្បីធានាថា ចុងចម្លើយអាចបានទទួលដំណឹងអំពីសំណុំរឿងនេះទេ។

២-២-តុលាការគឺមិនអាចចេញសាលក្រមកំបាំងមុខបានឡើយ ប្រសិនបើខ្លឹមសារនៃសេចក្តីថ្លែងការណ៍ដែលដើមចោទបានធ្វើនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលចុងចម្លើយមិនបានបង្ហាញខ្លួន ហើយខ្លឹមសារនៃសេចក្តីថ្លែងការណ៍នោះមិនបានជូនដំណឹងទៅចុងចម្លើយមុនកាលបរិច្ឆេទនោះ តាមមាត្រា ២០២ នៃក្រមនីតិវិធីរដ្ឋប្បវេណី តែតុលាការបែរជាចេញសាលក្រមទៀត។

២-៣-ចុងក្រោយ តុលាការមិនបានធានាសិទ្ធិប្តឹងតវ៉ា(ប្តឹងទាស់) ស្របតាមមាត្រា ២០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីទេ ដោយមិនបានបើកផ្លូវប្តឹងទាស់លើសាលក្រមខាងលើទេ ព្រោះសាលក្រមនេះបានចេញដោយកំបាំងមុខចុងចម្លើយ ដោយសារចុងចម្លើយអវត្តមាន តែបែរជាបើកផ្លូវឱ្យគូភាគីប្តឹងឧទ្ធរណ៍តែម្តង។

សរុបសេចក្តីមក ក្រុមហ៊ុន និងលោក
ពិតជាមានអាថ៌កំបាំង ឬអាចនិយាយថា មានការរួមគំនិតគ្នា រៀបចំឯកសារផ្សេងៗ ដើម្បីអាចខ្វីប្រាក់កូនក្តីខ្លួន។ ហើយក៏អាចនិយាយថា ពួកគេបានរួមគំនិតគ្នា ក្នុងគោលបំណងធ្វើឲ្យបាត់បង់ផលប្រយោជន៍របស់កូនក្តីខ្លួន ដោយទទួលបាននូវសាលក្រមរដ្ឋប្បវេណីលេខ ភ.ព.រ.រ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ ដោយឲ្យលោក គេចខ្លួន ពុំចូលរួមតតាំងក្នុងនីតិវិធីរបស់តុលាការ ។.

៣-តាមសេចក្តីថ្លែងការណ៍របស់លោក មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយក្រុមហ៊ុន បានថ្លែងការណ៍ តវ៉ាចំពោះអាស័យដ្ឋានរបស់សហចុងចម្លើយ ឈ្មោះ ថាដើមចោទផ្តល់អាស័យដ្ឋានសហចុងចម្លើយរូបនេះមិនត្រឹមត្រូវដែលធ្វើឲ្យបាត់បង់ផលប្រយោជន៍ដល់កូនក្តីខ្លួន នឹងនាំឲ្យមិនបានគោរពដល់គោលការណ៍ចំពោះមុខ។

ផ្ទុយទៅវិញ អាស័យដ្ឋានរបស់សហចុងចម្លើយឈ្មោះ ដែលដើមចោទឈ្មោះ ផ្តល់ជូនតុលាការគឺផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ដែលអាស័យដ្ឋាននេះ ដូចគ្នានិងអាស័យដ្ឋានរបស់ចុងចម្លើយឈ្មោះ នៅក្នុងសាលក្រមរដ្ឋប្បវេណីលេខ ភ.ព.រ.រ ចុះថ្ងៃទី ២០-១០ ដែលពេលនោះក្រុមហ៊ុន ជាភាគីដើមចោទ ហើយបានផ្តល់អាស័យដ្ឋាននេះជូនតុលាការ ដូច្នេះការតវ៉ាអំពីអាស័យដ្ឋានរបស់ឈ្មោះ ថាមិនត្រឹមត្រូវពីសំណាក់ក្រុមហ៊ុន ដែលមានលោក មេធាវីតំណាងដោយអាណត្តិ សរបញ្ជាក់ឲ្យឃើញថា ភាគីក្រុមហ៊ុន ទទួលស្គាល់ថា សាលក្រមរដ្ឋប្បវេណីលេខ ភ.ព.រ.រ ចុះថ្ងៃទី ២០-១០- របស់សាលាដំបូងរាជធានីភ្នំពេញ ពិតជាមានវិការៈ។

៤-តាមលិខិតជូនដំណឹង ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ លោកស្រីមេធាវីតំណាងឲ្យក្រុមហ៊ុន សុំឲ្យ ធនាគារកាថេយូណៃធីត ផ្តល់ពត៌មានពាក់ព័ន្ធនិងកម្ចីរបស់លោក ហើយនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ បានធ្វើលិខិតមួយផ្ញើជូន លោក ប្រធានក្រុមហ៊ុន ដោយបញ្ជាក់ពីបំណុលរបស់ លោក និងការដាក់បញ្ចាំបន្ទប់ខុនដូទាំង១០ បន្ទប់គឺៈបន្ទប់លេខ ដើម្បីធានាសំណងបំណុលអោយ ដូច្នេះ ក្រុមហ៊ុន ប្រាកដជាដឹងច្បាស់ថា ខុនដូទាំង១០បន្ទប់គឺៈបន្ទប់លេខ គឺជាទ្រព្យដែលកំពុងដាក់បញ្ចាំធានាបំណុលជាមួយ ។

តាមការទំនាក់ទំនងក្នុងសារអេឡិចត្រូនិច ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ របស់លោក បានផ្ញើជូនលោក ជាអគ្គនាយករងទី១ នៃ សាជីវកម្មធនាគារ គឺ ក្រុមហ៊ុន បានស្នើឲ្យ ធនាគារ សហការដើម្បីឲ្យក្រុមហ៊ុន អាចបង់សងកម្ចីរបស់លោក ដែលត្រូវបានផ្ទេរមកឲ្យក្រុមហ៊ុ ។ ហើយក្រុមហ៊ុន ទទួលស្គាល់ថា ខ្លួនបានទទួលប្រាក់ចំនួន អំពីកម្ចីរបស់លោក ។ ដូច្នេះ សារបញ្ជាក់ឲ្យឃើញថា ក្រុមហ៊ុន និងលោក ពិតជាមានទំនាក់ទំនងគ្នាក្នុងការធ្វើកម្ចីប្រាក់ពី ធនាគារ ដែលបានយក ខុនដូ១០ បន្ទប់ ដាក់ធានាបំណុល។

៥-នៅថ្ងៃទី ២២ ខែ សីហា ឆ្នាំ ក្រុមហ៊ុន បានប្ដឹងសុំរំលាយកិច្ចសន្យាទិញលក់ខុនដូទាំង១០បន្ទប់គឺៈបន្ទប់លេខ ជាមួយលោក ដោយពុំបានជូនដំណឹងឲ្យ សាជីវកម្មធនាគារ ដឹងដើម្បីចូលរួមក្នុងនីតិវិធីបណ្ដឹងជាមួយក្រុមហ៊ុនគាត់ឡើយ និងបានបិទបាំងព័ត៌មានអំពីកម្មវត្ថុនៃបណ្ដឹងគឺខុនដូទាំង១០បន្ទប់ ដែលកំពុងដាក់បញ្ចាំធានាបំណុលជាមួយ ធនាគារ មិនឲ្យតុលាការដឹង ដូច្នេះ ចំពោះសាលក្រមរដ្ឋប្បវេណីលេខ ភ.ព.រ.វ ចុះថ្ងៃទី ២០-១០- អ្នកដែលបាត់បង់ផលប្រយោជន៍ពិត ប្រាកដគឺ សាជីវកម្មធនាគារ ចំកាត់ មិនមែនលោក ទេ។

ក្រុមហ៊ុន ពិតជាបានឃុបខិតគ្នាជាមួយ លោក ធ្វើឲ្យប៉ះពាល់ផលប្រយោជន៍របស់ សាជីវកម្មធនាគារ ។

៦-ចុងចម្លើយឈ្មោះ អវត្តមាន ប៉ុន្តែតុលាការបានធ្វើការបញ្ជូនដីកាកោះ ទៅឲ្យចុងចម្លើយត្រឹមត្រូវតាមច្បាប់ហើយ រួមទាំងមាន ការចុះផ្សាយដីកាកោះ ជាសាធារណៈផង។

៧-សាលក្រមរដ្ឋប្បវេណីលេខ ភ.ព.រ.វ ចុះថ្ងៃទី ២០-១០- របស់សាលាដំបូងរាជធានីភ្នំពេញ បានចូលជាស្ថាពរ ដែលសាលក្រមនេះមានភាគីដើមចោទ ក្រុមហ៊ុន និងភាគីចុងចម្លើយឈ្មោះ ។ តាមសេចក្ដីថ្លែងចំណោមរបស់គូភាគីឃើញថា ភាគី សាជីវកម្មធនាគារ ពិតជាបាត់បង់ផលប្រយោជន៍ដោយការរួមគំនិតគ្នា រវាង ក្រុមហ៊ុន និងឈ្មោះ ។ ដូច្នេះ តតិយជន សាជីវកម្មធនាគារ មានមូលហេតុគ្រប់គ្រាន់ ដែលអាចឲ្យតុលាការចេញដីកាសម្រេចចាប់ផ្ដើមជំនុំជម្រះសារជាថ្មីបានតាមមាត្រា ៣១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

# ឧបសម្ព័ន្ធ៥

## សាលក្រមច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី

លេខ

ចុះថ្ងៃទី២៦-១០-

សាលក្រមរដ្ឋប្បវេណី

លេខ ភព.រ.វ

ចុះថ្ងៃទី ១១-៩-

-បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅបន្ទប់ជំនុំជម្រះទី២ នៅថ្ងៃទី ២៧-៨- វេលាម៉ោង១៤និង ៣០នាទីរសៀល ។

-កាលបរិច្ឆេទបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី ២៧-៨-

-កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី ១១-៩- ។

### ចៅក្រមជំនុំជំរះ

លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ។

### ក្រឡាបញ្ជីសវនាការ

លោក ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ ។

រវាងដើមចោទ ក្រុមហ៊ុន មាន ទីស្នាក់ការផ្លូវ ភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

ដោយមានឈ្មោះ និងឈ្មោះ ជាមេធាវីតំណាងដោយអាណត្តិ។

និងចុងចម្លើយ ធនាគារ

មានទីស្នាក់ការអគារលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ។

ដោយមានលោក ជាអគ្គនាយកធនាគារ ។

ដោយមានលោកស្រី ជាមេធាវីតំណាងដោយអាណត្តិ ។

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខៈ ចុះថ្ងៃទី ២៣-១២- របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសម្រេចលេខៈ ក្រVIញ ចុះថ្ងៃទី ១០-០៤- របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី៣ បានសម្រេចអនុញ្ញាតឲ្យចាប់ផ្តើមជំនុំជម្រះសាជាថ្មីលើសំណុំរឿងរដ្ឋប្បេណីលេខៈ ចុះថ្ងៃទី ១៤-១១- ដែលមានសាលក្រមរដ្ឋប្បវេណីលេខៈ ចុះថ្ងៃទី ២៣-១២ របស់សាលាដំបូង រាជធានីភ្នំពេញ។

-បានឃើញលិខិតឆ្លងដែនលេខៈ ចុះថ្ងៃទី ២៤-០៧ របស់លោក ដែនចេញដោយអាជ្ញាធរសហរដ្ឋអាមេរិក។

-បានឃើញលិខិតឆ្លងដែនលេខៈ ចុះថ្ងៃទី ២១-០៣- របស់លោកស្រី ដែលចេញដោយអាជ្ញាធរសហរដ្ឋអាមេរិក។

-បានឃើញដីកាបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ អយច ចុះថ្ងៃទី ១០-០៥ របស់អយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញកំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សីឈ្មោះ ចៅស៊ីម៉ាត់ ចុះថ្ងៃទី ១៧-០១-

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ចុះថ្ងៃទី ២៣-០៨ ។

-បានឃើញឯកសារជាភាសាអង់គ្លេស ចុះថ្ងៃទី ២២-០១ រវាងលោក លោកស្រី និងលោក ។

-បានឃើញឯកសារជាភាសាអង់គ្លេស ចុះថ្ងៃទី ២៥-០៥ រវាងលោក និងលោក ។

-បានឃើញសេចក្ដីសម្រេចសមាជិកភាគហ៊ុននៃក្រុមហ៊ុន ចុះថ្ងៃ ទី ២០-០៥- ។

-បានឃើញកិច្ចសន្យាខ្ចីប្រាក់រវាងលោក និងក្រុមហ៊ុន (អ្នកខ្ចី) និងធនាគារ (អ្នកផ្ដល់ឥណទាន)ចុះថ្ងៃទី ២៥-០៦- ។

-បានឃើញកិច្ចព្រមព្រៀងដាក់ធានារវាងលោក និងក្រុមហ៊ុន និងធនាគារ ចុះថ្ងៃទី ២៥-០៦- ។

-បានឃើញដីកាបញ្ជូនរបស់ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី រាជធានីភ្នំពេញ ចុះថ្ងៃទី ០២-០៧ ។

-បានឃើញលក្ខន្តិកៈក្រុមហ៊ុន ចុះថ្ងៃទី ១២-០១ ។

-បានឃើញលក្ខន្តិកៈក្រុមហ៊ុន ចុះថ្ងៃទី ២៩-០៧ ។

## អង្គហេតុ និងចំណុចវិវាទ

ក-ខ្លឹមសារសាលក្រមដែលទាមទារដោយភាគី:

ក.១-ដើមចោទទាមទារឲ្យតុលាការចេញសាលក្រម៖

១-ជំនុំជម្រះសាជាថ្មីចំពោះសាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ២៣-១២- លើសេចក្ដីសម្រេចទាំងមូល។

២-បង្គាប់ឲ្យចុងចម្លើយសងការខូចខាត រួមមានជម្ងឺចិត្ត ការខាតបង់ពេលវេលា និងសេវាមេធាវីចំនួន ឲ្យមកដើមចោទ។

៣-ឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្ដី។

ក.២-ចម្លើយតបរបស់ចុងចម្លើយ

សុំឲ្យលោក និងក្រុមហ៊ុន សងប្រាក់មកធនាគារតាមអំណាចសាលក្រមរដ្ឋប្បវេណីលេខ: ចុះថ្ងៃទី ២៣-១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដូច្នេះសុំឲ្យតុលាការច្រានចោលពាក្យបណ្ដឹងទាមទារឲ្យជំនុំជម្រះសាជាថ្មីចុះថ្ងៃទី ១៨-១០ របស់ក្រុមហ៊ុន និងសុំអនុវត្តបណ្ដោះអាសន្នលើសាលក្រមនេះ។

ខ-ការពន្យល់ត្រួសៗអំពីរឿងក្ដី:

-នៅថ្ងៃទី ១៨ ខែតុលា ឆ្នាំ ដើមចោទលោក តំណាងឲ្យក្រុមហ៊ុន បានដាក់ពាក្យបណ្ដឹងមកសាលាដំបូងរាជធានីភ្នំពេញ ប្ដឹងទាមទារឲ្យតុលាការជំនុំជម្រះសាជាថ្មីចំពោះសាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ២៣-១២- លើសេចក្ដីសម្រេចទាំងមូល ។

-នៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ បានចេញដីកាសម្រេចច្រានចោលពាក្យបណ្ដឹងទាមទារឲ្យជំនុំជម្រះសាជាថ្មីរបស់ឈ្មោះ តំណាងឲ្យក្រុមហ៊ុន តាមដីកាសម្រេចលេខ ត.រ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ

ដោយមានបណ្តឹងជំទាស់ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ប្រឆាំងចំពោះដីកាសម្រេចលេខ ត.រ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ សាលាឧទ្ធរណ៍បានសម្រេចសេចក្តីតាមដីកាសម្រេចលេខ ក្រVI ៣ ចុះថ្ងៃទី ១០-០៤- ដោយបានសម្រេចសេចក្តីលុបចោលដីកាសម្រេចច្រានបណ្តឹងទាមទារជំនុំជម្រះសាជាថ្មីលេខ ត.រ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ និងអនុញ្ញាតឲ្យចាប់ផ្តើមជំនុំជម្រះសារជាថ្មីលើសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ដែលមានសាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ២៣-១២- របស់សាលាដំបូងរាជធានីភ្នំពេញ ។

-ដើមចោទឈ្មោះ តំណាងឲ្យក្រុមហ៊ុន ដែលមានលោកស្រី និងឈ្មោះ មេធាវីតំណាងដោយអាណត្តិ បានថ្លែងការណ៍ថា កូនក្តីខ្លួនពុំបានខ្ចីលុយពីធនាគារ ចំនួន នោះទេ ។ ម្យ៉ាងទៀត ក្រុមហ៊ុន ក៏ពុំបានចាត់តាំងឲ្យលោក ទៅខ្ចីលុយពីធនាគារ ចំនួន ក្នុងនាមក្រុមហ៊ុននោះទេ ។ ការដែលលោក ខ្ចីលុយពីធនាគារ ចំនួន គឺជារឿងឯកជនរបស់លោក ដូច្នេះ ក្រុមហ៊ុន មិនត្រូវទទួលខុសត្រូវចំពោះបំណុលនេះទេ ។

-ចុងចម្លើយ ធនាគា ដែលមានលោកស្រី ជាមេធាវីតំណាងដោយអាណត្តិបានធ្វើសេចក្តីថ្លែងការណ៍តបថា លោក ពិតជាបានខ្ចីលុយពី ធនាគារ លើប្រាក់ដើមចំនួន ដោយបានចុះកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ដោយបានដាក់ប្រាតិភោគអចលនវត្ថុលេខ ភព ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ដែលមានទីតាំងស្ថិតនៅភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុន ។ ក្នុងការខ្ចីប្រាក់នេះ លោក ខ្ចីក្នុងនាមក្រុមហ៊ុន ដោយមានឯកសារសេចក្តីសម្រេចនៃសមាជិកភាគហ៊ុន នៃក្រុមហ៊ុន និងលិខិតបញ្ជាក់ទីតាំងអចលនវត្ថុដែលដាក់ប្រាតិភោគអំពីចៅសង្កាត់ ។

-លោក បានធ្វើសេចក្តីថ្លែងការណ៍តបថា ខ្លួនពិតជាបានខ្ចីលុយពីធនាគារ លើប្រាក់ដើមចំនួន ដោយបានចុះកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ដោយបានដាក់ប្រាតិភោគអចលនវត្ថុលេខ ភព ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ដែលមានទីតាំងស្ថិតនៅភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុន

ព្រោះពេលនោះរូបខ្លួនជាសមាជិកភាគហ៊ុនដែលមានតួនាទីជាអភិបាល ហើយខ្លួនជាអ្នកចាត់ចែងក្នុងក្រុមហ៊ុនដោយខ្វះលុយដើម្បីពង្រីកប្រតិបត្តិការក្រុមហ៊ុន ទើបម្ចាស់ភាគហ៊ុនទាំងអស់បានឯកភាពគ្នាឲ្យខ្លួនខ្ចីលុយពីធនាគារដោយបានធ្វើសេចក្តីសម្រេចនៃសមាជិកភាគហ៊ុននៃក្រុមហ៊ុន ក្នុងគោលបំណងឲ្យខ្លួនយកប័ណ្ណកម្មសិទ្ធិ អចលនវត្ថុលេខ ភព ដាក់បញ្ចាំហើយសមាជិកភាគហ៊ុនឈ្មោះ

និងឈ្មោះ ដែលជាប្ដីប្រពន្ធនិងគ្នាបានផ្ដិតមេដៃលើលិខិតនេះនៅចំពោះមុខចៅសង្កាត់ព្រែកលៀប ។

**សំអាងហេតុ**

តាមលទ្ធផលនៃការសាកសួរសាមីភាគី និងពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់យល់ឃើញថា:

១-តុលាការសម្រេចធ្វើការជំនុំជម្រះសារជាថ្មីលើសំណុំរឿងរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ តាមដីកាម្រេចលេខ ក្រ ញ ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ របស់សាលាឧទ្ធរណ៍ ។

២-នៅក្នុងនីតិវិធីត្រៀមក៏ដូចនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ភាគីដើមចោទ លោក តំណាងឲ្យក្រុមហ៊ុន ដែលមានមេធាវីតំណាងដោយអាណត្តិទទួលស្គាល់ថា លោក ពិតជាបានខ្ចីលុយពីធនាគារ លើប្រាក់ដើមចំនួន ដោយបានចុះកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ។ ប៉ុន្តែតំណាងឲ្យក្រុមហ៊ុន បានធ្វើការតវ៉ាលើអង្គហេតុថា ការខ្ចីលុយរបស់លោក ពុំមែនធ្វើឡើងក្នុងនាម ក្រុមហ៊ុន នោះទេ ព្រោះថាសមាជិកភាគហ៊ុន ឈ្មោះ និងឈ្មោះ មិនបានដឹងនិងឯកភាពឲ្យលោក ខ្ចីលុយនោះទេ ផ្ទុយទៅវិញលោក បានក្លែងបន្លំឯកសារសេចក្ដីសម្រេចនៃសមាជិកភាគហ៊ុននៃក្រុមហ៊ុន ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ដើម្បីយកអចលនវត្ថុទៅដាក់បញ្ចាំធានាបំណុលជាមួយធនាគារ ។

៣-លោក បានធ្វើសេចក្ដីថ្លែងការណ៍បំភ្លឺថា ក្នុងកំឡុងខែឧសភា ឆ្នាំ រូបខ្លួនជាសមាជិកភាគហ៊ុនដែលមានតួនាទីជាអភិបាល ហើយខ្លួនជាអ្នកចាត់ចែងក្នុងក្រុមហ៊ុន ដោយក្រុមហ៊ុនត្រូវការលុយដើម្បីពង្រីកអាជីវកម្មរបស់ខ្លួន សមាជិកភាគហ៊ុនទាំងអស់បានឯកភាពគ្នាខ្ចីលុយពីធនាគារដើម្បីពង្រីកដើមទុន ហើយបានធ្វើសេចក្ដីសម្រេចនៃសមាជិកភាគហ៊ុននៃក្រុមហ៊ុន ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ដោយឈ្មោះ និងឈ្មោះ បានផ្ដិតមេដៃចំពោះមុខចៅសង្កាត់ព្រមទាំងមានការចុះហត្ថលេខា និងបោះត្រាបញ្ជាក់របស់ចៅសង្កាត់ ដើម្បីឲ្យខ្លួនមានលទ្ធភាពយកអចលនវត្ថុរបស់ក្រុមហ៊ុនដែលមានប័ណ្ណកម្មសិទ្ធ អចលនវត្ថុលេខ ភព ទៅដាក់ប្រាតិភោគធានាបំណុលខ្ចីលុយពីធនាគារ ។ ហើយខ្លួនបានចុះកិច្ចសន្យាខ្ចីលុយក្នុងនាមក្រុមហ៊ុន ពីធនាគារ លើប្រាក់ដើមចំនួន នៅថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ។

៤-ធនាគារ ដែលមានលោកស្រី ជាអ្នកតំណាងដោយអាណត្តិបានធ្វើសេចក្ដីថ្លែងការណ៍ថា នៅថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ធនាគារ ពិតជាបានផ្ដល់កម្ចីឥណទានទៅឲ្យក្រុមហ៊ុន ដែលមាន លើទឹកប្រាក់ចំនួន ដោយបានដាក់ប្រាតិភោគអចលនវត្ថុលេខ ភព ចុះថ្ងៃទី២១

ខែធ្នូ ឆ្នាំ ដែលមានទីតាំងស្ថិតនៅភូមិ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុន

បន្ទាប់ពីធនាគារបានពិនិត្យឯកសារ សេចក្តីសម្រេចនៃសមាជិកភាគហ៊ុន នៃក្រុមហ៊ុន និងលិខិតបញ្ជាក់ទីតាំងអចលនវត្ថុដែលដាក់ប្រាតិភោគ អំពីចៅសង្កាត់ ដែលបញ្ជាក់ថា ម្ចាស់ភាគហ៊ុនទាំងអស់ នៃក្រុមហ៊ុន បានផ្តល់សិទ្ធិឱ្យលោក ក្នុងការខ្ចីប្រាក់ហើយអចលនវត្ថុដែលយកមកដាក់ប្រាតិភោគពិតជាកម្មសិទ្ធិរបស់ក្រុមហ៊ុន ។

៥-ភស្តុតាងជាឯកសារដែល ភាគីក្រុមហ៊ុន ដាក់ជូនតុលាការលិខិតឆ្លងដែនថតចម្លងរបស់ ឈ្មោះ និងឈ្មោះ តុលាការពិនិត្យឃើញថាមិនមានមូលដ្ឋានគ្រប់គ្រាន់ ដែលអាចបញ្ជាក់ថានៅថ្ងៃទី២០ ខែឧសភា ឆ្នាំ ឈ្មោះ និងឈ្មោះ មិនមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជានោះទេ ដោយហេតុថាឯកសារដាក់ជូនតុលាការ ជាឯកសារថតចម្លងដោយពុំ មានច្បាប់ដើមឱ្យតុលាការពិនិត្យផ្ទៀងផ្ទាត់បញ្ជាក់នូវការពិត ដែលជាហេតុធ្វើឱ្យតុលាការ ពុំមានមូលដ្ឋានអាចជឿបានថា ឯកសារថតចម្លងនេះពិតជាបានថតចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម និងបានថតគ្រប់ទំព័រ នៃលិខិតឆ្លងដែនរបស់អ្នកទាំងពីរ ។ ប៉ុន្តែផ្ទុយទៅវិញតាមភស្តុតាងជា ឯកសារចម្លើយរបស់សាក្សីឈ្មោះ ជាចៅសង្កាត់ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ នៅចំពោះមុខចៅក្រមស៊ើបសួរ ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ លោក បានបញ្ជាក់យ៉ាងច្បាស់ថា ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឈ្មោះ និងឈ្មោះ ពិតជាបានផ្តិតមេដៃ លើឯកសារសេចក្តីសម្រេចនៃមាជិកភាគហ៊ុន នៃក្រុមហ៊ុន នៅចំពោះមុខខ្លួន ហើយពេលនោះខ្លួនបានសួរបញ្ជាក់ និងបានពិនិត្យមើលឈ្មោះ អ្នកទាំងពីរនៅលើលិខិតឆ្លងដែន។

៦-ភស្តុតាងជាឯកសារដែល ភាគីក្រុមហ៊ុន ដាក់ជូនតុលាការ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ដែលបានបើកការចោទប្រកាន់ឈ្មោះ ពីបទក្លែងបន្លំ និងប្រើប្រាស់លិខិតក្លែង ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ តាមបញ្ញត្តិមាត្រា៦២៦ មាត្រា៦២៧ និងមាត្រា៦២៨ នៃក្រមព្រហ្មទណ្ឌ សំណុំរឿងព្រហ្មទណ្ឌ នេះត្រូវបានសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចសេចក្តី តាមសាលក្រមព្រហ្មទណ្ឌលេខ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ ដោយវិនិច្ឆ័យសេចក្តីឱ្យឈ្មោះ រួចខ្លួនពីបទចោទ បទក្លែងបន្លំ និងប្រើប្រាស់លិខិតក្លែង ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ ។

៧-នៅគ្រប់តំណាក់កាលនៃនីតិវិធីឈ្មោះ និងឈ្មោះ មិនបានចូលខ្លួនមកធ្វើសេចក្តីថ្លែងការណ៍បញ្ជាក់អំពីភស្តុតាង ថាពួកខ្លួនពិតជាបានឯកភាព ឬមិនបានឯកភាពឱ្យឈ្មោះ ខ្ចីលុយពិត

ធនាគារក្នុងនាមក្រុមហ៊ុន ប៉ុន្តែផ្ទុយ ទៅវិញ មេធាវីតំណាងដោយអាណត្តិ ឱ្យដើមចោទបានយកសេចក្តីថ្លែងការណ៍ជាលាយល័ក្ខអក្សរ របស់ឈ្មោះ និងឈ្មោះ ដាក់ជូនតុលាការក្នុងតំណាក់កាលនីតិវិធីត្រៀម ជាភាសាអង់គ្លេស ដែលតុលាការមិនអាចយកមកពិនិត្យពិចារណាបានដោយហេតុថា ភាសាដែលប្រើប្រាស់ក្នុងនីតិវិធីតុលាការ គឺជាភាសាខ្មែរ ។

៨-ភស្តុតាងជាឯកសារបញ្ជាក់ទទួលស្គាល់ ក្រុមហ៊ុន របស់ក្រសួងពាណិជ្ជកម្មលេខ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ , លក្ខន្តិកៈក្រុមហ៊ុន ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ និងឯកសារសេចក្តីសម្រេចនៃសមាជិកភាគហ៊ុននៃក្រុមហ៊ុន ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ បញ្ជាក់ថា លោក ជាសមាជិកភាគហ៊ុនដែលមានតួនាទីជាអភិបាល ហើយនៅថ្ងៃទី ២០ ខែឧសភា ឆ្នាំ ត្រូវបានសមាជិកភាគហ៊ុនទាំងអស់តែងតាំងតាមសេចក្តីសម្រេចនៃសមាជិកភាគហ៊ុននៃក្រុមហ៊ុន ឱ្យលោក តាងនាមជានីតិបុគ្គលជាតំណាងឱ្យក្រុមហ៊ុនក្នុងការចុះហត្ថលេខានៅចំពោះមុខអាជ្ញាធរពាក់ព័ន្ធដើម្បីដាក់បញ្ចាំប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ភព មានទំហំ ម៉ែត្រការ៉េ ។

៩-តាមសេចក្តីថ្លែងការណ៍របស់ភាគី និងភស្តុតាងជាឯកសារឃើញថា ដើមចោទក្រុមហ៊ុន ពុំមានភស្តុតាងធួនល្មមអាចបញ្ជាក់អំពីការទាមទាររបស់ខ្លួនបាន ដូច្នេះគប្បីតុលាការច្រានចោលការទាមទាររបស់ក្រុមហ៊ុន ។

១០-តាមសេចក្តីថ្លែងការណ៍របស់គូភាគី និងភស្តុតាងជាឯកសារឃើញថា លោក នៅតែទទួលស្គាល់កិច្ចសន្យាខ្ចីប្រាក់ជាមួយធនាគារ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ដែលពេលនោះខ្លួនជាតំណាងឱ្យក្រុមហ៊ុន ក្នុងការធ្វើកម្ចីឥណទានពីធនាគារ ដូច្នេះការសម្រេចសេចក្តីតាមសាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ២៣-១២- របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវហើយ ។

១១-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកចាញ់ក្តី។

## <u>សេចក្តីសំរេចបញ្ចប់</u>

១-ច្រានចោលពាក្យបណ្តឹងទាមទារជំនុំជម្រះសាជាថ្មីរបស់ដើមចោទឈ្មោះ ចុះថ្ងៃទី១៨-១០- តំណាងឱ្យក្រុមហ៊ុន ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខៈ ចុះថ្ងៃទី ២៣-១២- របស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការដដែល។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី ២៧-៨- ចំពោះមុខមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ, មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១១-៩- ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា:

«បានចំលងត្រឹមត្រូវតាមច្បាប់ដើម»

ភ្នំពេញ,ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ

**ក្រឡាបញ្ជី**

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**